# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal university of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាព ខណ្ឌចំការមន

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ភិក្ខុ **ឆួន ពិសិដ្ឋ**

កញ្ញា **ជួន ហេងវណ្ណារី**

ណែនាំដោយ

លោក **គាត គា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal university of Law and Economics**


**សារណាបញ្ចប់ការសិក្សា**

# ការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាព ខណ្ឌចំការមន

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ភិក្ខុ **ធួន ពិសិដ្ឋ**

កញ្ញា **ជួន ហេងវណ្ណារី**

ណែនាំដោយ

លោក **គាត គា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរឈ្មោះ **ធួន ពិសិដ្ឋ និង ជួន ហេងវណ្ណារី** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២៤ ឆ្នាំសិក្សា២០២០-២០២៤។ យើងខ្ញុំទាំងពីរសូមសម្តែងនូវគារវកិច្ចគោរពថ្លែងអំណរគុណ និងដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ៖

លោកអ្នកមានគុណទាំងបួន ដែលលោកបានខិតខំចិញ្ចឹមបីបាច់ និងថែរក្សាប្រកបដោយព្រហ្មវិហារធម៌ និងសង្គហៈធម៌លះបង់អស់កម្លាំងកាយចិត្តក្នុងការថែរក្សាកូនៗតាំងពីតូច រហូតដល់ធំ ព្រមទាំងផ្តល់នូវក្តីស្រឡាញ់ និងការអប់រំទូន្មានប្រៀនប្រដៅកូនៗឱ្យប្រព្រឹត្តតែអំពើល្អ សុចរិត ស្មោះត្រង់ ព្រមទាំងជម្រុញលើកទឹកចិត្តក្នុងការបញ្ជូនកូនៗឱ្យទទួលបានការអប់រំគ្រប់កម្រិត ឱ្យក្លាយជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អក្នុងសង្គមមិនតែប៉ុណ្ណោះតែងតែផ្តល់នូវការផ្គត់ផ្គង់គ្រប់បែបយ៉ាង ទាំងបច្ច័យទាំងបួន ផ្នែកសម្ភារៈសិក្សា និងខាងស្មារតីរហូតដល់យើងខ្ញុំទាំងពីរនាក់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនេះទាំងមូល។

សូមគោរពថ្លែងអំណរគុណផងដែរចំពោះ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង និងលោក លោកស្រីសាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់ដែលលោកបានយកចិត្តទុកដាក់ និងចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ បណ្តុះបណ្តាល និងពង្រឹងគុណភាពកម្មវិធីសិក្សាដល់និស្សិតគ្រប់ជំនាញប្រកបដោយប្រសិទ្ធិភាពការងារ ជាពិសេសជម្រុញលើកទឹកចិត្ត តម្រង់ទិសនិងបំពេញបន្ថែមនូវពុទ្ធិល្អៗដល់និស្សិតគ្រប់រូបព្រមទាំងយើងខ្ញុំទាំងពីរ ដើម្បីវិវត្តន៍ខ្លួនឱ្យក្លាយជាសសរទ្រូងរបស់សង្គម និងប្រទេសជាតិ។

សូមថ្លែងអំណរអរគុណជូនចំពោះ **ឯកឧត្តមអភិបាលនៃគណៈអភិបាល រាជធានីភ្នំពេញ និងលោកអភិបាលនៃគណៈអភិបាល ខណ្ឌចំការមន** ដែលបានអនុញ្ញាតឱ្យក្រុមសារណាយើងខ្ញុំបានចុះធ្វើការសិក្សាស្រាវជ្រាវឯកសារ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោក គាត គា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងកម្លាំងកាយចិត្ត ក្នុងការដឹកនាំកិច្ចការស្រាវជ្រាវមួយនេះ ដោយលោកបានផ្តល់ជាមតិល្អៗការត្រួសត្រាយផ្លូវ និងផ្តល់វិធីសាស្ត្រល្អៗ ដល់រូបយើងខ្ញុំទាំងពីរ រហូតទាល់តែទទួលបានសមិទ្ធផលមួយនេះ។

ជាចុងបញ្ចប់យើងខ្ញុំទាំងពីរសូមបួងសួង និងប្រសិទ្ធពរជ័យ ឱ្យជួបប្រទះតែភាពសុខដុមរមនាមានសុខភាពល្អ ប្រកបកិច្ចការងារអ្វីអោយទទួលបានតែភាពជោគជ័យគ្រប់ភារកិច្ច និងប្រកបនូវពុទ្ធិពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

អស់រយៈពេល៤ឆ្នាំ ដែលយើងខ្ញុំទាំងពីរនាក់បានចូលមកសិក្សានៅសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលជាគ្រឹះស្ថានអប់រំសាធារណៈរបស់រដ្ឋ។ នៅក្នុងសាកលវិទ្យាល័យនេះ គឺពិតជាសាកលវិទ្យាល័យមួយដ៏គួឱ្យចាប់អារម្មណ៍ ព្រោះសំបូរទៅដោយសាស្ត្រាចារ្យ ល្បីៗ ដែលមានបទពិសោធន៍គ្រប់គ្រាន់ក្នុងការបង្ហាត់បង្រៀន និងណែនាំសិស្សនិស្សិតឱ្យយល់ច្បាស់ ពីជំនាញ ដែលសិស្សនិស្សិតបានជ្រើសរើសយកមកសិក្សា ក្នុងនោះដែរ ចំពោះជំនាញដែលយើងខ្ញុំ ទាំងពីរ បានជ្រើសរើសយកមកសិក្សានោះ គឺជំនាញផ្នែកនីតិសាស្ត្រ។

ក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំទាំងពីរពិតជាមានក្តីសោមនស្សរីករាយជាខ្លាំង ដោយយើងខ្ញុំទាំងពីរនាក់ ទទួលបាននូវចំនេះដឹងជាច្រើន ទាំងផ្នែកទ្រឹស្តី និងការអនុវត្តនៅក្នុងផ្នែកនេះ។ ដោយចំណេះដឹង ដែលទទួលបាននេះហើយ ក៏បានជម្រុញឱ្យ ពួកយើងខ្ញុំធ្វើការសម្រេចចិត្តជ្រើសរើសយកការសរសេរ សារណាបញ្ចប់ការសិក្សានេះឡើង ដោយជ្រើសរើសយកប្រធានបទ "**ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខណ្ឌចំការមន**" នេះមកធ្វើជាប្រធានបទក្នុងការស្រាវជ្រាវ ដើម្បីធ្វើជាជំនួយស្មារតី ក៏ដូចជាឯកសារសិក្សាបន្ថែមសម្រាប់និស្សិតជំនាន់ក្រោយ អ្នកស្រាវជ្រាវ ឬអ្នកដែលចង់ស្វែងយល់ពីការ រៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពរបស់ខណ្ឌចំការមន ។

យ៉ាងណាមិញប្រសិនបើការស្រាវជ្រាវលើប្រធានបទនៃសារណាមួយនេះ នៅមានចំនុចខ្វះចន្លោះ ពាក្យពេចន៍ និងអត្ថន័យខ្លឹមសារ សូមលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ មេត្តាខន្តីអភ័យទោសដល់ការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំផង ហើយក្រុមយើងខ្ញុំមានសេចក្តីរីករាយយ៉ាងក្រៃលែង ក្នុងការទទួលនូវយកការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ ដើម្បីរួមចំណែកក្នុងការកែលម្អកិច្ចការស្រាវជ្រាវមួយនេះអោយមានភាពល្អប្រសើរ។

# មាតិកា


**សេចក្តីផ្តើម** ............................................................ ១


## ជំពូកទី១

## ការរៀបចំសណ្តាប់ធ្នាប់ខណ្ឌចំការមន


**១.១ ទិដ្ឋភាពទូទៅរបស់ខណ្ឌ** ............................................................ ៣

១.១.១ ទីតាំងភូមិសាស្ត្រ ............................................................ ៣

**១.២ បុព្វហេតុដែលនាំឱ្យមានការរៀបចំសណ្តាប់ធ្នាប់** ............................................................ ៣

១.២.១ កំណើនប្រជាជន ............................................................ ៤

១.២.២ ភាពក្រីក្រ ............................................................ ៤

១.២.៣.ចរាចរណ៍ ............................................................ ៥

១.២.៤ សន្តិសុខ និងសណ្តាប់ធ្នាប់ ............................................................ ៥

**១.៣ រចនាសម្ព័ន្ធខណ្ឌ** ............................................................ ៥

១.៣.១ ក្រុមប្រឹក្សាខណ្ឌ ............................................................ ៦

១.៣.២ គណៈអភិបាលខណ្ឌ ............................................................ ៧

**១.៤ បច្ចុប្បន្នភាពនៃការរៀបចំសណ្តាប់ធ្នាប់** ............................................................ ៩

១.៤.១ ការរៀបចំប្រព័ន្ធបង្ហូរទឹក និងសំរាម ............................................................ ៩

១.៤.២.ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ............................................................ ១២

១.៤.៣.ការរៀបចំសំណង់ និងលំនៅដ្ឋាន ............................................................ ១៣

១.៤.៤.ការរៀបចំរបៀបរៀបរយ ............................................................ ១៦

**១.៥ ទិសដៅអនាគតនៃការរៀបចំសណ្តាប់ធ្នាប់** ............................................................ ១៨

១.៥.១.ការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន ............................................................ ១៨

១.៥.២.ការអភិវឌ្ឍលើបរិស្ថាន និងសំណល់ ............................................................ ២០

១.៥.៣.ការអភិវឌ្ឍលើវិស័យដីធ្លី ............................................................ ២២

១.៥.៤.ការអភិវឌ្ឍលើវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ............................................................ ២២

# ជំពូកទី២

## ការរៀបចំសោភ័ណភាពខណ្ឌចំការមន


**២.១ សោភ័ណភាពពេលថ្ងៃ**..........២៤

២.១.១ ការដាំដើមឈើតាមដងផ្លូវ..........២៤

២.១.២ ការរៀបចំសំណង់អគារ..........២៥

២.១.៣ ការរៀបចំចរាចរណ៍តាមដងផ្លូវ..........២៦

**២.២ សោភ័ណភាពពេលយប់**..........២៧

២.២.១ ការដាំបង្គោលភ្លើងអគ្គិសនី..........២៨

២.២.២ ការបំពាក់ភ្លើងចំរុះពណ៌តាមសួនច្បារ និងទីកន្លែងសាធារណៈ..........២៨

**២.៣.វិស័យទេសចរណ៍**..........៣០

២.៣.១ តំបន់ទេសចរណ៍វប្បធម៌..........៣១

២.៣.២ តំបន់ទេសចរណ៍ធម្មជាតិ..........៣២

**២.៤ បញ្ហាបរិស្ថាន និងដំណោះស្រាយ**..........៣២

២.៤.១.ការបំពុលទឹក និងដំណោះស្រាយ..........៣៣

២.៤.២.ការបំពុលខ្យល់ និងដំណោះស្រាយ..........៣៥

២.៤.៣.ការបំពុលដោយសំលេង និងដំណោះស្រាយ..........៣៧

២.៤.៤.ការបំពុលដោយសំណល់រឹង រាវ និងដំណោះស្រាយ..........៣៨

២.៤.៥.ការបំពុលដី និងដំណោះស្រាយ..........៤០

**សេចក្តីសន្និដ្ឋាន**..........៤៣

**អនុសាសន៍**..........៤៤

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅតាមបណ្តាប្រទេសក្នុងតំបន់ក៏ដូចជានៅលើពិភពលោក ការប្រែប្រួលនៃការរស់នៅកាន់តែកើនឡើង ព្រមទាំង មានតម្រូវការកាន់តែច្រើនពីមួយថ្ងៃទៅមួយថ្ងៃ។ ហេតុដូច្នេះចាំបាច់ត្រូវរៀបចំប្រទេសក៏ដូចជាទីក្រុង និងតាមបណ្តាលខណ្ឌឱ្យមាន សណ្តាប់ធ្នាប់ សុវត្ថិភាព សន្តិសុខ អនាម័យ ព្រមទាំងសោភ័ណភាព។ យ៉ាងណាមិញក្រោយពេលប្រទេសកម្ពុជា បានរួចផុតពីសម័យកម្ពុជាប្រជាធិបតេយ្យ និងមានការបង្រួបបង្រួមជាតិឡើងវិញក្រោយថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩ ព្រមទាំងធ្វើការកសាងប្រទេសពីបាតដៃទទេមករហូតដល់បច្ចុប្បន្ន រួមមានការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ វត្តអារាម ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត និងការរៀបចំក្នុងរាជធានីភ្នំពេញ ដែលជាបេះដូងរបស់ប្រទេសឱ្យមាន ភាពស្រស់បំព្រងទាំងសោភ័ណភាពបរិស្ថាន និងបរិយាកាស។ ម្យ៉ាងទៀតតាមរយៈការរីកចម្រើនលូតលាស់ឥតឈប់ឈរលើ វិស័យអចលនវត្ថុ លំនៅដ្ឋាន និងហេដ្ឋារចនាសម្ពន្ធ័នានា បានធ្វើអោយទីក្រុងជាពិសេសនៅតាមបណ្តាលខណ្ឌ មានការរីកចម្រើនឆ្ពោះទៅមុខជាលំដាប់។ ក្នុងនោះដែរដើម្បីឱ្យ ខណ្ឌមួយមានការប្រកួតប្រជែងនៅក្នុងក្រុងមួយបាន ចាំបាច់យើងសិក្សាសំខាន់លើចំណុចចម្បងមួយចំនួនទៀតសោតរួមមានដូចជា ការរៀបចំហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រក្នុងខណ្ឌ ការរៀបចំទុកដាក់នូវកាកសំណល់ ការរៀបចំសន្តិសុខសណ្តាប់ ការរៀបចំចិញ្ចើមផ្លូវ ការរៀបចំសោភ័ណភាពក្នុងខណ្ឌ មានការដាក់បង្គោលភ្លើងបំភ្លឺផ្លូវនាពេលរាត្រី ដែលធ្វើអោយការរៀបចំខណ្ឌប្រកបដោយចីរភាព។ ដោយគិតឃើញពីកត្តា អស់ទាំងនេះហើយ ទើបបានយើងខ្ញុំសម្រេចជ្រើសរើសសរសេរពីការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាព របស់ខណ្ឌចំការមន។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីធ្វើការសិក្សាឱ្យមានលក្ខណៈស៊ីជម្រៅ និងមានភាពកាន់តែច្បាស់លាស់ទៅលើប្រធាន បទសារណាខាងលើ យើងខ្ញុំបានលើកឡើងនូវចំណោទបញ្ហាមួយចំនួន មកធ្វើការបកស្រាយ ដែលបញ្ហាទាំងនោះរួមមានៈ តើបុព្វហេតុអ្វីខ្លះដែលនាំឱ្យមានការរៀបចំខណ្ឌចំការមន? តើគួរធ្វើយ៉ាងដូចម្តេចដើម្បីរៀបចំខណ្ឌចំការមនឱ្យមានសណ្តាប់ធ្នាប់ និងសោភ័ណភាព? និងបច្ចុប្បន្នភាពនៃការអភិវឌ្ឍនទៅលើវិស័យសំណង់និងលំនៅដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធ សោភ័ណភាពបរិស្ថានរស់នៅល្អគ្មាន បំពុលផ្សេងៗ និងវិធានការដោះស្រាយនៃការបំពុលទាំងនោះ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះគោលបំណងក្នុងការយកប្រធានបទ ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពក្នុងខណ្ឌចំការមន យកមកសរសេរជាសារណា សម្រាប់បញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ គឺយើងខ្ញុំចង់បង្ហាញឱ្យ

ឃើញពី សក្តានុពលរបស់ខណ្ឌចំការមន ពីព្រោះខណ្ឌនេះត្រូវបានគេចាត់ទុកថាជាខណ្ឌមួយដ៏មានប្រជាប្រិយភាពបំផុតហើយវា គឺជាតំបន់ពាណិជ្ជកម្មចំកណ្តាលទីក្រុងភ្នំពេញដែលជាបេះដូងនៃព្រះរាជាណាចក្រកម្ពុជា។ បន្ថែមពីនោះទៅទៀតតំបន់នេះគឺ បណ្តុំទៅដោយស្ថាបត្យកម្មប្រណិតៗ អគារពាណិជ្ជកម្ម ផ្សារទំនើប ហាងលក់ទំនិញ ជាច្រើនដែលផ្តល់ភាពងាយស្រួលក្នុងការរស់នៅ និងបំពេញនូវរាល់តម្រូវការជាច្រើនដូចជា ភោជនីយដ្ឋាន កន្លែងកម្សាន្ត ផងដែរ។ លើសពីនេះទៅទៀត គោលបំណងនៃការបង្កើតស្នាដៃស្រាវជ្រាវនេះឡើង គឺមានបំណងក្នុងការជួយជម្រុញឱ្យមាន ការអភិវឌ្ឍន៍ជាពិសេសការរៀបចំ ឱ្យមានសណ្តាប់ធ្នាប់ល្អ និងសោភ័ណភាពរស់នៅស្រស់បំព្រងនៅក្នុងខណ្ឌ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

រាល់ការសិក្សាស្រាវជ្រាវទាំងអស់ គឺសុទ្ធសឹងតែមានគោលបំណងនៅក្នុងការស្រាវជ្រាវ។ ចំណែកការសិក្សាស្រាវជ្រាវដែលទាក់ទងនឹង ការរៀបចំខណ្ឌចំការមន ឱ្យមានសណ្តាប់ធ្នាប់ និងសោភ័ណភាព គឺយើងខ្ញុំចង់បកស្រាយ និងបង្ហាញអំពីយន្តការ ដែលទាក់ទងនឹងការរៀបចំ សណ្តាប់ធ្នាប់ និងសោភ័ណភាពក្នុងខណ្ឌមួយនេះតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ គឺមានសារៈសំខាន់ណាស់ដល់មិត្តនិស្សិត និងមិត្ត អ្នកអានអ្នកស្រាវជ្រាវ សាធារណៈជនទាំងអស់ឱ្យបានយល់ដឹងកាន់តែស៊ីជម្រៅអំពីការរៀបចំ ផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍន៍នៅក្នុងទីក្រុង ដើម្បីធ្វើយ៉ាងណាឱ្យ ខណ្ឌចំការមនមាន សណ្តាប់ធ្នាប់ និងសោភ័ណភាព។ និងចូលរួមចំណែកក្នុងការជម្រុញឱ្យការអភិវឌ្ឍន៍បន្ថែមទៀត។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

សម្រាប់ការសិក្សាស្រាវជ្រាវចំពោះប្រធានបទនេះគឺ យើងខ្ញុំបានស្វែងរកឯកសារដែលពាក់ព័ន្ធនានា នៅក្នុងបណ្ណាល័យនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ការស្នើសុំឯកសារពីសាលាខណ្ឌចំការមន និងតាមរយៈប្រព័ន្ធអ៊ីនធឺណែត គេហទំព័រផ្សេងៗ ដោយក្នុងនេះយើងខ្ញុំបាន ប្រមូលផ្តុំឯកសារទាំងនោះយកមកវិភាគ និងសរសេរជាសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

បន្ទាប់ពីយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ និងពិចារណាទៅលើប្រធានបទ“ ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខណ្ឌចំការមន ”រួចមក យើងខ្ញុំទាំងពីរបានសម្រេចធ្វើការបែងចែកចេញជា ២ ជំពូក មានដូចតទៅ៖

- **ជំពូកទី ១ ការរៀបចំសណ្តាប់ធ្នាប់ក្នុងខណ្ឌចំការមន**
- **ជំពូកទី ២ ការរៀបចំសោភ័ណភាពក្នុងខណ្ឌចំការមន**

# ជំពូកទី ១

# ការរៀបចំសណ្ដាប់ធ្នាប់ខណ្ឌចំការមន

# ជំពូកទី ១

# ការរៀបចំសណ្តាប់ធ្នាប់ខណ្ឌចំការមន

## ១.១ ទិដ្ឋភាពទូទៅរបស់ខណ្ឌ

ខណ្ឌចំការមន គឺជាខណ្ឌមួយស្ថិតក្នុងចំណោមខណ្ឌទាំង១៤ នៃរាជធានីភ្នំពេញ ដែលមានព្រំប្រទល់ខាង កើតទល់នឹងខណ្ឌច្បារអំពៅខ័ណ្ឌដាច់ដោយដងទន្លេបាសាក់ ខាងលិចទល់នឹងខណ្ឌបឹងកេងកង ខាងត្បូងទល់នឹងខណ្ឌមានជ័យ ចំណែកខាងជើងទល់នឹងខណ្ឌដូនពេញ។

### ១.១.១ ទីតាំងភូមិសាស្ត្រ

រាជធានីភ្នំពេញបាន ចែកជា ១៤ ខណ្ឌ។ ខណ្ឌចំនួន ៥ បានចាត់ទុកថាជាខណ្ឌខាងក្នុងរាជធានី ភ្នំពេញ មានដូចជាខណ្ឌដូនពេញ ខណ្ឌចំការមន ខណ្ឌបឹងកេងកង ខណ្ឌទួលគោក និងខណ្ឌ៧មករា។ ខណ្ឌទាំង៥ នេះមានចម្ងាយប្រមាណជា ៣,៥គីឡូម៉ែត្រ ពីចំណុចកណ្តាលនៃរាជធានីភ្នំពេញ ហើយមានផ្ទៃដី ៤០គីឡូម៉ែត្រការ៉េ ឬស្មើនឹង៤% នៃផ្ទៃដីរាជធានី ភ្នំពេញទាំងមូល។ ខណ្ឌ៩ ផ្សេងទៀតចាត់ទុកថាជា ខណ្ឌខាងក្រៅនៃរាជធានីភ្នំពេញ ដែលមានចម្ងាយ-ប្រហែល ២០គីឡូម៉ែត្រ ពីចំណុចកណ្តាលនៃរាជធានីភ្នំពេញ។ ខណ្ឌចំការមន គឺជាខណ្ឌមួយដែលស្ថិតនៅកណ្តាលរាជធានីភ្នំពេញ ដែលមានសាលាខណ្ឌស្ថិតនៅកោះពេជ្រ ផ្ទះលេខ៥៤៨ បុរីអេលីតថោន ផ្លូវញ៉ូគុន ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន។

បច្ចុប្បន្នខណ្ឌចំការមនមាន សង្កាត់ចំនួន០៥ ភូមិចំនួន៣៨ភូមិ ២០៥ក្រុម និងមានផ្ទៃដីទំហំ ៧.៤២២ គីឡូម៉ែត្រការ៉េ។ ខណ្ឌមានប្រជាពលរដ្ឋសរុបចំនួន ៤៩.០៨៨នាក់ ស្រី២៤.៧៥២នាក់ ខណ្ឌមានដងស៊ីតេប្រជាជនរស់នៅ ៦.៦១៣នាក់/គម២។ ខណ្ឌចំការមនគឺជា តំបន់ពាណិជ្ជកម្ម សេវាកម្ម សិប្បកម្ម ទេសចរណ៍ និងជាតំបនស្នាក់នៅផងដែរ។[1]

## ១.២ បុព្វហេតុដែលនាំឱ្យមានការរៀបចំសណ្តាប់ធ្នាប់

ដោយផ្អែកតាមទីតាំងភូមិសាស្ត្រខាងលើខណ្ឌចំការមនគឺជាខណ្ឌដែលស្ថិតនៅកណ្តាលទីក្រុងភ្នំពេញ ដែលសម្បូរទៅដោយ អគារពាណិជ្ជកម្ម ស្ថាប័នរបស់រដ្ឋ អគារលំនៅដ្ឋាន ផ្សារទំនើប វត្តអារាម មន្ទីរពេទ្យ សាលារៀន និងសំណង់អគារតូច ធំ ជាច្រើនជាពិសេសគឺជា ខណ្ឌដែលមានប្រជាពលរដ្ឋរស់នៅច្រើននិងមានគ្រប់និន្នាការចម្រុះ ទាំងនេះហើយទើបធ្វើឱ្យ ការរៀបចំសន្តិសុខសណ្តាប់ធ្នាប់ ក្នុងខណ្ឌត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំងតាមរយៈ ការខិតខំប្រឹងប្រែងធ្វើយ៉ាងណារក្សាឱ្យបាននូវសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់

[1] កម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌចំការមន

ជូនប្រជាពលរដ្ឋទាំង នៅមូលដ្ឋាន ក្រុម ផ្ទាល់ និងភ្ញៀវទេសចរណ៍ដែលអញ្ជើញមកទស្សនា បានយ៉ាងល្អប្រសើរផងដែរ។ ទោះបីជាមានការខិតខំ ប្រឹងប្រែងយ៉ាងនេះក្ដីបញ្ហាសន្តិសុខសណ្ដាប់ធ្នាប់ក៏នៅតែជាបញ្ហាចោទមួយចំនួនផងដែរ ដោយសារតែការយល់ដឹង របស់ប្រជាពលរដ្ឋមួយចំនួននៅមានកម្រិត ដែលទាក់ទងទៅនឹងច្បាប់ និងបទប្បញ្ញត្តិមួយចំនួនទៀតដែលពាក់ព័ន្ធ នឹងច្បាប់ស្ដីពីច្បាប់ចរាចរណ៍ផ្លូវគោក ច្បាប់ស្ដីពីផ្លូវថ្នល់ ផែនការណែនាំស្ដីពីការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព ច្បាប់ និងបទដ្ឋានគតិយុត្តដែលអនុវត្តក្នុងវិស័យនគរូបនីយកម្ម និងសំណង់ ជាពិសេសកត្តា កំណើនប្រជាជន និងកត្តាចរាចរណ៍ជាដើម។

### ១.២.១ កំណើនប្រជាជន

ជាក់ស្ដែង ផ្អែកតាមការជំរឿនប្រជាជនកម្ពុជានៅឆ្នាំ២០១៩ មានប្រជាជនសរុបប្រមាណចំនួន ១៥,៦ លាននាក់ និងមានគ្រួសារសរុប៣,៦លានគ្រួសារ គឺមានការកើនឡើង ធៀបនឹងឆ្នាំ២០០៨ ដែលមានប្រជាជនសរុប១៣,៤លាននាក់ និងគ្រួសារចំនួន២,៨លានគ្រួសារ ហើយនិងនៅឆ្នាំ២០១៤ មានចំនួន ប្រជាជនសរុប ១៤,៨លាននាក់ និងគ្រួសារចំនួន ៣,៣លានគ្រួសារ តែប៉ុណ្ណោះ។ ផ្អែកតាម ទិន្នន័យនេះ ចំនួនគ្រួសារបានកើនឡើងជាមធ្យមប្រមាណជាង២% ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០២២។ ចំនួនប្រជាជនកម្ពុជាត្រូវបានប៉ាន់ស្មានមានកំណើនដល់ជាង១៧លាននាក់ ដែលមានប្រមាណ៣,៩លានគ្រួសារ នៅឆ្នាំ២០២៣ ហើយនឹងបានរំពឹងថានៅមានកំណើនដល់ជិត១៩លាននាក់នៅឆ្នាំ២០៣០។ នៅក្នុងបណ្ដារាជធានីខេត្តទាំងអស់របស់ប្រទេសកម្ពុជា គេសង្កេតឃើញថា រាជធានីភ្នំពេញមានកំណើន ប្រជាជនច្រើនជាងគេ ដែលមានចំនួនរហូតដល់ ២.១២៩.៣៧១ នាក់ ស្មើនឹង ១៣,៩% នៃប្រជាជនសរុប។[2]

### ១.២.២ ភាពក្រីក្រ

អនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្ដីពីការកាត់បន្ថយភាពក្រីក្រជាបណ្ដើរៗ ស្របតាមយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៤ រដ្ឋបាលខណ្ឌបានយកចិត្តទុកដាក់រៀបចំផែនការសកម្មភាព លើវិស័យសង្គមកិច្ចចូលរួម អនុវត្តលើកកម្ពស់ សុខុមាលភាពជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទនៅក្នុងមូលដ្ឋានខណ្ឌ ទាំងស្មារតីនិងសម្ភារៈ ព្រមទាំងបង្កលក្ខណៈផ្ដល់សេវាសង្គមកិច្ច បានលទ្ធផលគួរជាទីកត់សំគាល់។ រយៈកាលកន្លងមកនេះ ដោយបង្កើតឱ្យ មានយន្តការកម្មវិធីនានា ដើម្បីផ្ដល់សេវាសង្គមកិច្ចជួយឧបត្ថម្ភគាំទ្រដល់ជនរងគ្រោះ និងងាយរងគ្រោះ។ ទោះបីមានការខិតខំយ៉ាងនេះក្ដី ក៏នៅតាមដងវិថី ឬទីផ្សារមួយចំនួននៅតែមានជនអនាថា ឬកុមារដើរសុំទាន នៅពេលយប់តាមដងវិថី និងសួនច្បារសាធារណៈមានជនខិលខូចមួយចំនួន យកទី

[2] ស្ថិតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩

តាំងទាំងនោះជាកន្លែងទំនាក់ទំនង គ្នាក្នុងគោលបំណងប្រព្រឹត្តអំពីអាណាចារ និងជួញដូរផ្លូវភេទ ដែលធ្វើឱ្យប៉ះពាល់ប្រពៃណីល្អរបស់សង្គមខ្មែរ។[3]

### ១.២.៣.ចរាចរណ៍

ស្របពេលដែលរាជធានីភ្នំពេញកំពុងតែមានភាពរីកចម្រើនស្ទើរគ្រប់វិស័យពិតមែនក៏ដោយ ក៏បញ្ហាមួយត្រូវបានលើកឡើងជាផលវិបាកនិងជាកត្តាសំខាន់ដែលរដ្ឋកំពុងតែយក ចិត្តទុកដាក់ដោះស្រាយនោះគឺ បញ្ហាកកស្ទះចរាចរណ៍។ កត្តាមួយដែលត្រូវបានគេតែងតែលើកឡើងថា ជាកត្តាសំខាន់បំផុតដែលបណ្តារឱ្យមានការកកស្ទះចរាចរណ៍នោះ គឺឥរិយាបថរបស់អ្នកប្រើប្រាស់ផ្លូវផ្ទាល់។ អ្នកបើកបរមួយចំនួនពុំបានយល់ដឹងពីច្បាប់ចរាចរណ៍នោះ ឡើយ ដោយអ្នកបើកបរខ្លះគ្មានបណ្ណបើកបរ ខ្លះមិនស្គាល់ពីសិទ្ធិអាទិភាពរបស់ខ្លួននៅលើដងវិថី ខ្លះបើកបរបញ្ច្រាសទិស ខ្លះមិនគោរពភ្លើងសញ្ញាចរាចរណ៍ជាដើម។ ការបើកបរដោយមិនមានទំនួលខុសត្រូវ មិនចេះអធ្យាស្រ័យ និងមិនបានសិក្សាស្វែងយល់ពីផលប៉ះពាល់ដែលខ្លួនយើងម្នាក់ៗអាច នឹងបង្កឱ្យមានការខូចខាត ឬគ្រោះថ្នាក់អ្នកដទៃនោះ បង្កើតឱ្យមានបរិយាកាសអាប់អួរនិងគួរឱ្យស្អប់ ខ្ពើមជាទីបំផុតដែលទង្វើនោះមិនគួរឱ្យកើតមានឡើយនៅក្នុងសង្គម។ ទាក់ទងនឹងបញ្ហាការកកស្ទះចរាចរណ៍នេះដែលរាជរដ្ឋាភិបាលកម្ពុជាក៏ដូចជារដ្ឋបាលរាជធានីភ្នំពេញ បានខិតខំរកដំណោះស្រាយជូនប្រជាពលរដ្ឋ មានដូចជា សេវារថយន្តក្រុងសាធារណៈ សាងសង់ស្ពានអាកាសធំៗ និងធ្វើការពង្រីកផ្លូវមួយចំនួន។

### ១.២.៤ សន្តិសុខ និងសណ្តាប់ធ្នាប់

នៅក្នុងខណ្ឌមួយ ដែលមានការរស់នៅប្រកបទៅដោយចីរភាពបានលុះត្រាតែថា នៅក្នុងភូមិសាស្ត្រមួយនោះប្រកបដោយសន្តិសុខ និងសណ្តាប់ធ្នាប់។ បច្ចុប្បន្នរដ្ឋបាលខណ្ឌចំការមន មានការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើបញ្ហា សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ព្រោះជាការងារដ៏សំខាន់ដែលត្រូវតែយកចិត្តទុកដាក់ពង្រឹង និងមានវិធានការយ៉ាងម៉ឺងម៉ាត់ដើម្បីអនុវត្តតាមគោលនយោបាយ «ភូមិ-សង្កាត់មានសុវត្ថិភាព» ដែលជាគោលនយោបាយដ៏មានសារៈសំខាន់ដែលរដ្ឋបាលខណ្ឌ បានយកចិត្តទុកដាក់ ដើម្បីប្រមូលអស់នូវកំលាំងសរុប និងមធ្យោបាយសរុបធ្វើយ៉ាងណាឱ្យភូមិ សង្កាត់គ្មានសកម្មភាព លួចឆក់ ប្លន់គ្រប់ប្រភេទ គ្មានការផលិត ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ គ្មានអំពើអនាចារ ការជួញដូរស្ត្រីនិងកុមារ និងអំពើហិង្សាក្នុងគ្រួសារ គ្មានក្មេងទំនើងនិងការលេងល្បែងស៊ីសង និងគ្មានការប្រើប្រាស់ អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។[4]

## ១.៣ រចនាសម្ព័ន្ធខណ្ឌ

រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី២ នៃរដ្ឋសភាបានសម្រេចចិត្តដាក់ឱ្យអនុវត្តនូវកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅថ្នាក់ឃុំ សង្កាត់ តាមរយៈការដាក់ចេញច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការរៀបចំ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅឆ្នាំ២០០១ និងបានរៀបចំបោះឆ្នោតជ្រើសរើសក្រុម

[3] កម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌចំការមន

[4] កម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌចំការមន

ប្រឹក្សា ឃុំ សង្កាត់អាណត្តិទី០១ នៅឆ្នាំ២០០២។ ដោយមានបទពិសោធន៍ជោគជ័យចំពោះការអនុវត្តនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចពង្រីកវិសាលភាពនៃ ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅថ្នាក់ក្រោមជាតិទាំងមូល ដោយបានដាក់ចេញនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នៅឆ្នាំ២០០៨។[5]

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បានកំណត់គោលដៅយុទ្ធសាស្ត្រ នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជាដូចខាងក្រោមៈ

- ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន
- ជំរុញការអភិវឌ្ឍនៅមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។

លើសពីនេះទៀត ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវា សាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ការិយាល័យ អង្គភាពជំនាញនានាដែលពីមុន គឺជាខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននៅថ្នាក់ខណ្ឌត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងរដ្ឋបាលខណ្ឌ តាមរយៈអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាល ខណ្ឌនៃរាជធានីភ្នំពេញ ដែលចូលជាធរមានចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០។

### ១.៣.១ ក្រុមប្រឹក្សាខណ្ឌ

បណ្តាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួនដែលត្រូវបានជ្រើសរើសឡើងតាមការបោះឆ្នោតអសកល។[6] ក្រុមប្រឹក្សាមានអាណត្តិ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មី ចូលកាន់តំណែង។ អាណត្តិរបស់ក្រុមប្រឹក្សាត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានិង ផុតកំណត់ថ្ងៃបោះឆ្នោតបន្ទាប់។[7] ក្រុមប្រឹក្សានីមួយៗ ត្រូវមានប្រធានម្នាក់ ដោយប្រធានក្រុមប្រឹក្សាគឺ ជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេ នៅ ក្នុងក្រុមប្រឹក្សា។ ក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សាប្រធានក្រុម ប្រឹក្សា ត្រូវជ្រើសរើសយកបេក្ខជនដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជន និងមានសំឡេងឆ្នោត បានការច្រើនជាងគេ។[8]

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការ បង្កើតការជំរុញ និង ការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យព្រមទាំងដើម្បីបំពេញ មុខងារភារកិច្ចដែលបានប្រគល់។ ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែក តាមកត្តាប្រជារាស្ត្រ និង កត្តាភូមិសាស្ត្រ។[9]

---

[5] សៀវភៅ ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ ទំព័រទី១

[6] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២៣ ឧសភា ២០០៨,មាត្រា១៤

[7] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២៣ ឧសភា ២០០៨,មាត្រា១៥

[8] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២៣ ឧសភា ២០០៨,មាត្រា១៧

[9] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២៣ ឧសភា ២០០៨,មាត្រា១៨

### ១.៣.២ គណៈអភិបាលខណ្ឌ

គណៈអភិបាលខណ្ឌរួមមាន អភិបាល០១រូប និងអភិបាលរងចំនួន០៦រូប។[10] អភិបាល និងអភិបាលរងមានអាណត្តិការងារមិនលើសពីបួន(៤)ឆ្នាំ និងអាចត្រូវបានតែងតាំងបានបួន(៤)ឆ្នាំទៀតសម្រាប់អាណត្តិទី២របស់ខ្លួននៅក្នុងដែនសមត្ថកិច្ចដដែល។[11] អភិបាលខណ្ឌ ត្រូវតែងតាំងឡើងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយត្រូវធ្វើការជ្រើសរើសពីក្នុងចំណោម មន្ត្រីរាជការស៊ីវិលទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឬក្រៅក្របខ័ណ្ឌក្រសួងមហាផ្ទៃ។ ដោយឡែក អភិបាលរង ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយត្រូវជ្រើស រើសពីក្នុងចំណោមមន្ត្រីរាជការស៊ីវិលទាំងពីរភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ឬ ក្រៅក្របខ័ណ្ឌក្រសួងមហាផ្ទៃ។[12] អភិបាលខណ្ឌមានតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងមូលដ្ឋានរបស់ខ្លួន។ នៅក្នុងតួនាទីជាតំណាងនេះអភិបាលខណ្ឌត្រូវ ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ អំពីច្បាប់ និងធានាឱ្យមានការអនុវត្តច្បាប់ព្រមទាំងធានាឱ្យមានការការពារ និងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងខណ្ឌ។ គឺជាប្រធានគណៈបញ្ជាការឯកភាពខណ្ឌនៅក្នុងការដឹកនាំសម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធនានា និងសង្កាត់ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៅក្នុងខណ្ឌ។ ណែនាំដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងាររបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខណ្ឌចំការមន ឱ្យអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវស្របតាមច្បាប់គោលនយោបាយជាតិ និងលិខិតបទដ្ឋាន គតិយុត្តនានាដែលពាក់ព័ន្ធនឹងការិយាល័យអង្គភាព និងទីភ្នាក់ងារនីមួយៗរបស់ខណ្ឌ។ សម្របសម្រួលតម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ននានាដែលប្រចាំនៅខណ្ឌ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពនៅមូលដ្ឋាននោះ។

---

[10] មាត្រា២ នៃអនុក្រឹត្យលេខ១១៩ អនក្របក ចុះថ្ងៃទី ១៧ មិថុនា ២០២២

[11] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២៣ ឧសភា ២០០៨,មាត្រា១៤៧

[12] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២៣ ឧសភា ២០០៨,មាត្រា១៤១។

# រចនាសម្ព័ន្ធរដ្ឋបាលខណ្ឌចំការមន



## ១.៤ បច្ចុប្បន្នភាពនៃការរៀបចំសណ្តាប់ធ្នាប់

ដើម្បីភាពងាយស្រួលក្នុងការរស់នៅរបស់ប្រជាពលរដ្ឋ រដ្ឋបាលខណ្ឌ បានលើកគំរោងក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្មីៗជាច្រើន។ ការអភិវឌ្ឍនទាំងអស់នេះ គឺធ្វើឡើងដើម្បីបំរើនិងផ្គត់ផ្គង់ឱ្យបានទាន់ តម្រូវការរបស់ប្រជាពលរដ្ឋរស់នៅក្នុងខណ្ឌដែលកំពុងតែមានកំណើនជារៀងរាល់ថ្ងៃជាលំដាប់។ មកដល់ពេលបច្ចុប្បន្ន យើងសង្កេតឃើញថានៅក្នុងខណ្ឌចំការមន មានការអភិវឌ្ឍនជាច្រើនដែលគួរឱ្យកត់សម្គាល់។ ការអភិវឌ្ឍននេះ មិនមែនត្រឹមតែនៅក្នុងវិស័យណាមួយនោះទេ ពោលគឺមានការ អភិវឌ្ឍនទៅលើគ្រប់វិស័យទាំងអស់។ ប៉ុន្តែដោយការរៀបរាប់ពីការអភិវឌ្ឍន ទាំងអស់នោះគឺមានភាពធំ ទូលាយពេកដូចនេះ យើងនឹងធ្វើការរៀបរាប់ដោយផ្តោតសំខាន់តែទៅលើចំណុចដែលប្រាស្រ័យពាក់ព័ន្ធនឹង វិស័យមួយចំនួនតែប៉ុណ្ណោះ។

### ១.៤.១ ការរៀបចំប្រព័ន្ធបង្ហូរទឹក និងសំរាម

#### ក. ការរៀបចំប្រព័ន្ធបង្ហូរទឹក

សម្រាប់ខណ្ឌចំការមនគឺ មានប្រព័ន្ធលូបង្ហូរទឹកសំអុយគ្រប់ផ្លូវក្នុងភូមិសាស្ត្ររបស់ខណ្ឌ រួមមានបណ្តាញលូចាស់ និងជួសជុលដាក់ថ្មី ព្រមទាំងបានស្តារលូជារៀងរាល់ឆ្នាំ។ ផ្អែកតាមលក្ខណៈភូមិសាស្ត្រ ខណ្ឌចំការមនមានលក្ខណៈជា ដីទំនាប បាតខ្ទះ និងប្រព័ន្ធលូតាមផ្លូវតូចៗមួយចំនួននៅមានបំពង់លូតូច បំពង់លូចាស់ បាក់បែក និងលូនៅជ្រៅ រួមទាំងការចោលសម្រាមតាមផ្លូវក្នុងអណ្តូងលូបិទមុខលូ,ប្រឡាយ និងអាងស្តុកទឹកគោករាក់ផង នាំឱ្យមានទឹកលិច ផ្លូវ នារដូវវស្សា ពិសេសពេលមានភ្លៀងខ្លាំង និងរយៈពេលយូរ ដែលចាំបាច់ត្រូវមានការជួសជុលដាក់លូថ្មីនិង ស្តារជាប្រចាំ។ [13] ជាក់ស្តែងទីតាំងប្រឡាយប្រលាយបឹងត្របែក គឺជាប្រព័ន្ធចរន្តបង្ហូរទឹកដ៏ចម្បងដោយរំដោះទឹកពីតាមបណ្តាខណ្ឌធំៗជាច្រើន នៃកណ្តាលរាជធានីភ្នំពេញ។ បច្ចុប្បន្នប្រឡាយមេធំខាងលើគេសង្កេតឃើញថា មានជម្រៅជ្រៅជាងមុន ក្រោយអាជ្ញាធរបានកាយរួច ដែលអាចធ្វើឱ្យប្រឡាយមានបរិមាអាចផ្ទុកទឹកបានកាន់តែច្រើនជាងមុនផងដែរ។ ក្នុងនោះដែលប្រឡាយ ក៏ត្រូវបានសម្អាតស្អាតល្អ ដោយមិនមានសំរាមនៅលើផ្ទៃប្រឡាយនោះឡើយ ដែលនេះជាកត្តាងាយឱ្យទឹកអាចហូរទៅបានលឿនដោយមិនមានការរាំងស្ទះពីសំរាមនោះទេ។ ប្រជាពលរដ្ឋដែលរស់នៅតំបន់នោះ ក៏បានបង្ហាញក្តីរីករាយផងដែរ ពេលសង្កេតឃើញថាអាជ្ញាធរបានយកចិត្តទុកដាក់ធ្វើការស្តារ និងកាយប្រឡាយ ដើម្បីរំដោះទឹក ព្រោះកន្លងទៅនៅពេលមិនទាន់មានការកាយប្រឡាយឱ្យបានធំនោះ ពលរដ្ឋតែងឧស្សាហ៍ជួបការជន់លិចជាខ្លាំងនៅរៀងរាល់ភ្លៀងខ្លាំងម្តងៗដោយលិចដល់តាមខ្នងផ្ទះក៏ដូចជាជន់លិចតាមដងផ្លូវរំខានដល់ការធ្វើដំណើរជាដើម។ ពលរដ្ឋបន្តលើកឡើងថាការគិតគូរធ្វើការស្តារនិងកាយបែបនេះ វាជាភាពល្អប្រសើរខ្លាំងណាស់ដើម្បីធានាបានថាទោះ រដូវវស្សាមកដល់មានភ្លៀងខ្លាំងក៏ដោយក៏មិនមាន ការជន់លិចក្នុង រាជធានីភ្នំពេញ នោះទេប៉ុន្តែបើមានការជន់លិចក៏មិនអាចលិចក្នុងរយៈពេលយូរប៉ះពាល់ដល់ពលរដ្ឋនោះដែរទាំងការរស់នៅ និងការធ្វើដំណើរជាដើម។

[13] កម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌចំការមន

ដោយឡែកយោងតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ២២១ អនក្រ.បក ចុះហត្ថលេខាដោយ**សម្តេចតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីកម្ពុជា នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ បានសម្រេចកំណត់ផ្ទៃអាងស្តុកទឹកបឹងត្របែកទំហំ១៤៥,៦២៧ម៉ែត្រក្រឡា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ។ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានីភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។[14] យោងតាមលិខិតនេះបានឱ្យដឹងថា ការស្ថាបនាជញ្ជាំងទប់នឹងត្រូវធ្វើពីបេតុងអារម៉េ ដែលនឹងព័ទ្ធជុំវិញអាងស្តុកទឹកបឹងត្របែក ដើម្បីការពារមិនឱ្យមានរំលោភបន្តទៀត។ មួយវិញទៀត រដ្ឋនឹងធ្វើការជីកស្តារអាងទឹកបឹងត្របែកផ្នែកខាងលើឱ្យជ្រៅជាងមុន ដើម្បីឱ្យស្ថានីយបូមទឹក អាចបូមទម្លាក់បន្តទៅកាន់ប្រព័ន្ធបង្ហូរទឹក នៅតំបន់ភាគខាងត្បូងរាជធានីភ្នំពេញបាន។ ការស្តារនេះនឹងធ្វើឱ្យអាងស្តុកទឹក មានសមត្ថភាពគ្រប់គ្រាន់ក្នុងការស្តុកទឹកភ្លៀងដើម្បីបញ្ចៀសនូវការលិចលង់នៅក្នុងក្រុង។ ពាក់ព័ន្ធនិងគម្រោងដែលសំដៅបញ្ចប់ នូវបញ្ហាទឹកជន់លិចក្នុងរាជធានីភ្នំពេញ តាមអនុសាសន៍របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីកម្ពុជា** រាជធានីភ្នំពេញ មានគម្រោងចំនួន៥០គម្រោង ហើយក្នុងគម្រោងនេះ ប្រឡាយបឹងត្របែកក៏ស្ថិតនៅក្នុងគម្រោងនេះដែរ។ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញនូវគោលបំណងប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ សំដៅបញ្ចប់ នូវបញ្ហាទឹកជន់លិចរាជធានីភ្នំពេញ ក្នុងរយៈពេល ៥ឆ្នាំ នៅក្រោយបញ្ចប់គម្រោងនេះរាជធានីភ្នំពេញ នឹងលែងលិចលង់ ដែលវាជា ការរីករាយនិងការសាទរពីប្រជាពលរដ្ឋ។[15]

**ខ. សំរាម**

ស្របពេលដែលប្រទេសកម្ពុជារក្សាបាននូវកំណើនសេដ្ឋកិច្ច ក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយនេះចំពោះការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ត្រូវតែរក្សាឱ្យ បាននូវតុល្យភាពជាមួយនឹងការគាំពារបរិស្ថាន ដើម្បីធានាចីរភាព និងបរិយាប័ន្ន។ ទន្ទឹមនឹងល្បឿនយ៉ាង ឆាប់រហ័សនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដែលនាំឱ្យមានកំណើនឆាប់រហ័សនៃនគរូបនីយកម្ម, ការកែប្រែនិងលើកកម្ពស់ជីវភាព និងភាពកាន់តែសម្បូរបែបនៃការរស់នៅរបស់ប្រជាជនកម្ពុជា បាននិងកំពុងប្រឈមនឹងបញ្ហាជាផលវិបាកត្រឡប់មកវិញផងដែរ គឺល្បឿននៃកំណើនសំរាម សំណល់រឹងទីប្រជុំជន ដែលបាននិងកំពុងកើនឡើងក្នុងសន្ទុះមួយគួរឱ្យកត់សម្គាល់ និងត្រូវមានការយកចិត្តទុកដាក់ខ្ពស់។

ទន្ទឹមនឹងនេះរដ្ឋបាលខណ្ឌចំការមន បានយកចិត្តទុកយ៉ាងខ្លាំងចំពោះបរិមាណសំណល់ដែលកើនឡើងជាប្រចាំ នឹងធ្វើឱ្យមានការព្រួយបារម្មណ៍ចំពោះបញ្ហាទុកដាក់សំណល់រឹង ទាំងនេះទោះបីជាការផ្តល់សេវាកម្មបានល្អប្រសើរមួយភាគធំក៏ដោយ ក៏នៅតែមានបញ្ហាប្រឈម ដោយមានការកកស្ទះដោយកន្លែង និងនៅសេសសល់តាម

[14] អនុក្រឹត្យលេខ២២១អនក្រ.បក ស្តីពីការកំណត់ផ្ទៃអាងស្តុបទឹកបឹងត្របែកស្ថិតនៅក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ
[15] គេហទំព័រ https://www.cpp.org.kh ចូលមើលថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៤

សំណល់មិនរៀបរយ ការទុកដាក់សំរាមចោលរាយប៉ាយ អនាធិប្បតេយ្យ ផ្លូវតូចចង្អៀត មិនយល់ដឹងពីវិធីវេចខ្ចប់ និង ញែកសំរាម ក្រុមហ៊ុនខកខានមិនបានទៅយកសំរាមជាដើម។[16] ជាការពិតណាស់ដើម្បីគ្រប់គ្រងសំរាម សំណល់រឹង ប្រកបដោយប្រសិទ្ធភាព និងភាពគ្រប់ជ្រុងជ្រោយ គឺចាំបាច់ត្រូវមានការចូលរួមយ៉ាងសកម្ម ប្រកបដោយស្មារតីភ្ញាក់រលឹក និងការទទួលខុសត្រូវខ្ពស់,ការផ្លាស់ប្តូរឥរិយាបថ,ទម្លាប់,របៀបរបបរស់នៅ,របៀបរបបនៃការធ្វើអាជីវកម្ម-ផលិតកម្ម ព្រមទាំងការយល់ដឹងរបស់គ្រប់តួអង្គនិងភាគីពាក់ព័ន្ធទាំងអស់ដែលជាអ្នកបង្កើតសំរាម សំណល់រឹងទីប្រជុំជន ដោយត្រូវអនុវត្តគោលការណ៍សកល (3Rs): កាត់បន្ថយ (Reduce) ប្រើប្រាស់ឡើងវិញ (Reuse) និង កែច្នៃ (Recycle) ហើយត្រូវចាត់ទុកថា "សំណល់ជាធនធាន" រីឯ "អ្នកបង្កើតសំរាមមានកាតព្វកិច្ចបង់ថ្លៃសេវា" ។

ដើម្បីសម្រេចបានលើការគ្រប់គ្រង សំរាម និងសំណល់រឹងទីប្រជុំជន រាជរដ្ឋាភិបាលសម្រេចដាក់ឱ្យអនុវត្តនូវផែនការ សកម្មភាពអាទិភាពជាគោល រួមមានជាអាទិ៍៖

១- ការរៀបចំយន្តការស្ថាប័ន និងការបង្កើតក្របខណ្ឌគតិយុត្ត ទាំងនៅថ្នាក់ជាតិ (គណៈកម្មាធិការ គ្រប់គ្រង សំរាម សំណល់រឹងទីប្រជុំជន) និងថ្នាក់ក្រោមជាតិ (រដ្ឋបាលរាជធានី, ក្រុង និងស្រុក) ។

២- ការកសាងសមត្ថភាព និងការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីធានាប្រសិទ្ធភាពនៃការ អនុវត្តយុទ្ធសាស្ត្រខាងលើ ។[17]

ដើម្បីសម្រេចបានលើការគ្រប់គ្រង សំរាម និងសំណល់រឹងទីប្រជុំជន រដ្ឋបាលរាជធានីភ្នំពេញបានផ្តល់សិទ្ធិដល់ក្រុមហ៊ុនចំនួន៣ ធ្វើប្រតិបត្តិការប្រមូលសំរាមក្នុងរាជធានីភ្នំពេញ បន្ទាប់ពីក្រុមហ៊ុនទាំង៣នេះទទួលបានជោគជ័យលើការដេញថ្លៃ។ ក្រុមហ៊ុនចំនួន៣ នោះមាន ក្រុមហ៊ុន Cintri ក្រុមហ៊ុន 800SUPER និងក្រុមហ៊ុន Mizuda Group ដោយបែងចែកជា ៣តំបន់ គឺតំបន់ទី១ មាន៥ខណ្ឌ គឺខណ្ឌទួលគោក ខណ្ឌឬស្សីកែវ ខណ្ឌសែនសុខ ខណ្ឌជ្រោយចង្វារនិងខណ្ឌព្រែកព្នៅ ដែលដេញថ្លៃឈ្នះដោយក្រុមហ៊ុន 800SUPER ។ ចំណែកឯតំបន់ទី២មាន៥ខណ្ឌ គឺខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌដង្កោ ខណ្ឌពោធិ៍សែនជ័យ និងខណ្ឌកំបូល ដែលដេញថ្លៃឈ្នះដោយក្រុមហ៊ុនMizuda Group និង តំបន់ទី៣ មាន៤ខណ្ឌគឺ ខណ្ឌចំការមន ខណ្ឌបឹងកេងកង ខណ្ឌមានជ័យ និងខណ្ឌច្បារអំពៅ ដែលដេញថ្លៃឈ្នះដោយក្រុមហ៊ុន Cintri។[18] ទន្ទឹមនេះផងដែលរដ្ឋបាលខណ្ឌចំការមន និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាធារណជន និងសហគមន៍មូលដ្ឋាន នឹងអនុវត្តតាមវិធានការគោលនយោបាយលម្អិតនីមួយៗ ដែលបានដាក់ចេញ នៅក្នុងឯកសារគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីឱ្យការអនុវត្តគោលនយោបាយនេះសម្រេច

[16] កម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌចំការមន

[17] គោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០២០-២០៣០

[18] គេហទំព័រ https://www.information.gov.kh ចូលមើលថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៤

បានជោគជ័យ ដូចបានរំពឹងទុក និងប្រកបដោយប្រសិទ្ធភាព, ប្រសិទ្ធផល និងតម្លាភាព។ ដោយប្រកាន់ខ្ជាប់នូវអភិក្រមការងារប្រកប ដោយបុរេសកម្ម និងសកម្ម ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីធានាបាននូវភាពជោគជ័យនៃការអនុវត្ត គោលនយោបាយនេះក្នុងការចូលរួមថែរក្សាអភិរក្សបរិស្ថានក្រោមពាក្យស្លោក “កម្ពុជាស្អាតផ្តើមចេញពីយើងម្នាក់ៗ”។

### ១.៤.២.ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធ គឺជាអាទិភាពដ៏សំខាន់មួយ នៅក្នុងអាទិភាពគន្លឹះទាំង៥ “មនុស្ស ផ្លូវ ទឹក ភ្លើងនិងបច្ចេកវិទ្យា” នៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ ដោយកិច្ចការអាទិភាពទី២ ក្នុងបញ្ចកោណទី២ គឺការលើកកម្ពស់ការតភ្ជាប់ និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន បានផ្តោតគោលដៅយុទ្ធសាស្ត្រលើការបង្កើនប្រសិទ្ធភាពហេដ្ឋារចនាសម្ព័ន្ធគាំទ្រ, ការកសាង និងការអភិវឌ្ឍនទៅលើហេដ្ឋារចនាសម្ព័ន្ធថ្មី។ សមិទ្ធផលនេះ ក៏នឹងជួយកាត់បន្ថយចំណាយលើឥន្ធនៈដោយសារការកកស្ទះ ចំណោញពេលវេលា និងសម្រួលដល់ការធ្វើដំណើរប្រកបការងារ ជាពិសេស ការជួយលើកកម្ពស់ការកសាងសេដ្ឋកិច្ចមូលដ្ឋានរបស់ប្រជាពលរដ្ឋផងដែរ។[19] ជាក់ស្តែងនៅក្នុងភូមិសាស្ត្រ ខណ្ឌចំការមនមានផ្លូវគមនាគមន៍ខ្វាត់ខ្វែងគ្រប់ប្រភេទដូចជា ផ្លូវប្រភេទបេទីមីណឺ ផ្លូវក្រាលកៅស៊ូDBST និង ផ្លូវក្រាលបេតុង ព្រមទាំងមានភ្លើងបំភ្លឺតាមផ្លូវសាធារណៈស្ទើរតែគ្រប់ផ្លូវ ជួយជំរុញវិស័យនានាឱ្យបានរីកចម្រើន ក្រៅពីជួយសំរួលផ្នែកចរាចរណ៍សម្រាប់ប្រជាពលរដ្ឋក្នុងរាជធានី ខណ្ឌ ជាពិសេសក៏បានរួមចំណែកដល់ការទាក់ទាញ វិស័យទេសចរណ៍ផងដែរ។

ទន្ទឹមនឹងនេះក៏មានបញ្ហាប្រឈមលើកិច្ចដំណើរការ និងថែទាំដោយសារការជួសជុលផ្លូវកន្លងមក មានអ្នកអនុវត្តមួយចំនួនតូច ពុំទាន់អនុវត្តបានតាមបទដ្ឋានបច្ចេកទេសឱ្យបានពេញលេញ និងយន្តការត្រួតពិនិត្យនៅមានកម្រិត ដែលជាហេតុធ្វើឱ្យ ផ្លូវមួយចំនួនប្រឈមមុខនឹងការជួសជុលឡើងវិញ ក្នុងរយៈពេលតិចជាង៥ឆ្នាំ។ ម្យ៉ាងទៀត រថយន្តដឹកទំនិញធំៗ ដឹកហួសកំណត់ ព្រមជាមួយគ្នានឹងទឹកភ្លៀងធ្លាក់ខ្លាំង ទឹកជន់លិចផ្លូវជាច្រើនក៏ជាមូលហេតុ ធ្វើឱ្យផ្លូវងាយទទួលរង នូវការខូចខាត។[20]

**ទន្ទឹមនឹងនេះខណ្ឌបានធ្វើការអនុវត្តគម្រោងអភិវឌ្ឍនក្នុង ឆ្នាំ២០២៣បានជាច្រើនមានដូចជា៖**

- ដឹកដាក់បណ្តាញលូ១ខ្សែទំហំ១ម៉ែត្រ ប្រវែងសរុប១,៣៥៤ម៉ែត្រសង្ខាងផ្លូវលេខ៤៣២ ពីមាត់ប្រឡាយផ្លូវលេខ១០៥ដល់ផ្លូវលេខ១៦៣ ប្រវែង១,២០៤ម៉ែត្រ ក្នុងសង្កាត់ទួលទំពូងទី១ និងសង្កាត់បឹងត្របែក និង ចាប់ពីផ្លូវលេខ៤៣០ ដល់ផ្ទះលេខ១១២(ខាងត្បូង)ប្រវែង១៥០ម៉ែត្រ ក្នុងសង្កាត់ទួលទំពូងទី២ អនុវត្តបាន ១០០% ។
- ជីកដាក់បណ្តាញលូ ១ខ្សែ ទំហំ ០.៨ម៉ែត្រ ប្រវែង ៧៩៦ម៉ែត្រ លើកំណាត់ផ្លូវលេខ៩៩ ពីផ្លូវលេខ៤៨៤ ដល់ផ្លូវលេខ៥០៨ (សងខាង) ក្នុងសង្កាត់ផ្សារដើមថ្កូវ អនុវត្តបាន ១០០% ។

---

[19] យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧

[20] កម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌចំការមន

- ជួសជុលចាក់បេតុងឆ្អឹងដែក កម្រាស់១៥សង់ទីម៉ែត្រ បណ្តោយ៣៩៨ម៉ែត្រ ទទឹង៦,៩ ម៉ែត្រ មានផ្ទៃក្រឡា ២,៧៤៦.២ ម៉ែត្រការ៉េ ក្នុងសង្កាត់ផ្សារដើមថ្កូវ អនុវត្តបាន ១០០% ។
- ជួសជុលផ្លូវអ៊ុតកៅស៊ូAC ផ្លូវលេខ៤៤០ ចាប់ពីផ្លូវលេខ១៦៣ ដល់ផ្លូវលេខ១៥៥ មានបណ្តោយ១២៥ ម៉ែត្រ និងទទឹង ៨,៦ ម៉ែត្រ កម្រាស់៥សម ផ្ទៃក្រឡាសរុប ១,០៧៥ ម៉ែត្រការ៉េ សង្កាត់ទួលទំពូងទី១ អនុវត្តបាន ១០០% ។
- ជួសជុលផ្លូវអ៊ុតកៅស៊ូAC ផ្លូវលេខ៩៩ ចាប់ពីផ្លូវលេខ៥០៨ ដល់ផ្ទះលេខ១៤៧ មានបណ្តោយ១៥២ម៉ែត្រ ទទឹង៦,៦ម៉ែត្រ កម្រាស់៥សម ផ្ទៃក្រឡាសរុប ១,០០៣.២ ម$^២$ សង្កាត់ផ្សារដើមថ្កូវ អនុវត្តបាន ១០០% ។[21]

### ១.៤.៣.ការរៀបចំសំណង់ និងលំនៅដ្ឋាន

សំណង់លំនៅដ្ឋានជាចំណុចដែលអាជ្ញាធររដ្ឋត្រូវពិនិត្យ ដើម្បីការពារសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ប្រកបដោយគុណភាពសំណង់ និងអាចដឹងពីផលប៉ះពាល់ក្នុងការជួសជុល ឬការកែសម្រួលបណ្តាសំណង់ ព្រមជាមួយនិងការចេញនូវលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ អគារលំនៅដ្ឋាន អគារសាធារណៈ ដែលធ្វើការសាងសង់ខុសពីក្បួនច្បាប់បច្ចេកទេសនៃការសាងសង់។[22] លំនៅដ្ឋាន និងការតាំងទីលំនៅថ្មីជាបញ្ហាដែរពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ទីក្រុង ដែលត្រូវមានការ ចូលរួមពីវិស័យនានាទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ ក្នុងការកសាងផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី ការងារសំណង់ ការងារស្ថាបត្យកម្ម វិស្វកម្ម ការរៀបចំ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ ការស្វែងរកហិរញ្ញប្បទាន និងប្រភពធនធានការវាយតម្លៃ អំពីផលប៉ះពាល់បរិស្ថាន និងសង្គម។ល។ ដូច្នេះត្រូវមានការសម្របសម្រួលរវាងស្ថាប័នពាក់ព័ន្ធ និង ការរៀបចំនូវលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ឆ្លើយតបទៅនឹងគោលនយោបាយលំនៅដ្ឋានមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធតាមលំដាប់ថ្នាក់របស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យ ឯកជន និងសហគមន៍ផ្ទាល់។ គោលនយោបាយលំនៅដ្ឋានត្រូវសង្កត់ធ្ងន់លើយុទ្ធសាស្ត្រគាំទ្រ ដូចជាការចូលរួមសម្រេចរបស់សហគមន៍មូលដ្ឋាន និងការផ្តល់ហិរញ្ញប្បទានសម្រាប់ជួសជុល ឬ សាងសង់លំនៅដ្ឋាន ការសាងសង់លំនៅដ្ឋានថ្មីដើម្បីដោះស្រាយតម្រូវការចំពោះមុខ ការកំណត់មូលដ្ឋានសម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដីនៅទីក្រុង ទីប្រជុំជន ទីជនបទ ការរៀបចំនូវបណ្តាហេដ្ឋារចនាសម្ព័ន្ធ សេវាសាធារណៈ និងការកំណត់តម្លៃសេវានៃការអនុញ្ញាតសាងសង់។[23]

ជាក់ស្តែងរដ្ឋបាលខណ្ឌចំការមន បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើ ស្ថានភាពនៃការប្រើប្រាស់ដីធ្លីក្នុងគោលបំណងគ្រប់គ្រង និងប្រើប្រាស់ដីធ្លីឱ្យបានត្រឹមត្រូវ និងផ្តល់ផលប្រយោជន៍ជាអតិបរិមាដល់សង្គមជាតិ

[21] របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមនប្រចាំឆ្នាំ២០២៣
[22] សៀវភៅនីតិនគរបនីយវិទ្យា របស់បណ្ឌិតអ៊ុន សកក្កដា ទំព័រ៦៨
[23] គោលនយោបាយជាតិស្តីពីលំនៅដ្ឋាន ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៤ ត្រង់ចំណុចទី៥ ផែនការសកម្មភាព

ហើយស្របតាមគោលការណ៍ច្បាប់ កន្លងមកនេះរដ្ឋបាលខណ្ឌបានរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងដីធ្លី ដោយផ្តោតសំខាន់លើវិធានការពង្រឹងប្រព័ន្ធគ្រប់គ្រង ការលុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ និង ការដាក់ចេញ នូវវិធានការសមស្រប ដើម្បីទប់ស្កាត់ការប្រមូលដីទុកដោយមិនបានប្រើប្រាស់។ វិធានការនេះធ្វើឡើងដើម្បីបង្កើន ប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងប្រើប្រាស់ដីទំនេររបស់រដ្ឋ និងឯកជន ព្រមទាំងការដោះស្រាយ តាមបទបញ្ញត្តិច្បាប់ដែល ឯកជនកាន់កាប់ដីរដ្ឋដោយមិនសមស្របតាមលិខិតបទដ្ឋានគតិយុត្ត។[24]

**ជាមួយគ្នានេះផងដែល រដ្ឋបាលខណ្ឌចំការមន បានសម្រេចការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ជាច្រើនដូចទិន្នន័យខាងក្រោម៖**

១.<u>ការងារសុរិយោដី និង ភូមិបាល</u> ៖

| ល.រ | សង្កាត់ | អំណោយផ្តាច់ | | | | | | លក់ផ្តាច់ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ប័ណ្ណកម្មសិទ្ធិផ្ទះ | | ប័ណ្ណដី (LMAP) | | ប័ណ្ណសហកម្មសិទ្ធិ | | ប័ណ្ណកម្មសិទ្ធិផ្ទះ | | ប័ណ្ណដី (LMAP) | | ប័ណ្ណសហកម្មសិទ្ធិ | |
| | | ចំនួន | ផ្ទៃក្រឡា | ចំនួន | ផ្ទៃក្រឡា | ចំនួន | ផ្ទៃក្រឡា | ចំនួន | ផ្ទៃក្រឡា | ចំនួន | ផ្ទៃក្រឡា | ចំនួន | ផ្ទៃក្រឡា |
| 1 | ទន្លេបាសាក់ | | | 25 | 7418 | 5 | 430.74 | 8 | 736.61 | 84 | 38883.84 | 566 | 51046.27 |
| 2 | ទួលទំពូងទី១ | 2 | 170.45 | 14 | 3060 | | | | | 12 | 2100 | | |
| 3 | ទួលទំពូងទី២ | 1 | 68 | 15 | 4320 | | | | | 15 | 2079 | | |
| 4 | បឹងត្របែក | 2 | 143.91 | 12 | 2298 | | | | | 20 | 7242 | 15 | 650.86 |
| 5 | ផ្សារដើមថ្កូវ | | | 10 | 1926 | | | | | 15 | 3647 | | |
| សរុប | | 5 | 382.36 | 76 | 19022 | 5 | 430.74 | 8 | 736.61 | 146 | 53951.8 | 581 | 51697.1 |

ប្រភព៖ របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមនប្រចាំឆ្នាំ២០២៣

[24] កម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌចំការមន

## ២.ការងារសុរិយោដី និង ភូមិបាល ៖

| ល.រ | សង្កាត់ | ចេញប័ណ្ណកម្មសិទ្ធិ | | | | | | ទុតិយតា | | ទំនាស់ | | ការងារច្រកមន្ទីរសុរិយោដី | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ប័ណ្ណកម្មសិទ្ធិផ្ទះ | | ប័ណ្ណដី ( LMAP ) | | ប័ណ្ណសហកម្មសិទ្ធិ | | ដី ឬ ផ្ទះ | | ដី ឬ ផ្ទះ | | បង្រួមក្បាលដី | | បំបែកក្បាលដី | |
| | | ចំនួន | ផ្ទៃក្រឡា | ចំនួន | ផ្ទៃក្រឡា | ចំនួន | ផ្ទៃក្រឡា | ចំនួន | ផ្ទៃក្រឡា | ចំនួន | ផ្ទៃក្រឡា | ចំនួន | ផ្ទៃក្រឡា | ចំនួន | ផ្ទៃក្រឡា |
| 1 | ទន្លេបាសាក់ | 1 | | 4 | 9763 | 1 | 3943 | 8 | 111.16 | | | 1 | 1836 | 1 | 29464 |
| 2 | ទួលទំពូងទី១ | 2 | 148.3 | 9 | 1293 | | | | | | | | | | |
| 3 | ទួលទំពូងទី២ | 1 | 63.54 | 3 | 346 | | | | | | | | | | |
| 4 | បឹងត្របែក | 1 | 42.2 | 6 | 676 | | | 1 | 13524 | | | 1 | 2168 | | |
| 5 | ផ្សារដើមថ្កូវ | | | 15 | 21037 | | | 1 | 432 | | | | | | |
| សរុប | | 5 | 254.04 | 37 | 33115 | 1 | 3943 | 10 | 14067.2 | 0 | 0 | 2 | 4004 | 1 | 29464 |

## ៣ .ការងារសំណង់ :របស់រដ្ឋបាលខណ្ឌចំការមន ៥០០ ម៉ែត្រក្រឡា = ៖

| ល.រ | សង្កាត់ | សំណង់ច្រកចេញចូលតែមួយ | | | សំណង់ជួសជុលច្រកចេញចូលតែមួយ | | |
|---|---|---|---|---|---|---|---|
| | | មានច្បាប់ | គ្មានច្បាប់ | ខុសប្លង់ | មានច្បាប់ | គ្មានច្បាប់ | ខុសប្លង់ |
| | | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន |
| 1 | ទន្លេបាសាក់ | 5 | | | 7 | | |
| 2 | ទួលទំពូងទី១ | 3 | | | 5 | | |
| 3 | ទួលទំពូងទី២ | 3 | | | 7 | | |
| 4 | បឹងត្របែក | 2 | | | 6 | | |
| 5 | ផ្សារដើមថ្កូវ | 8 | | | 2 | | |
| សរុប | | 21 | 0 | 0 | 27 | 0 | 0 |

ប្រភព៖ របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមនប្រចាំឆ្នាំ២០២៣

### ១.៤.៤.ការរៀបចំរបៀបរៀបរយ

ដើម្បីរួមចំណែកធ្វើឱ្យប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ ជាពិសេសក្នុងភូមិសាស្ត្រខណ្ឌចំការមនបានរស់នៅប្រកបដោយសេចក្តីសុខ ទាំងផ្លូវកាយនិងផ្លូវចិត្ត ដែលមានគ្រប់សមាសភាពដូចជាៈ អាជីវករ សេវាករ មន្ត្រីរាជការ បុគ្គលិក និយោជិត និយោជក អ្នកមាន ជីវភាពធូរធារ អ្នកក្រីក្រ ព្រះសង្ឃ អ្នកកាន់សាសនាផ្សេងៗ តម្រូវឱ្យរដ្ឋបាលខណ្ឌយកចិត្តទុកដាក់ខ្ពស់ លើការងារ សន្តិសុខ និងសណ្តាប់ធ្នាប់ ដែលកន្លងមកការងារនេះ យើងសង្កេតឃើញថាមានសក្តានុពលផង និងបញ្ហាប្រឈមមួយចំនួនផងដែរ។

**ក.ការងារសន្តិសុខ-សណ្តាប់ធ្នាប់សាធារណៈ៖**

- សភាពការណ៍សន្តិសុខសង្គម
- សភាពការណ៍ការងារការពារ សម័យប្រឡងសញ្ញាបត្រ ទុតិយភូមិ ឆ្នាំ ២០២៣
- សភាពការណ៍កិច្ចការពារការិយាល័យចុះឈ្មោះបោះឆ្នោត
- សភាពការណ៍ ការងារប្រឆាំងបទល្មើស
- ការងារស្ថិតិ និងអត្តសញ្ញាណប័ណ្ណ
- សភាពការណ៍គ្រោះថ្នាក់សង្គម
- ការងាររឹតបន្តឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក
- ការងារការពារក្បួនថ្នាក់ដឹកនាំនិងគណៈប្រតិភូ។[25]

**ខ.លទ្ធផលកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស ៖**

+បទល្មើសឧក្រិដ្ឋ ៖ បង្ក្រាបបាន ០៦ ករណី ឃាត់ខ្លួន ១៦ នាក់ ប្រុស ១៤ នាក់

+បទល្មើសមជ្ឈឹម ៖ បង្ក្រាបបាន ៣៩ ករណី ឃាត់ខ្លួន ៥០ នាក់ ប្រុស ៤៨ នាក់

+បង្ក្រាបបទល្មើសគ្រឿងញៀន៖ ៥៦លើក បង្ក្រាបបាន ៥៦លើក ឃាត់ខ្លួន ៦៨នាក់ ប្រុស ៦០នាក់

+ការងារបង្ក្រាបក្មេងទំនើង ៖ ៣៣លើក បង្ក្រាបបាន ៣៣លើក ឃាត់ខ្លួន ៤៨នាក់ ប្រុស ៤៧នាក់

+បង្ក្រាបល្បែងស៊ីសងខុសច្បាប់៖ ០១លើក បង្ក្រាបបាន ០១លើក ឃាត់ខ្លួន ០៣នាក់ ប្រុស ០៣នាក់។[26]

**គ.ការងារសហការបង្ក្រាបបទល្មើសជាមួយស្ថាប័នពាក់ព័ន្ធ ៖**

-សហការចុះបង្ក្រាបករណីបង្ខាំងមនុស្ស និងធ្វើទារុណកម្ម៖ ០៨ លើក

-សហការករណីជនជាតិ ចិន មកសុំអន្តរាគមន៍ពីស្ថានទូតចិន និងរុស្ស៊ី ៖ ០២ លើក

-សហការត្រួតពិនិត្យបញ្ចប់ការប្រើប្រាស់-ធ្វើអាជីវកម្ម និងតាំងទីលំនៅដ្ឋាន ៖ ០១ លើក

-សហការចុះបង្ក្រាបបទល្មើសគ្រឿងញៀន ៖ ០៧ លើក

-សហការបង្ក្រាបទីតាំងបង្កប់ល្បែងស៊ីសងខុសច្បាប់ ៖ ២៨ លើក

[25] របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមនប្រចាំឆ្នាំ២០២៣

[26] របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមនប្រចាំឆ្នាំ២០២៣

-សហការត្រួតពិនិត្យទីតាំងខារ៉ាអូខេ ក្លឹបកំសាន្ត និងហាងម៉ាស្សា ៖ ០៤ លើក

-សហការអប់រំ-ណែនាំភោជនីយ៍បង្កសំឡេងរំខាន និងលួចសម្ភារភ្ញៀវ ៖ ០៧ លើក

-សហការចុះបង្ក្រាបទីតាំងផលិតផលក្លែងក្លាយ ៖ ០២ លើក

-សហការអប់រំ-ណែនាំទីតាំងទិញ-លក់អេតចាយ ៖ ០២ លើក

-សហការត្រួតពិនិត្យសន្តិសុខតាមបណ្តាខុនដូរ អាផាតមិន សណ្ឋាគារ ៖ ១៣ លើក

-សហការចុះបង្ក្រាប និងឃាត់ជនសង្ស័យករណីលួចម៉ូតូ ៖ ០១ លើក (សង្កាត់ទន្លេបាសាក់)។[27]

**ឃ.ការងារប្រជុំផ្សព្វផ្សាយគោលនយោបាយ (ភូមិ-សង្កាត់ មានសុវត្ថិភាព) ៖ ៦០ លើក**

គណៈបញ្ជាឯកភាពខណ្ឌ ចុះធ្វើវេទិកាសាធារណៈ ៦០ លើក ៦០ គោលដៅ អ្នកចូលរួមសរុប ២,៧៣៦ នាក់ ស្រី ១,៥៤៣ នាក់ ផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន ,ចរាចរណ៍ ,អគ្គីភ័យ ,យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ , ក្មេងទំនើង និងបទល្មើសផ្សេងៗ ដែលមានក្នុងមូលដ្ឋាន តាមរយៈវេទិកាសាធារណៈ យើងបានទទួលមតិរបស់ប្រជាពលរដ្ឋ ដែលបានបង្ហាញពីក្តីបារម្ភជុំវិញបញ្ហាដែលមានក្នុងមូលដ្ឋានរបស់ខ្លួន។ គ្រប់សំណូមពរ របស់ប្រជាពលរដ្ឋខាងលើ ត្រូវបានសមត្ថកិច្ច អាជ្ញាធរ ពាក់ព័ន្ធដោះស្រាយ តាមសមត្ថកិច្ចរបស់ខ្លួន ធ្វើឱ្យប្រជាពលរដ្ឋមានការគាំទ្រយ៉ាងកក់ក្តៅ ក្នុងការអនុវត្តន៍គោល នយោបាយ ភូមិ-សង្កាត់ មានសុវត្ថិភាព (សង្កាត់ទន្លេបាសាក់ ១២ លើក ,ទួលទំពូង១ .១២ លើក ,ទួលទំពូង២ .១២ លើក ,បឹងត្របែក ១២ លើក ,ផ្សារដើមថ្កូវ ១២ លើក)។[28]

**ង.ការងារប្រជុំផ្សព្វផ្សាយ អប់រំ និងពិគ្រោះយោបល់ ៖ ១,២២៩ លើក** (**សង្កាត់ទាំង៥**)

គណៈបញ្ជាការឯកភាពខណ្ឌ-សង្កាត់ បានផ្សព្វផ្សាយតាមម៉ូតូ ,រ៉ឺម៉កកង់បី ដាក់មេក្រូ ព្រមទាំងចុះផ្សាយតាមសហគមន៍ និងសាលារៀនចំនួន ១,២២៩ លើក ដល់ប្រជាពលរដ្ឋ ,សិស្សានុសិស្ស ក្នុងមូលដ្ឋានសរុប ១៧,១៦៧ នាក់ ស្រី ៩,៤២៥ នាក់ ផ្សព្វផ្សាយពីការឆ្លងការរីករាលដាលជម្ងឺកូវីដ-១៩ ព្រមទាំងបញ្ហាផលប៉ះពាល់ការប្រើប្រាស់គ្រឿងញៀន ,ចរាចរណ៍ ,អគ្គីភ័យ ,យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ,ក្មេងទំនើង ក្នុងនោះមានសង្កាត់ទន្លេបាសាក់ ២៥០ លើក ,ទួលទំពូង១ .២៧០ លើក ,ទួលទំពូង២ .២៣៧ លើក ,បឹងត្របែក ២៣៩ លើក ,ផ្សារដើមថ្កូវ ២៣៣ លើក ។[29]

**ច.ការងារផ្សព្វផ្សាយក្នុងសហគមន៍ពីផលប៉ះពាល់នៃគ្រឿងញៀន ៖ ១៥ លើក**

កម្លាំងនគរបាលខណ្ឌចំការមន សហការជាមួយសង្កាត់-សង្កាត់ ចុះផ្សព្វផ្សាយតាមខ្នងផ្ទះ និងតាមសាលារៀន ចំនួន ១៥ លើក ដល់ប្រជាពលរដ្ឋ និងសិស្សានុសិស្ស សរុប ៨៧៥ នាក់ ស្រី ៤៩៤ នាក់ ស្តីពីការឆ្លងការរីករាលដាលជម្ងឺឆ្លងផ្សេងៗ ,ផលប៉ះពាល់គ្រឿងញៀន ,គ្រោះថ្នាក់ចរាចរណ៍ ,ក្មេងទំនើង និងបទល្មើស

[27] របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមនប្រចាំឆ្នាំ២០២៣

[28] របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមនប្រចាំឆ្នាំ២០២៣

[29] របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមនប្រចាំឆ្នាំ២០២៣

ផ្សេងៗ ក្នុងនោះសង្កាត់ ទន្លេបាសាក់ ០៣លើក ,ទួលទំពូង១ .០៧លើក ,ទួលទំពូង២ .០១លើក ,បឹងត្របែក ០១លើក ,ផ្សារដើមថ្កូវ ០៣លើក)។[30]

**ឆ.ការងារផ្សព្វផ្សាយក្នុងសហគមន៍ពីផលប៉ះពាល់នៃគ្រឿងញៀន ៖ ៣៥ លើក**

កម្លាំងនគរបាលខណ្ឌចំការមន សហការជាមួយសង្កាត់-សង្កាត់ ចុះផ្សព្វផ្សាយតាមខ្នងផ្ទះ និងតាមសាលារៀន ចំនួន ៣៥លើក ដល់ប្រជាពលរដ្ឋ ,សិស្សានុសិស្ស សរុប ៣,៥៥៥នាក់ ស្រី ៧៤៧នាក់ ស្តីពីការឆ្លងការរីករាលដាលជម្ងឺកូវីដ-១៩ ,ផលប៉ះពាល់គ្រឿងញៀន ,គ្រោះថ្នាក់ចរាចរណ៍ ,ក្មេងទំនើង និងបទល្មើសផ្សេងៗ ។[31]

**ជ.ការងារចុះត្រួតពិនិត្យរដ្ឋបាល ៖ ៤៩ លើក**

គណៈបញ្ជាការឯកភាពខណ្ឌ-សង្កាត់ សហការត្រួតពិនិត្យរដ្ឋបាល ៤៩ លើក លើ ៤៩ គោលដៅ ជាលទ្ធផលត្រួតពិនិត្យបាន ៥៥១ ខ្នងផ្ទះ ១,៤២៩ បន្ទប់ ១,២៧៩ គ្រួសារ មនុស្ស ២,៥២៩ នាក់ ស្រី ១,៣១៦ នាក់ អាយុ ១៨ ឆ្នាំ ឡើង មាន ២,៣៣៣ នាក់ ស្រី ១,២១៦ នាក់ ពុំមានអ្វីគួរឱ្យកត់សំគាល់ឡើយ (សង្កាត់ទន្លេបាសាក់ ៤១ លើក ,ទួលទំពូង១ .០២ លើក ,បឹងត្របែក ០៣ លើក ,ផ្សារដើមថ្កូវ ០៣ លើក) ។[32]

## ១.៥ ទិសដៅអនាគតនៃការរៀបចំសណ្តាប់ធ្នាប់

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់ រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានបន្តធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ ក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និង សក្តិសិទ្ធភាព។ ជាមួយគ្នានេះដែលទិសដៅក្នុងការអភិវឌ្ឍរបស់ខណ្ឌចំការមននាពេលអនាគត គឺធ្វើការលើកស្ទួយនូវ ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋឱ្យមានការរីកចម្រើនតាមរយៈការរៀបចំផែនការអភិវឌ្ឍន៍ ទៅតាម វិស័យនីមួយៗប្រកបដោយ សមភាព តម្លាភាព និងគណនេយ្យភាព។

### ១.៥.១.ការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន

**ក.ផ្លូវថ្នល់**

-បន្តការកសាងផ្លូវតាមបណ្តោយច្រាំងទន្លេបាសាក់ចាប់ពី **ស្ពរច្បារសម្តេច ហ៊ុន សែន** រហូតដល់គល់ស្ពាន ព្រះមុនីវង្ស និងកសាងផ្លូវតាមបណ្តោយច្រាំងកោះពេជ្យចាប់ពីគល់ស្ពាននាគផ្នែកខាងកើត រហូតដល់

[30] របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមនប្រចាំឆ្នាំ២០២៣

[31] របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមនប្រចាំឆ្នាំ២០២៣

[32] របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមនប្រចាំឆ្នាំ២០២៣

ស្ពានហង្ស ដើម្បីចូលរួមការអភិវឌ្ឍនវិស័យទេសចរណ៍ សុខុមាលភាព និងសោភ័ណភាពរាជធានីភ្នំពេញ។ ជាមួយគ្នានេះក៏ត្រូវបង្កបរិយាកាសវិនិយោគ ដើម្បីធ្វើការអភិវឌ្ឍផ្លូវខាងលើនេះផងដែរ

-បន្តរៀបចំផ្លូវឱ្យល្អប្រណីត អមដោយដើមផ្កាអមសងខាងផ្លូវ និងសួនពុះចែកទ្រូងផ្លូវ ចិញ្ចើមផ្លូវ ផ្លូវជនពិការ ផ្លូវថ្មើរជើង គន្លងផ្លូវទោចក្រយាន បរិក្ខាផ្លូវថ្នល់ ដែលមានបរិស្ថានធម្មជាតិស្រស់បំព្រង បង្គោលភ្លើង និងភ្លើងលម្អក្បូរក្បាច់រចនាបថខ្មែរ ទាក់ទិននឹងធម្មជាតិ ប្រកបដោយសក្តានុពលទាក់ទាញទេសចរណ៍ និងអ្នកដំណើរឆ្លងកាត់ខណ្ឌ

-សិក្សាការបើកផ្លូវ ច្រកផ្លូវ និងពង្រីកទ្រូងផ្លូវបន្ថែម ដើម្បីបង្កភាពងាយស្រួលដល់ចរាចរណ៍សាធារណៈ ការធ្វើ អភិបាលកិច្ចល្អ និងនគរូបនីយកម្មល្អ

-រៀបចំកំណត់កម្រិតកម្ពស់នគរូបនីយកម្ម កម្រិតកម្ពស់ចិញ្ចើមផ្លូវត្រូវមានកម្ពស់០,២ម៉ែត្រធៀបជាមួយនឹង ទ្រូងផ្លូវ ហើយត្រូវមានមុំជម្រាល០,១% និងមានបទដ្ឋានបច្ចេកទេសតែមួយដើម្បីមានភាពងាយស្រួល

-សាងសង់ស្ពានថ្មើរជើងរំលងមហាវិថីសំខាន់ៗ និងផ្លូវដែលមានចរាចរណ៍មមាញឹកដើម្បីសម្រួល និងបញ្ចៀស គ្រោះថ្នាក់ចរាចរណ៍

-បន្តកែលម្អបណ្តាញផ្លូវមេសំខាន់ៗជាផ្លូវឯកទិសដោយសាងសង់ស្ពានអាកាសនៅចំណុចប្រសព្វផ្លូវឆ្លងកាត់ ស្របតាមការវិវឌ្ឍនៃចរាចរក្នុងរាជធានីភ្នំពេញ ដើម្បីសម្រួលចរាចរណ៍សាធារណៈ

-រៀបចំគន្លងផ្លូវរថយន្តសាធារណៈនៅតាមផ្លូវសំខាន់ៗ និងតំបន់ទីប្រជុំជន ដើម្បីសម្រួលដល់ការធ្វើចរាចរណ៍ របស់រថយន្តសាធារណៈ ក៏ដូចជាលើកទឹកចិត្តដល់ប្រជាជនឱ្យប្រើប្រាស់សេវារថយន្តសាធារណៈ

-អនុវត្តសេចក្តីសម្រេចលេខ០៣៩សសរ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់ស្ថាបត្យកម្មចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយានសម្រាប់សាធារណៈជន និងជនពិការ ដើម្បីធានាសោភ័ណភាពសាធារណៈ និងការធ្វើចរាចរណ៍ប្រកបដោយសុវត្ថិភាព សុខុលភាព និងភាពងាយស្រួល ដល់សាធារណៈជន និងជនពិការ

-សិក្សារៀបចំទីតាំងចំណតរថយន្តក្រោមដី ដើម្បីបញ្ចៀសការកកស្ទះចរាចរណ៍

-លើកកម្ពស់ និងផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍តាមផ្លូវគោក។[33]

**ខ.ផ្លូវទឹក**

-ការពារផ្ទៃទឹកទន្លេពីការសាងសង់សំណង់ផ្សេងៗដែលប៉ះពាល់ដល់ការធ្វើចរាចរណ៍ផ្លូវទឹក

-សិក្សាសំណង់ច្រាំងទន្លេ ដើម្បីការពារការបាក់ស្រុតដីច្រាំងចូលក្នុងទឹកទន្លេ ដែលធ្វើឱ្យប៉ះពាល់ដល់ការធ្វើចរាចរណ៍ផ្លូវទឹក

-សិក្សាការបូមដីពីបាតទន្លេដែលធ្វើឱ្យរាំងស្ទះដល់ការធ្វើចរាចរណ៍តាមផ្លូវទឹក និងសមស្របតាមបទដ្ឋានបច្ចេកទេស

-រៀបចំភ្លើងបំភ្លឺតាមបណ្តោយច្រាំងទន្លេដែលឆ្លងកាត់ខណ្ឌចំការមន ដើម្បីសម្រួលដល់ការធ្វើចរាចរណ៍ផ្លូវទឹក និងបម្រើដល់វិស័យទេសចរណ៍

[33] ប្លង់គោលប្រើប្រាស់ដីខណ្ឌចំការមន ចក្ខុវិស័យឆ្នាំ២០៣៥

-រៀបចំមធ្យោបាយធ្វើដំណើរតាមផ្លូវទឹកឱ្យបានច្រើនប្រភេទ ដើម្បីចម្រុះចរាចរណ៍

-សាងសង់កំពង់ផែសម្រាប់លើកដាក់ទំនិញចេញចូលតាមដងទន្លេ

-លើកកម្ពស់ និងផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍តាមផ្លូវទឹក។[34]

**គ.ផ្លូវអាកាស**

-រក្សាលំហអាកាសពីការសាងសង់សំណង់ផ្សេងៗ ដោយកំណត់កម្ពស់សំណង់ ក្នុងតំបន់គ្រប់គ្រងកម្ពស់ឧបសគ្គព្រលានយន្តហោះ ឱ្យស្របតាមព្រះរាជក្រមលេខ នស/រកម/០១០៨/០០៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ ច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-សំណង់អគារខ្ពស់ៗត្រូវបំពាក់ភ្លើងសញ្ញាពណ៌ក្រហមសម្គាល់កម្ពស់ឧបសគ្គ តាមបទដ្ឋានបច្ចេកទេសរបស់ អាកាសចរស៊ីវិល ពិសេសអគារមន្ទីរពេទ្យ ត្រូវរៀបចំឱ្យមានចំណតឧទ្ធម្ភាគចក្រ និងនិមិត្តសញ្ញាពេទ្យ នៅលើដំបូលអគារ ដើម្បីជួយសង្គ្រោះបន្ទាន់។[35]

## ១.៥.២.ការអភិវឌ្ឍលើបរិស្ថាន និងសំណល់

**ក. បរិស្ថាន**

រដ្ឋបាលខណ្ឌបានធ្វើការកំណត់ និងបែងចែកតំបន់ប្រើប្រាស់ដី សម្រាប់ទុកដាក់កាកសំណល់រឹង តាមគ្រប់ទីតាំងផ្សារ ទីតាំងបុរី តាមភូមិ និងតាមខ្នងផ្ទះ គ្រឹះស្ថានសាធារណៈនិងឯកជន ដោយតម្រូវឱ្យមានការទុកដាក់ឱ្យបានត្រឹមត្រូវតាមបទដ្ឋានកំណត់។

**ដើម្បីឆ្លើយតបទៅនឹងបញ្ហាបរិស្ថាន រដ្ឋបាលខណ្ឌបានដាក់ចេញនូវវិធានការចាំបាច់មួយចំនួនក្នុងការការពារតំបន់សំខាន់ៗដូចខាងក្រោមៈ**

-ការពារ និងថែរក្សា តំបន់ច្រាំងទន្លេ បឹង ប្រឡាយ តំបន់សួនជ្រាបទឹក និងដើមឈើតាមផ្លូវសាធារណៈ -ការពារ និងថែរក្សា ប្រព័ន្ធបណ្តាញផ្លូវ បណ្តាញលូ និងបណ្តាញទឹកស្អាត ស្របតាមបទប្បញ្ញត្តិជាធរមាន

-ការពារ និងថែរក្សាទន្លេបាសាក់ ដើម្បីធានាប្រព័ន្ធអេកូឡូស៊ី និងជីវចម្រុះក្នុងទន្លេ

-កាត់បន្ថយការបំពុលខ្យល់ដោយសារម៉ាស៊ីនភ្លើង តាមរយៈការផ្គត់ផ្គង់អគ្គិសនីរដ្ឋឱ្យបានច្រើនបំផុត និងជម្រុញឱ្យប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ

-លើកកម្ពស់មធ្យោបាយដឹកជញ្ជូនដែលមិនបំពុលបរិស្ថានក្នុងខណ្ឌ

-បង្កើតគណៈកម្មាធិការត្រួតពិនិត្យបរិស្ថានឱ្យមានប្រសិទ្ធភាពមួយនៅថ្នាក់ខណ្ឌ និងលើកកម្ពស់ចំណេះដឹងរបស់ប្រជាជនអំពីបរិស្ថាន

-រៀបចំឱ្យមានមូលនិធិសម្រាប់ថែទាំបរិស្ថាន និងជំរុញការវិនិយោគវិស័យឯកជន និងសាធារណៈ

-ជំរុញការគ្រប់គ្រង ការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន ដោយផ្សារភ្ជាប់ជាមួយ ចលនាភូមិមួយផលិតផលមួយ ការលើកកម្ពស់អេកូទេសចរណ៍ និង/ឬសកម្មភាពសេដ្ឋកិច្ចនានា ដែលមាន លក្ខណៈមេត្រីបរិស្ថានទទួលខុសត្រូវសង្គម។[36]

---

[34] ប្លង់គោលប្រើប្រាស់ដីខណ្ឌចំការមន ចក្ខុវិស័យឆ្នាំ២០៣៥

[35] ប្លង់គោលប្រើប្រាស់ដីខណ្ឌចំការមន ចក្ខុវិស័យឆ្នាំ២០៣៥

[36] ប្លង់គោលប្រើប្រាស់ដីខណ្ឌចំការមន ចក្ខុវិស័យឆ្នាំ២០៣៥

**ខ. សំណល់**

**ជាមួយគ្នានេះផងដែលដើម្បីឆ្លើយតបទៅនឹងបញ្ហា កាកសំណល់រដ្ឋបាលខណ្ឌបានដាក់ចេញនូវវិធានការចាំបាច់មួយចំនួនក្នុងការគ្រប់គ្រងសំណល់រឹង និងរាវដូចខាងក្រោមៈ**

**យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង**

-ពង្រឹងយន្តការ និងហេដ្ឋារចនាសម្ព័ន្ធក្នុងការគ្រប់គ្រងសំណល់រឹងក្នុងខណ្ឌ

-លើកកម្ពស់ទំនើបកម្មមធ្យោបាយនិងបរិក្ខាប្រមូលសំណល់រឹង រៀបចំទីតាំងសម្រាប់ទុកដាក់សំណល់រឹងស្របតាមបទដ្ឋានបច្ចេកទេស និងស្តង់ដារទីក្រុងស្អាត

-អភិវឌ្ឍបច្ចេកវិទ្យាទំនើបក្នុងការគ្រប់គ្រងសំណល់រឹង

-ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ ការវិនិយោគរបស់វិស័យឯកជន និងសាធារណៈក្នុងការគ្រប់គ្រងសំណល់រឹង

-ជំរុញឱ្យមានការអនុវត្តគោលការណ៍ «កាត់បន្ថយការប្រើប្រាស់ ប្រើប្រាស់ឡើងវិញ និងកែច្នៃលើការគ្រប់គ្រងសំណល់រឹង»

- ជំរុញឱ្យមានការកាត់បន្ថយការប្រើប្រាស់ថង់ផ្លាស្ទិច

-ផ្សព្វផ្សាយពីគោលការណ៍បរិស្ថាន និងអនាម័យ ដើម្បីធានាបាននិរន្តរភាព ជាតំបន់លំនៅឋានប្រកបដោយសុខុមាលភាព។[37]

**យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ**

- រៀបចំ កែលម្អ និងពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀង និងលូទឹកកខ្វក់ ឱ្យដាច់ពីគ្នា ដោយតភ្ជាប់ទៅនឹងអាងប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រ និងត្រូវចម្រោះទឹកឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យ មុននឹងបង្ហូរចូលប្រព័ន្ធលូសាធារណៈ

-ណែនាំគ្រប់ម្ចាស់សំណង់លំនៅឋាន ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្មផ្សេងៗ និងសំណង់សាធារណៈត្រូវ មានអាងប្រព្រឹត្តកម្មទឹកកខ្វក់ និងអាងបង្គន់អនាម័យត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស

-មន្ត្រីសមត្ថកិច្ចជំនាញ នឹង/ឬសហការជាមួយអាជ្ញាធរមូលដ្ឋាន ត្រូវត្រួតពិនិត្យជាប្រចាំរាល់ការដ្ឋានសំណង់ ក្នុងការធ្វើអាងប្រព្រឹត្តកម្មទឹកកខ្វក់ និងអាងបង្គន់អនាម័យ

-រៀបចំអណ្តូងលូអោយមានប្រព័ន្ធចម្រោះជាមុននូវកាកសំណល់ភក់ មុននឹងបង្ហូរចូលលូសាធារណៈ ឱ្យស្របតាមបទដ្ឋានបច្ចេកទេស

-ផ្សព្វផ្សាយដល់សាធារណៈជន នូវអនុក្រឹត្យលេខ២៣៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។[38]

[37] ប្លង់គោលប្រើប្រាស់ដីខណ្ឌចំការមន ចក្ខុវិស័យឆ្នាំ២០៣៥

[38] ប្លង់គោលប្រើប្រាស់ដីខណ្ឌចំការមន ចក្ខុវិស័យឆ្នាំ២០៣៥

### ១.៥.៣.ការអភិវឌ្ឍលើវិស័យដីធ្លី

ផ្អែកលើប្លង់គោលប្រើប្រាស់ដីខណ្ឌចំការមនចក្ខុវិស័យឆ្នាំ២០៣៥ ប្រភេទដីអាចសាងសង់បាន មានទំហំផ្ទៃដីសរុបប្រមាណ៦២៤,៨៦ហិកតា ស្មើនឹង៨៨,៧៥% នៃផ្ទៃដីសរុប ដោយបានកំណត់អំពីបទប្បញ្ញត្តិប្រើប្រាស់ដី នៅក្នុងតំបន់នីមួយៗ រួមមាន សន្ទស្សន៍ប្រើប្រាស់ដី ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ សួនច្បារ ដែលអាចជ្រាបទឹក ការដាំដើមឈើ ជួរតម្រង់ ធ្លាគម្លាត កម្ពស់សំណង់ ចំណតរថយន្ត អាងបង្គន់អនាម័យ ពណ៌អគារ សោភ័ណភាព និងមានរចនាបថស្ថាបត្យកម្មខ្មែរ និង/ឬមានធម្មជាតិត្រឹមត្រូវ ស្របតាមបទប្បញ្ញតិជាធរមាន។[39] ជាមួយគ្នានេះដែលខណ្ឌបានធ្វើការបែងចែកជា តំបន់ៗនៃការប្រើប្រាស់ដីក្នុងនោះមាន ៖

- តំបន់លំនៅឋាន
- តំបន់ពាណិជ្ជកម្ម
- តំបន់ចម្រុះ
- តំបន់ដឹកជញ្ជូន
- តំបន់ទេសចរណ៍
- តំបន់រដ្ឋបាលនិងសេវាសាធារណៈ
- តំបន់លំហសាធារណៈនិងផ្ទៃបៃតង
- តំបន់វប្បធម៌និងសាសនា
- តំបន់អភិរក្សជុំវិញវិមានឯករាជ។[40]

### ១.៥.៤.ការអភិវឌ្ឍលើវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិតរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**បានដាក់ចេញនូវវិធានការនានា ប្រកបដោយប្រសិទ្ធភាព បន្តរក្សាបាននូវសុខសន្តិភាពស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ជាពិសេសបញ្ហាក្មេងទំនើង ដើម្បីធានាបាននូវប្រក្រតីភាពនៃគ្រប់សកម្មភាពក្នុងសង្គម ធ្វើឱ្យមានលំនឹងខាងសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទាំងមូល ព្រមទាំងសម្រេចបាននូវវឌ្ឍនភាពសង្គម ស្របតាមគោលការណ៍នានាដែលបានកំណត់ ការជំរុញចលនាអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព បានធ្វើឱ្យបរិយាកាសសន្តិសុខសណ្តាប់ធ្នាប់សង្គមកាន់តែល្អប្រសើរ។ ជាមួយគ្នានេះដែលរដ្ឋបាលខណ្ឌចំការមនបានយកចិត្តទុកដាក់លើការងារសំខាន់ៗដែលទាក់ទងស្ថានភាពនៃការគ្រប់គ្រង សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ព្រោះជាការងារដ៏សំខាន់ដែលត្រូវតែយកចិត្តទុកដាក់ពង្រឹង និងមានវិធានការយ៉ាងម៉ឺងម៉ាត់ដើម្បីអនុវត្ត។ ដោយមានគណៈបញ្ជាការឯកភាពថ្នាក់ខណ្ឌនិងថ្នាក់សង្កាត់ ដើម្បីពង្រឹងយន្តការក្នុងការការពារសន្តិសុខ សុវត្ថិភាពសង្គម និង រៀបចំសណ្តាប់ធ្នាប់សាធារណៈនៅក្នុងមូលដ្ឋានខណ្ឌទាំងមូល។

[39] ប្លង់គោលប្រើប្រាស់ដីខណ្ឌចំការមន ចក្ខុវិស័យឆ្នាំ២០៣៥

[40] ប្លង់គោលប្រើប្រាស់ដីខណ្ឌចំការមន ចក្ខុវិស័យឆ្នាំ២០៣៥

# ជំពូកទី ២
# ការរៀបចំសោភ័ណភាពខណ្ឌចំការមន

# ជំពូកទី២

# ការរៀបចំសោភ័ណភាពខណ្ឌចំការមន

## ២.១ សោភ័ណភាពពេលថ្ងៃ

សោភ័ណភាព បរិស្ថាន និងអនាម័យ ជាកត្តាដែលគួរទទួលបាននូវការរៀបចំឱ្យមានលក្ខណៈល្អប្រសើរ ដើម្បីលើកកម្ពស់ទីក្រុងស្អាត ទាក់ទាញភ្ញៀវទេសចរណ៍ ផ្តល់ផាសុកភាព និង សុខុមាលភាពល្អចំពោះប្រជាជន។ ចំពោះខណ្ឌចំការមនដែលជាខណ្ឌមួយដែលស្ថិតនៅកណ្ដាល រាជធានីភ្នំពេញវិញ ក៏បានផ្តោតសំខាន់ទៅលើបញ្ហាសោភ័ណភាព បរិស្ថាន និងអនាម័យល្អប្រសើរ ផងដែរតាមរយៈការអនុវត្តផ្ទាល់ និងដាក់ចេញនូវផែនការណ៍ផ្សេងៗកែលម្អសោភ័ណភាព បរិស្ថាន និងអនាម័យក្នុងខណ្ឌ។ សោភ័ណភាពពេលថ្ងៃ គឺសំដៅទៅដល់សំណង់អគារ លំនៅដ្ឋាន ស្ពានអាកាស ផ្លូវថ្នល់ ផ្ទះល្វែង បុរី ស្ពានក្រោមដី ប្រព័ន្ធលូ សួនច្បារ បង្គោលភ្លើង ស្លាកសញ្ញាចរាចរណ៍ យានជំនិះគ្រប់ប្រភេទ សរុបមកគឺអ្វីៗដែលកើតមានឡើងនៅលើដី។[41]
ជាក់ស្តែងប្រសិនបើក្រឡេកមកមើលទិដ្ឋភាពក្នុងខណ្ឌចំការមននាពេលបច្ចុប្បន្ន សង្កេតឃើញថានៅតាមដងផ្លូវមានដាំដើមឈើ ស្រស់បំព្រងគួរជាទីចាប់អារម្មណ៍ ចំណែកប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធក៏រៀបចំបានយ៉ាងល្អម៉ត់ចត់ ដោយរៀបចំឱ្យមានភ្លើងសញ្ញា ស្លាកសញ្ញា គំនូសសញ្ញាចរាចរណ៍ បង្គោលភ្លើងបំភ្លឺផ្លូវ កាម៉េរាសុវត្ថិភាព តាមដងផ្លូវ ការរៀបចំដាក់ឱ្យមានលូទំហំធំ ក៏ដូចជាប្រព័ន្ធបង្ហូរទឹកឱ្យបានឆាប់រហ័ស ដើម្បីចៀសវាងមាន ការជន់លិចផ្លូវពេលមានភ្លៀងធ្លាក់រយៈពេលយូរដែលបង្កការរំខាន់ដល់ដល់ធ្វើដំណើររបស់ប្រជាពលរដ្ឋ។

### ២.១.១ ការដាំដើមឈើតាមដងផ្លូវ

ការដាំដើមឈើនៅតាមដងផ្លូវ គឺជាការលើកកម្ពស់សោភ័ណភាពទីក្រុងផង និងជាការរួមចំណែកកាត់បន្ថយការបំពុលបរិស្ថានដែលកើតចេញពីយានជំនិះប្រចាំថ្ងៃផងដែរ។ ជាមួយគ្នានេះផងដែលអភិបាលរាជធានីភ្នំពេញ **ឯកឧត្តម ឃួង ស្រេង** បានជំរុញឱ្យអាជ្ញាធរខណ្ឌទាំង១៤ ថែរក្សាដើមឈើ ឱ្យបានគង់វង្ស និងធ្វើរបាយការណ៍៣ខែម្តងមករដ្ឋបាលរាជធានីភ្នំពេញ ជុំវិញការអភិវឌ្ឍនៃការដាំដើមឈើនៅក្នុង មូលដ្ឋានរបស់ខ្លួន ដើម្បីធ្វើយ៉ាងណាឱ្យដើមឈើនៅអាចរស់នៅដោយភាពគង់វង្ស និងរក្សាបានជាទីក្រុងមានពណ៌បៃតង។ ការជំរុញបែបនេះបានធ្វើឡើងកាលពីព្រឹកថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ ក្នុងពិធីដាំ និងចែកកូនឈើ ដើម្បីអបអរសាទរ "រុក្ខាទិវា" ០៩ កក្កដា ឆ្នាំ២០២៣ នៅក្នុងបរិវេណសាលាបឋមសិក្សាទ្រនំជ្រើង សង្កាត់បឹងធំ ខណ្ឌកំបូល។

ឯកឧត្តមអភិបាល បានមានប្រសាសន៍លើកឡើងថា៖ ពិធីដាំ និងចែកកូនឈើ ដើម្បីអបអរសាទរ "រុក្ខាទិវា" ០៩ កក្កដា នេះធ្វើឡើងដើម្បីបង្ហាញពីស្មារតីយកចិត្តទុកដាក់ ក្នុងការថែរក្សាព្រៃឈើ ធ្វើឱ្យភ្នំពេញ មានពណ៌បៃតងស្រស់ស្អាត។ ឯកឧត្តមបន្តថាព្រៃឈើមានអត្ថប្រយោជន៍ច្រើនណាស់ ដូចជាផ្តល់ជាជម្រកសត្វព្រៃ

[41] សៀវភៅរូបនីកម្មវិទ្យាបណ្ឌិត អ៊ុន សកក្កដា

ផ្តល់អ៊ុកស៊ីសែន និងការទប់ទល់ការប្រែប្រួលអាកាសធាតុជាដើម។ ព្រៃឈើមានតម្លៃមិនអាចកាត់ថ្លៃបាន ដូច្នេះ យើងត្រូវថែទាំនិងរក្សាព្រៃឈើឱ្យបានគង់វង្សទាំងអស់គ្នា។ **ឯកឧត្តម ឃួង ស្រេង** ក្នុងឱកាសនោះ ក៏បានជំរុញអាជ្ញាធរខណ្ឌទាំងអស់លើកទឹកចិត្តឱ្យប្រជាពលរដ្ឋចូលរួមដាំដើមឈើយ៉ាងហោចណាស់ក្នុង១ខណ្ឌយ៉ាងតិច ២០០ដើម។ បន្ថែមពីលើនេះ **ឯកឧត្តម** ក៏បានជំរុញឱ្យអាជ្ញាធរខណ្ឌទាំង១៤ ថែរក្សាដើមឈើឱ្យបានគង់វង្ស ដោយក្រោយការដាំ ត្រូវធ្វើរបាយការណ៍៣ខែម្តង មករដ្ឋបាលរាជធានីភ្នំពេញ ជុំវិញការដាំដើមឈើនៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីឱ្យបានដឹងថា ដើមឈើរស់ឬងាប់ ងាយស្រួលយើងបានដាំបន្ថែម ធ្វើយ៉ាងណាឱ្យរាជធានីភ្នំពេញជាទីក្រុងរក្សាមានភាពបៃតង ស្រស់ស្អាត។[42]

## ២.១.២ ការរៀបចំសំណង់អគារ

ផ្អែកតាមអនុក្រឹត្យលេខ១៥១អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ អនុក្រឹត្យលេខ៤២អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យលេខ៨៦អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យលេខ ១៨១អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញឆ្នាំ ២០៣៥ អនុក្រឹត្យលេខ១១៨អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ ខណ្ឌចំការមនត្រូវបានកំណត់ការប្រើប្រាស់ដីជាពីរប្រភេទគឺ ប្រភេទដីអាចសាងសង់បាន និងប្រភេទដីកម្រិតការសាងសង់។[43]

### ក. តំបន់នគរូបនីយកម្មខណ្ឌបច្ចុប្បន្ន

-ជម្រុញដាក់លេខផ្លូវ និងលេខផ្ទះ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងរដ្ឋបាល

-ជម្រុញការគ្រប់គ្រងនិងកែលម្អខណ្ឌចំការមនសម្រាប់ការរស់នៅប្រកបដោយសុខុមាលភាព

-កែលម្អ និងស្តារបណ្តាញហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ បណ្តាញទឹកស្អាត បណ្តាញអគ្គិសនី ការប្រមូលសំណល់រឹង និងរាវ ឱ្យមានលក្ខណៈសមស្រប និងមានគុណភាព ដើម្បីលើកកម្ពស់គុណភាពរស់នៅ និងសោភ័ណភាព ខណ្ឌ និងរាជធានី

-កែលម្អ និងពង្រីកផ្លូវសំខាន់ៗដូចជា មហាវិថី វិថី អនុវិថី ផ្លូវជនពិការ ផ្លូវថ្មើរជើង គន្លងផ្លូវទោចក្រយានចិញ្ចើមផ្លូវ ភ្លើងបំភ្លឺ ស្លាកសញ្ញាចរាចរ ស្លាកផ្សព្វផ្សាយពាណិជ្ជកម្ម កំណត់ប្រភេទដើមឈើ រៀបចំសួនច្បារ តាមបណ្តោយផ្លូវ សួនសាធារណៈ សួនកុមារ ទីលានកីឡា កន្លែងកម្សាន្ត អភិវឌ្ឍផ្ទៃបៃតង នៅក្នុងខណ្ឌ ស្របទៅតាមតំបន់ប្រើប្រាស់ដី ឱ្យមានសោភណភាពរស់រវើក សណ្តាប់ធ្នាប់ល្អ បរិស្ថានរស់នៅប្រកបដោយ សុខភាពល្អសម្រាប់មនុស្សទាំងអស់គ្នា

-គ្រប់គ្រង និងអភិវឌ្ឍន រូបសំណាក**ព្រះបរមរតនកោដ្ឋ ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តមសីហនុ** សួន ច្បារផ្កាវាំ-ទឹករាំ ឬនាគបាញ់ទឹក រូបសំណាក**សម្តេចសង្ឃរាជ ជួន ណាត** សួនច្បារ**សម្តេចតេជោ ហ៊ុន សែន**

[42] គេហទំព័រ https://phnompenh.gov.khចូលមើលថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤

[43] ប្លង់គោលប្រើប្រាស់ដីខណ្ឌចំការមន ចក្ខុវិស័យឆ្នាំ២០៣៥

-រៀបចំ និងកំណត់រចនាបទអគារ ពណ៌អគារ និងរបង ឱ្យមានសោភ័ណភាពល្អ ស្របតាមទីតាំងភូមិសាស្ត្រ ជាមជ្ឈមណ្ឌលវប្បធម៌ នយោបាយ សន្តិសុខ សេដ្ឋកិច្ច សង្គម

-រៀបចំផែនការប្រើប្រាស់ដីដោយកំណត់បទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍ ការសាងសង់ ប្លង់លម្អិត នគរូបនីយកម្ម តាមតំបន់នីមួយៗ។[44]

**ខ. ទិសដៅនគរូបនីយកម្ម**

-និន្នាការនៃការអភិវឌ្ឍនគរូបនីយកម្ម មានលទ្ធភាពពង្រីកតាមវិធីសាស្ត្រនៃការអភិវឌ្ឍនបញ្ឈរ

-គ្រប់គ្រងការអភិវឌ្ឍន និងធ្វើសមាហរណកម្មការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ប្រកបដោយប្រសិទ្ធភាព និងចីរភាព ស្របតាមបទដ្ឋានបច្ចេកទេសនគរូបនីយកម្ម និងការអភិវឌ្ឍនរូបវន្ត ជាពិសេសបណ្តាញផ្លូវ និងបណ្តាញអគ្គិសនី បណ្តាញទឹកស្អាត ប្រព័ន្ធលូ អាងស្តុកទឹក និងអាងប្រព្រឹត្តិកម្មផ្សេងៗ

-ពង្រឹងសមត្ថភាពរបស់មន្ត្រី រួចធ្វើផែនការអភិវឌ្ឍន និងគ្រប់គ្រងការអភិវឌ្ឍន ការអភិរក្ស ជាពិសេសប្រសិទ្ធភាពនៃគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខណ្ឌចំការមន ដែលមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលខណ្ឌចំការមន ជាសេនាធិការក្នុងការគ្រប់គ្រង និងអនុវត្តការងាររៀបចំដែន ដី និងនគរូបនីយកម្ម។[45]

## ២.១.៣ ការរៀបចំចរាចរណ៍តាមដងផ្លូវ

ការរៀបចំហេដ្ឋារចនាសម្ព័ន្ធក៏ជាកត្តាមួយដ៏សំខាន់ក្នុងការលើកកម្ពស់សោភ័ណភាពរបស់ខណ្ឌមួយផ្នែកផងដែល ជាពិសេសរាល់ការរៀបចំកសាងសំណង់ដូចជា សំណង់រោងចក្រ សហគ្រាស ស្ថានីយប្រេង ឃ្លាំងទំនិញ និងសំណង់បុរី លំនៅដ្ឋាន ផ្ទះល្វែង ផ្សារ មន្ទីរពេទ្យ សាលារៀន ជាដើមត្រូវតែធ្វើឡើងដោយ គោរពតាមស្តង់ដារ ដែលច្បាប់បានកំណត់។ ចំពោះការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវត្រូវអនុលោមតាមច្បាប់ផ្លូវថ្នល់មាត្រា៣០ ចែងថាដើម្បីធានាដល់ ការធ្វើចរាចរណ៍លើផ្លូវល្បឿនលឿន ផ្លូវជាតិ ផ្លូវខេត្ត ប្រកបដោយសុវត្ថិភាព រាល់សំណង់ដែលមានច្រកចេញចូលជា ផ្លូវថ្នល់ខាងលើនេះត្រូវអនុវត្តដូចខាងក្រោម៖

-ការសាងសង់សំណង់ដូចជា ស្ថានីយប្រេងឥន្ធនៈ ស្ថានីយហ្គាស កន្លែងលាងយានយន្តយានដ្ឋាន ឬសំណង់ប្រហាក់ប្រហែលផ្សេងៗទៀត ដែលមានមនុស្សជួបជុំគ្នាមធ្យមត្រូវស្ថិតក្នុងចម្ងាយយ៉ាងតិច ១៥ ម៉ែត្រ ពីខ្សែបន្ទាត់ព្រំដីចំណីផ្លូវ

-ការកសាងសង់មជ្ឈមណ្ឌលពាណិជ្ជកម្ម ពហុកីឡាដ្ឋាន ទីលានប្រកួត រោងមហោស្រព មន្ទីរពេទ្យ គ្រឹះស្ថានសិក្សា ការរៀបចំផ្សារ ផ្សារណាត់ ពិព័រណ៍ទំនិញ ឬកិច្ចការផ្សេងទៀតដែលមានមនុស្សជួបជុំគ្នា ច្រើនត្រូវស្ថិតក្នុងចម្ងាយយ៉ាងតិចបំផុត ៥០ម៉ែត្រ ពីខ្សែបន្ទាត់ព្រំដីចំណីផ្លូវថ្នល់

-ការកំណត់ដូចមានចែងក្នុងចំណុចទី១ និងទី២ ខាងលើនេះមិនអនុវត្តចំពោះរាល់សំណង់ដែលបានសាង សង់មុនស្របតាមបទប្បញ្ញត្តិជាធរមានឡើយ

[44] ប្លង់គោលប្រើប្រាស់ដីខណ្ឌចំការមន ចក្ខុវិស័យឆ្នាំ២០៣៥

[45] ប្លង់គោលប្រើប្រាស់ដីខណ្ឌចំការមន ចក្ខុវិស័យឆ្នាំ២០៣៥

-ការកំណត់ចម្ងាយដូចមានចែងនៅចំណុចទី១ ទី២ ខាងលើចំពោះផ្លូវជនបទត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។[46]

ទន្ទឹមនេះផងដែលខណ្ឌបានរៀបចំគម្រោងជាច្រើនដើម្បីបម្រើដល់វិស័យដឹកជញ្ជូនក្នុងនោះមានដូចជា៖

**ក. កសាងប្រព័ន្ធដឹកជញ្ជូនឆ្លាតវៃសាធារណៈតាមរយៈ**

-ការបង្កើតប្រព័ន្ធគ្រប់គ្រងចរាចរណ៍តាមបែបសមាហរណកម្ម

-ការប្រើប្រាស់ប្រព័ន្ធដឹកជញ្ជូនសន្សំសំចៃ និងមិនប៉ះពាល់ដល់បរិស្ថាន ( Eco-friendly ) -

-ការបង្កើតប្រព័ន្ធទំនាក់ទំនងសម្រាប់មធ្យោបាយដឹកជញ្ជូនសាធារណៈ -

-ការប្រើប្រាស់គំនូសផ្លូវឆ្លាតវៃ ដោយលាយសារធាតុបារីត២០% ជាមួយនឹងទឹកថ្នាំគំនូសផ្លូវ ដើម្បីមានចំណាំង ផ្កោត និងភ្លឺនៅក្នុងពេលធ្វើចរាចរណ៍

-ការបំពាក់អំពូលឆ្លាតវៃនៅតាមដងផ្លូវ ដែលជាប្រភេទអំពូលដែលមានការសន្សំសំចៃខ្ពស់ និងគ្រប់គ្រងថាមពលដោយស្វ័យប្រវត្តិ

-ការបំពាក់កាមេរ៉ាសុវត្ថិភាពលើដងផ្លូវ និងទីប្រជុំជនសំខាន់ៗនៅក្នុងខណ្ឌ ដើម្បីត្រួតពិនិត្យចរាចរណ៍ជាទូទៅ នៅតាមដងផ្លូវក៏ដូចជានូវតាមទីសាធារណៈនានា ដើម្បីធានាសុវត្ថិភាពជូនប្រជាជន និងបង្រ្កាបនូវរាល់សកម្មភាព អវិជ្ជមានដែលកើតមានទាន់ពេលវេលានិងមានប្រសិទ្ធភាព និងពន្លឿនការស្រាវជ្រាវរកមុខសញ្ញាចំពោះ ករណីណាមួយដែលកើតមានឡើងតាមដង ផ្លូវនិងទីសាធារណៈនានា

**ខ. កសាងផ្លូវដឹកជញ្ជូនសាធារណៈ និងការផ្ដល់ព័ត៌មាននៃពេលវេលាមកដល់**

-ការបង្កើតប្រព័ន្ធព័ត៌មានដឹកជញ្ជូនសាធារណៈដល់អ្នកដំណើរ ( ពេលវេលា )

-អាចផ្ដល់ការពិនិត្យព័ត៌មាននៃការធ្វើដំណើរ( ពេលវេលាមកដល់របស់រថយន្តសាធារណៈ )តាមទូរស័ព្ទដៃទំនើប ( smart phone )

**គ. កសាងប្រព័ន្ធចតយានយន្តឆ្លាតវៃ**

-កសាងសុវត្ថិភាព និងបែងចែកចំណតសម្រាប់ចតយានយន្តផ្ទាល់ខ្លួន

-ផ្តល់ព័ត៌មានជាក់លាក់និងទាន់ពេលអំពីកន្លែងចតយានយន្ត។[47]

## ២.២ សោភ័ណភាពពេលយប់

សោភ័ណភាពពេលយប់ គឺសំដៅទៅលើការបំពាក់ភ្លើងបំភ្លឺតាមអគារនានា និងតាមដងមហាវិថីនានាក្នុងទីក្រុងជាពិសេសការបំពាក់ភ្លើងបំភ្លឺចម្រុះពណ៌ពេលរាត្រីនៅតាមសួនច្បារសាធារណៈផងដែរ។ ជាក់ស្ដែងការលម្អ សោភ័ណភាពនាពេលយប់មិនត្រឹមតែជាគ្រឿងលម្អតុបតែងតែប៉ុណ្ណោះទេតែជាការរៀបចំនេះដែលធ្វើឱ្យទិដ្ឋភាពនៅ ក្នុងខណ្ឌមានភាពប្លែក ជួយបង្កើនសម្រស់ ភាពទាក់ទាញដល់ភ្ញៀវទេសចរណ៍ឱ្យមកលេងកម្សាន្តបែបលក្ខណៈគ្រួសារ ឬបែបមិត្តភាពផ្សេងទៀត ជាពិសេសអាចជួយបំភ្លឺផ្លូវដល់អ្នកដំណើរ ដែលនេះក៏អាចជួយ

[46] ច្បាប់ស្តីពីផ្លូវថ្នល់,លេខ នស/រកម/០៥១៤/០០៨, ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៤, មាត្រា៣០

[47] ប្លង់គោលប្រើប្រាស់ដីខណ្ឌចំការមន ចក្ខុវិស័យឆ្នាំ២០៣៥

កាត់បន្ថយនូវ គ្រោះថ្នាក់ បានមួយកម្រិតផងដែរ។ ការរៀបចំសោភ័ណភាពនាពេលយប់រួមមាន៖ ការបំពាក់ភ្លើងតាមដងផ្លូវ និង ការបំពាក់ភ្លើងចម្រុះពណ៌តាមសួនច្បារ និងទីកន្លែងសាធារណៈ។ល។

### ២.២.១ ការដាំបង្គោលភ្លើងអគ្គីសនី

**ការរៀបចំថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យារបស់ខណ្ឌ**

-បន្តកែលម្អបណ្តាញអគ្គិសនី ទូរគមនាគមន៍ឱ្យស្របតាមបទដ្ឋានបច្ចេកទេស

-រៀបចំឱ្យមានប្រព័ន្ធសុវត្ថិភាពស្វ័យប្រវត្តិនៅទីសាធារណៈ ដើម្បីងាយស្រួលគ្រប់គ្រង អន្តរគមន៍បានទាន់ពេលវេលា ធានាបាននូវសុវត្ថិភាពក្នុងការរស់នៅ

-បន្ត និងជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់អគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ

-ជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់រថយន្តដើរដោយអាគុយ

-ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍ សេដ្ឋកិច្ច និងពាណិជ្ជកម្ម។[48]

### ២.២.២ ការបំពាក់ភ្លើងចំរុះពណ៌តាមសួនច្បារ និងទីកន្លែងសាធារណៈ

ចំពោះការបំពាក់ភ្លើងបំភ្លឺតាមសួនច្បារ និងដងផ្លូវសាធារណៈ ជាកត្តាមួយសំខាន់ខ្លាំងណាស់ក្នុងការលើកកម្ពស់ សោភ័ណភាពទីក្រុង ជាពិសេសការដាក់ភ្លើងបំភ្លឺផ្លូវក្នុងពេលរាត្រីបានផ្តល់ភាពងាយស្រួលដល់អ្នកដែលធ្វើដំណើរតាមដងផ្លូវទៅមក។ តួយ៉ាងចំពោះរដ្ឋបាលខណ្ឌចំការមន ជាពិសេសសាលារាជធានីភ្នំពេញបានធ្វើការយកចិត្តទុកដាក់ទៅលើការបំពាក់ភ្លើងចំរុះពណ៌តាម មហាវិថី សួនច្បារ និងនៅតាមទីកន្លែងសាធារណៈ ជាងនេះទៅទៀតបានដាក់ ភ្លើងបំភ្លឺនៅតាមដងផ្លូវសំខាន់ៗមួយចំនួននៅក្នុងខណ្ឌផងដែរ។ ការបំពាក់ភ្លើងបំភ្លឺតាមដងផ្លូវមិនត្រឹមតែធ្វើឱ្យមាន សោភ័ណភាពនៅតាមដងផ្លូវនឹងនៅក្នុងខណ្ឌប៉ុណ្ណោះទេ ការបំពាក់ភ្លើងនេះក៏ជាមធ្យោបាយដ៏ល្អមួយក្នុងការថែរក្សា សន្តិសុខ សុវត្ថិភាព ដល់ប្រជាពលរដ្ឋដែលបើកបរនៅពេលរាត្រីទៀតផង។ ជាមួយគ្នានេះដែល រដ្ឋបាលរាជធានីភ្នំពេញតែងតែបានចេញនូវ សេចក្តីណែនាំដល់រដ្ឋបាលខណ្ឌទាំង ១៤ រដ្ឋបាលសង្កាត់ទាំង ១០៥ មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានី គ្រឹះស្ថានសិក្សា ក្រុមហ៊ុន រោងចក្រ-សហគ្រាស ផ្សារទំនើប រមណីយដ្ឋាន មជ្ឈមណ្ឌលកម្សាន្ត ម្ចាស់ទីតាំងអាជីវកម្មគ្រប់ប្រភេទ និងគេហដ្ឋានប្រជាពលរដ្ឋទាំងអស់អំពីការរៀបចំសណ្តាប់ធ្នាប់សាធារណៈ ការថែរក្សាបរិស្ថាននិងអនាម័យ ការរៀបចំតុបតែង លម្អ ដោយភ្លើងចម្រុះពណ៌និងការរៀបចំសោភ័ណភាពផ្សេងៗ ដើម្បីការកម្ពស់សោភ័ណភាពរបស់ទីក្រុង។ ជាក់ស្តែងក្នុងអំឡុងពេលរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាស៊ីហ្គេមលើកទី៣២ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ រដ្ឋបាលរាជធានីភ្នំពេញបានចេញសេចក្តីណែនាំ៨ចំណុចអំពីសណ្តាប់ធ្នាប់សាធារណៈ ការថែរក្សាបរិស្ថាននិងអនាម័យដែលពលរដ្ឋគួរចូលរួមអនុវត្តដើម្បីលើកកម្ពស់សោភ័ណភាពទីក្រុង ពេលរៀបចំព្រឹត្តិការណ៍កីឡាស៊ីហ្គេមនិងប៉ារ៉ាហ្គេម។[49]

[48] ប្លង់គោលប្រើប្រាស់ដីខណ្ឌចំការមន ចក្ខុវិស័យឆ្នាំ២០៣៥

[49] ផែនការណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញលេខ ០០៥/២៣ សនណអ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣

**ខាងក្រោមនេះគឺជាសេចក្តីណែនាំពីរដ្ឋបាលរាជធានីភ្នំពេញ ទាំង៨ចំណុចះ**

១.គ្រប់លំនៅឋាន ផ្សារទំនើប អគារពាណិជ្ជកម្ម រោងចក្រ សហគ្រាស រមណីយដ្ឋាន មជ្ឈមណ្ឌល កម្សាន្ត សំណង់បុរី មូលដ្ឋានអាជីវកម្ម គ្រប់ប្រភេទផ្សេងទៀត សូមចងទង់ជាតិ ដោយដាក់ដងឱ្យបានត្រឹមត្រូវ និង រៀបចំ តុបតែង លម្អ ភ្លើងពណ៌ នៅមុខគេហដ្ឋាន លើអគារ តាមរបង និងនៅមុខមូលដ្ឋានអាជីវកម្ម របស់ខ្លួន។ ទង់ជាតិត្រូវមានលក្ខណៈត្រឹមត្រូវស្របតាមអត្តសញ្ញាណជាតិ និង ត្រូវចង់ឱ្យមានរបៀបរៀបរយល្អ ព្រមទាំងត្រូវពិនិត្យមើល ក្រណាត់ទង់ជាតិ ចៀសវាងប្រើប្រាស់ កំណាត់ដាច់រហែក ស្លក់ពណ៌ ឬទក់ ដែលធ្វើឱ្យបាត់បង់សោភ័ណភាព។

២-គ្រប់គ្រឹះស្ថានរដ្ឋ-ឯកជន ផ្សារទំនើប អគារពាណិជ្ជកម្ម រោងចក្រ-សហគ្រាស រមណីយដ្ឋាន មជ្ឈមណ្ឌលកម្សាន្ត សំណង់បុរី និងមូលដ្ឋានអាជីវកម្មគ្រប់ប្រភេទនៅក្នុងរាជធានីភ្នំពេញសូមះ

-ចងបដាពាក្យស្លោក ដែលមានខ្លឹមសារឆ្លុះបញ្ចាំងពីការអភិវឌ្ឍជាតិ និងព្រឹត្តិការណ៍ប្រកួតកីឡា ទាំងពីរនេះ ដោយត្រូវចងតាមលក្ខណៈបច្ចេកទេស និងសមស្របតាមទំហំអគារ ឬទីតាំងរបស់ ខ្លួនចៀសវាងបង្កគ្រោះថ្នាក់ និងបាត់បង់សោភ័ណភាព។

-រៀបចំបំពាក់ខ្សែភ្លើងពណ៌បំភ្លឺ និងដាក់គោមភ្លើងបំភ្លឺនៅតាមរបងនៅមុខអគារ ឬតាមជញ្ជាំង អគារ ឬ ដើមឈើ និងមូលដ្ឋានអាជីវកម្មរបស់ខ្លួន ឱ្យមានភាពទាក់ទាញ និងសោភ័ណភាព។

-នៅមុខទីតាំងផ្សារទំនើប និងអគារពាណិជ្ជកម្មធំៗ ដែលមានសួនច្បារ និងទឹកបាញ់ ត្រូវរៀបចំ តុបតែង លម្អភ្លើងពណ៌បំភ្លឺចម្រុះពណ៌ ហើយទីតាំងដែលមានបំពាក់ទូរទស្សន៍ LED ត្រូវចាក់ ផ្សាយអំពីសកម្មភាព និង ខ្លឹមសារផ្សេងៗពាក់ព័ន្ធនឹងព្រឹត្តិការណ៍ប្រកួតកីឡានេះ។

-សម្រាប់មូលដ្ឋានអាជីវកម្មទេសចរណ៍ ត្រូវដាក់ពាក្យស្លោក ផ្សព្វផ្សាយ និងប្រើប្រាស់ខ្លឹមសារ និងនិមិត្តសញ្ញាផ្សព្វផ្សាយ “ឆ្នាំទស្សនាកម្ពុជា ២០២៣" (Visit Cambodia Year 2023) ដើម្បី ផ្សារភ្ជាប់ជាមួយនឹង និមិត្តសញ្ញា។ព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេម លើកទី១២ ឆ្នាំ២០២៣" ជាមួយ រូបតំណាង "បូរី និងរំដួល” និងពាក្យស្លោក "កម្ពុជាព្រះរាជាណាចក្រ អច្ឆរិយ ផ្តល់ភាពកក់ក្តៅ” និង "គ្រប់ថ្ងៃ គឺជាអច្ឆរិយភាព” ។

៣-គ្រប់ផ្សាររដ្ឋ ផ្សារឯកជន ផ្សារមីនីម៉ាត (Mini Mart) ហាងលក់ទំនិញ ហាងលក់វត្ថុអនុស្សាវរីយ៍ និងមូលដ្ឋានអាជីវកម្មគ្រប់ប្រភេទនៅក្នុងរាជធានីភ្នំពេញត្រូវលក់ទំនិញមានបិទស្លាកតម្លៃត្រឹមត្រូវ និងគុណភាពល្អ។

៤-គ្រប់លំនៅឋាន មូលដ្ឋានអាជីវកម្ម និងការដ្ឋានសាងសង់សំណង់នានា នៅក្នុងរាជធានីភ្នំពេញ សូម ចូលរួមថែរក្សា និងសម្អាតអនាម័យ-បរិស្ថាននៅតាមទីតាំងរបស់ខ្លួន ដោយត្រូវធ្វើការបោស សម្អាត ប្រមូល ទុកដាក់ និងវេចខ្ចប់សំរាម ឬកាកសំណល់ផ្សេងៗឱ្យបានត្រឹមត្រូវតាមលក្ខណៈ បច្ចេកទេស និងបញ្ចេញឱ្យបាន ទៀងទាត់តាមពេលវេលាកំណត់។

៥-គ្រប់គេហដ្ឋាន និងមូលដ្ឋានអាជីវកម្មគ្រប់ប្រភេទនៅក្នុងរាជធានីភ្នំពេញ ត្រូវបញ្ឈប់ការហាល សម្លៀក បំពាក់ ឬសម្ភារៈប្រើប្រាស់ផ្សេងៗនៅខាងមុខ ឬលើដំបូលគេហដ្ឋានធ្វើឱ្យប៉ះពាល់ដល់ សោភ័ណភាព ។

៦-ដោយឡែកចំពោះទីតាំងដីទំនេរ និងម្ចាស់ការដ្ឋានសាងសង់សំណង់នានាដែរស្ថិតនៅតាមបណ្តោយ មហាវិថី និងវិថីសំខាន់ៗនានា ត្រូវរៀបចំធ្វើរបងបិទបាំងទីតាំងរបស់ខ្លួន ឬកែលម្អឱ្យមាន សោភ័ណភាព និង របៀបរៀបរយល្អ។

៧-បងប្អូនប្រជាពលរដ្ឋ និងគ្រប់មូលដ្ឋានអាជីវកម្មទាំងអស់ ត្រូវចូលរួមសហការជាមួយកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ដើម្បីរក្សាការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និង របៀបរៀបរយសង្គម ឱ្យបានល្អប្រសើរក្នុងអំឡុងពេលរៀបចំព្រឹត្តិការណ៍ទាំងពីរនេះ សំដៅចូលរួម លើកកម្ពស់កិត្តិនាមរបស់ព្រះរាជាណាចក្រកម្ពុជា និង ប្រជាជនកម្ពុជាទាំងមូល។

៨-រដ្ឋបាលខណ្ឌទាំង១៤ និងមន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ ត្រូវបំផុសចលនាប្រជាពលរដ្ឋ និងវិស័យឯកជនទាំងអស់ ឱ្យយល់ដឹងទូលំទូលាយពីសារសំខាន់ ដើម្បីបង្កើនការ ចូលរួមលើកទឹកចិត្ត និងគាំទ្រដល់ការរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាទាំងពីរនេះឱ្យបានផុលផុស និងអធិកអធម។[50]

## ២.៣.វិស័យទេសចរណ៍

ក្នុងឆ្នាំ២០២៣ កម្ពុជាទទួលបានទេសចរណ៍អន្តរជាតិ ប្រមាណ ៥,៤៥លាននាក់ កើនឡើង ៣២.៨ភាគរយ ធៀបនឹងឆ្នាំ២០២២ និងទេសចរជាតិចំនួន ១៨,៥លាននាក់ ដែលបង្កើនចំណូលចូលជាតិប្រមាណ ៣០០០លានដុល្លារ។ ប៉ុន្តែនៅឆ្នាំ២០២៤ កម្ពុជារំពឹងថា ចំនួនទេសចរនឹងកើនឡើងជាងឆ្នាំ២០២៣។ នេះបើតាមការឱ្យដឹងរបស់ **ឯកឧត្តម ថោង រដ្ឋសក្តិ រដ្ឋលេខាធិការក្រសួងទេសចរណ៍**។ ឯកឧត្តមបន្តថា៖ ក្រសួងបានបង្កើននូវប្រភេទសេវាកម្មទេសចរណ៍ និងព្រឹត្តិការណ៍ទេសចរណ៍សម្បូរបែបសំដៅទាក់ទាញភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិឱ្យកាន់តែច្រើនឡើងថែមទៀត ធានាឱ្យបាននូវការបង្កើតឱកាសការងារ និងបង្កើនប្រាក់ចំណូលជូនប្រជាពលរដ្ឋដោយផ្ទាល់ក្នុងមូលដ្ឋាន ជំរុញបានការនាំចេញនៅនឹងកន្លែង ពិសេសចូលរួមដល់ការអភិរក្សវប្បធម៌ និងកិច្ចការពារបរិស្ថាន ធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងការទទួលខុសត្រូវខ្ពស់ ដើម្បីឈានទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងឆ្នាំ២០៥០ ជាប្រទេសមានចំណូលខ្ពស់។ ឯកឧត្តមបានបង្ហាញឱ្យដឹងទៀតថា៖ ក្រសួងបានរៀបចំនូវគោលនយោបាយអភិវឌ្ឍន៍ទេសចរណ៍ច្បាស់លាស់ **ជាពិសេសគំនិតផ្តួចផ្តើមថ្មី បង្កើន៥ និងអភិវឌ្ឍន៍៣ រួមមាន បង្កើន៥ គឺ**

ទី១.បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងកិត្តិនាមកម្ពុជា

ទី២.បង្កើនប្រសិទ្ធភាពនៃការផ្សព្វផ្សាយភាពទាក់ទាញទេសចរណ៍កម្ពុជាទៅកាន់ទីផ្សារសំខាន់ៗ

ទី៣.បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងសម្របសម្រួលកិច្ចការផ្ទៃក្នុងដែរពាក់ព័ន្ធទៅនឹងការធ្វើដំណើររបស់ទេសចរណ៍ រួមទាំងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទន់ និងរឹង

ទី៤.បង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍផលិតផលទេសចរណ៍

ទី៥.បង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍធនធាន និងគោលដៅទាក់ទាញទេសចរណ៍ប្រកបដោយភាពប្រកួតប្រជែងខ្ពស់។

**ដោយឡែក ចំពោះការអភិវឌ្ឍ ៣ រួមមាន ៖**

ទី១.អភិវឌ្ឍន៍រចនាសម្ព័ន្ធស្ថាប័ន

ទី២.អភិវឌ្ឍន៍ប្រព័ន្ធឌីជីថល

[50] ផែនការណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញលេខ ០០៥/២៣ សនណអ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣

ទី៣.អភិវឌ្ឍធនធានមនុស្ស។[51]

ជាមួយគ្នានេះដែរទាក់ទិននឹងការខិតខំជំរុញលើវិស័យទេសចរណ៍ ក្នុងឱកាសអញ្ជើញចូលរួមវេទិកាសេដ្ឋកិច្ចពិភពលោកឆ្នាំ២០២៤ នៅទីក្រុងដាវ៉ូស ប្រទេសស្វីស កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៤កន្លងទៅ **សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃកម្ពុជា** បានជួបពិភាក្សាការងារជាមួយលោកស្រី Jane Sun អគ្គនាយិកាក្រុមហ៊ុន Trip.com ដែលជាក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្មផ្តោតជាសំខាន់លើវិស័យទេសចរណ៍ជាសកល។ នៅក្នុងកិច្ចជំនួបនោះ លោកស្រី Jane Sun បានបញ្ជាក់អំពីគោលបំណងរបស់ក្រុមហ៊ុនក្នុងការបន្តសហការជាមួយក្រុមហ៊ុនដៃគូនៅកម្ពុជា ដើម្បីនាំភ្ញៀវទេសចរណ៍ចូលមកទស្សនាប្រទេសកម្ពុជាឱ្យបានកាន់តែច្រើន។ ជាការឆ្លើយតប នាយករដ្ឋមន្ត្រីកម្ពុជាបានសម្តែងនូវក្តីរីករាយចំពោះជំនួបនាពេលនោះ និងបានបង្ហាញនូវការស្វាគមន៍ចំពោះបំណងរបស់ក្រុមហ៊ុនក្នុងការពង្រីកសកម្មភាពវិនិយោគនៅកម្ពុជា ជាពិសេសតាមរយៈកិច្ចសហការជាមួយនឹងបណ្តាក្រុមហ៊ុនដៃគូក្នុងស្រុកស្របពេលដែលរាជរដ្ឋាភិបាលបាន និងកំពុងដាក់ចេញនូវគោលនយោបាយជំរុញកំណើនវិស័យទេសចរណ៍នៅក្រោយវិបត្តិនៃជំងឺកូវីដ-១៩។[52]

ទន្ទឹមនឹងនេះផងដែលខណ្ឌចំការមន ដែរជាខណ្ឌមួយមានសក្តានុពលទេសចរណ៍ជាច្រើនដូចជាតំបន់ទេសចរណ៍វប្បធម៌ ទេសចរណ៍ធម្មជាតិ និងខ្សែទស្សនាកម្សាន្ត ផលិតផល ហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងសេវាកម្មទេសចរណ៍។ ខណ្ឌក៏បានយកចិត្តទុកដាក់លើយុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍ឱ្យកាន់តែប្រសើរឡើង។

### ២.៣.១ តំបន់ទេសចរណ៍វប្បធម៌

-បង្កលក្ខណៈងាយស្រួលដល់ផ្នែកឯកជន ក្នុងការកសាងអគារបំរើវិស័យទេសចរណ៍រួមមាន ការកម្សាន្ត រមណីយដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន ទេសចរណ៍ផ្នែកធុរកិច្ច និងពិព័រណ៍ផលិតផល

-រៀបចំបែងចែកតំបន់សណ្ឋាគារ ភោជនីយដ្ឋាន រមណីយដ្ឋាន ផ្សារទំនើប ផ្សាររាត្រី លំនៅឋានទេសចរណ៍

-កែលម្អ និងរៀបចំមហាវិថី វិថី អនុវិថី ផ្លូវសម្រាប់ដឹកជញ្ជូន ផ្លូវថ្មើរជើង សម្រាប់មនុស្សទាំងអស់គ្នាដោយរៀបចំឱ្យមានផ្លូវសម្រាប់រថយន្ត កង់ ថ្មើរជើង ផ្លូវជនពិការ និងបណ្តាញបៃតង ធានាបាននូវសោភ័ណភាព វប្បធម៌ សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងគុណភាពបរិស្ថានល្អ

-យកចិត្តទុកដាក់សុវត្ថិភាពចំណីអាហារ ដោយត្រូវជំរុញលើកកម្ពស់អនាម័យ ប្រព័ន្ធត្រួតពិនិត្យស្តង់ដា និងបញ្ហា ជំងឺឆ្លងផ្សេងៗតាមរយៈចំណីអាហារ

-ធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសាធារណៈ ដើម្បីលុបបំបាត់ឱ្យបាននូវសកម្មភាពលួច ឆក់ ការបាត់បង់របស់របរភ្ញៀវ នៅតាមដងផ្លូវ កន្លែងកម្សាន្ត កន្លែងស្នាក់នៅ និងកន្លែងផ្សេងៗទៀត

-ថែរក្សា និងការពារនូវសំណង់សម្រាប់បម្រើវិស័យវប្បធម៌ ដូចជាពោងភាពយន្ត និងអគារវប្បធម៌ ព្រមទាំងជំរុញឱ្យ មានការបើកដំណើរការឡើងវិញនូវទីតាំងទាំងនោះ។[53]

[51] គេហទំព័រ https://economy.ams.com.kh ចូលមើលថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤

[52] គេហទំព័រ https://economy.ams.com.khចូលមើលថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤

[53] ប្លង់គោលប្រើប្រាស់ដីខណ្ឌចំការមន ចក្ខុវិស័យឆ្នាំ២០៣៥

### ២.៣.២ តំបន់ទេសចរណ៍ធម្មជាតិ

-កែច្នៃទីតាំងក្រោមសួនច្បារផ្កាវាំ-ទឹកវាំ រហូតដល់ **សួនច្បារសម្តេច ហ៊ុន សែន** ដើម្បីបង្កើតជាទីតាំង ចំណតរថយន្ត សួនច្បារលំហែកម្សាន្ត សួនកុមារ ទីលានសម្រាប់ប្រជាពលរដ្ឋមកពីបណ្តាខេត្តឆ្ងាយៗកម្សាន្ត និងសេវាបម្រើវិស័យទេសចរណ៍ផ្សេងៗទៀត

-រៀបចំអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងទេសចរណ៍កែច្នៃនៅតាមដងទន្លេបាសាក់ បឹង ប្រឡាយ និងរៀបចំមហាវិថី វិថី អនុវិថី ជារុក្ខវិថី

-រៀបចំចងក្រង សហគមន៍ទេសចរណ៍ អភិវឌ្ឍន៍ទេសចរណ៍ស្នាក់នៅ និងលក់ផលិតផលក្នុងតំបន់ទេសចរណ៍វប្បធម៌

-លើកកម្ពស់ប្រសិទ្ធភាពនៃការអភិរក្ស ការការពារធនធានធម្មជាតិ និងជីវចម្រុះតាមដងទន្លេបាសាក់ បឹងត្របែក ខាងត្បូង និងប្រឡាយបឹងត្របែក

-រៀបចំសណ្តាប់ធ្នាប់ ប្រព័ន្ធចរាចរណ៍ កំពង់ចម្លង កំពង់ផែ ស្លាកសញ្ញាបង្ហាញផ្លូវទេសចរណ៍ និងប្រព័ន្ធការពារសុវត្ថិភាព

-លើកទឹកចិត្តដល់វិស័យឯកជនឱ្យមានដំណើរការបានល្អនូវសេវាកម្មនាវាកម្សាន្តនៅតាមដងទន្លេ ដើម្បីបំពេញ នូវតម្រូវការទេសចរណ៍

-រៀបចំណើច្រាំងទន្លេបាសាក់ ជាសួនច្បារ ជាតំបន់លម្ហែកម្សាន្ត និងកន្លែងទេសចរណ៍ធម្មជាតិ ដែលមានអនាម័យ បរិស្ថានល្អ រក្សានូវលក្ខណៈដើមធម្មជាតិរបស់ទន្លេ ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍

-ជំរុញឱ្យមានការរៀបចំកម្មវិធីប្រពៃណី និងកម្សាន្តផ្សេងៗ ដូចជាកម្មវិធីរាំរបាំបុរាណ ការប្រកួតអក្សរសាស្ត្រ សិល្បៈចម្រៀង ប្រណាំងទូក រត់ប្រណាំង ទិវាបរិស្ថានទីក្រុងស្អាត ដើម្បីលើកស្ទួយវិស័យទេសចរណ៍

-រៀបចំមណ្ឌលផ្សព្វផ្សាយ មណ្ឌលព័ត៌មានទេសចរណ៍ គេហទំព័រតំបន់ទេសចរណ៍ទាំងមូលហើយចាំបាច់ត្រូវតែ ភ្ជាប់ជាមួយគេហទំព័ររបស់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អតំបន់ និងតំបន់

-ធ្វើសមាហរណកម្មសេដ្ឋកិច្ចតំបន់ជុំវិញខណ្ឌទៅក្នុងវិស័យទេសចរណ៍ ដើម្បីលើកកម្ពស់ទំនិញសហគមន៍តាមរយៈសហគមន៍មួយផលិតផលមួយ និងការបង្កើតសហគមន៍ផលិតកម្មបម្រើភ្ញៀវទេសចរនៅតាមតំបន់ទេសចរណ៍ វប្បធម៌ ទេសចរណ៍ធម្មជាតិ និងខ្សែទស្សនាកម្សាន្តផលិតផល

- យកចិត្តទុកដាក់ និងពង្រឹងសុវត្ថិភាពប្រព័ន្ធឬមធ្យោបាយសង្គ្រោះបន្ទាន់ ជាពិសេសត្រូវបណ្តុះបណ្តាលមន្ត្រីជំនាញសង្គ្រោះបន្ទាន់ ឬសង្គ្រោះបឋម សន្តិសុខការពារតាមតំបន់ទេសចរណ៍វប្បធម៌ ទេសចរណ៍ធម្មជាតិ និងខ្សែទស្សនាកម្សាន្តផលិតផល ព្រមទាំងមានសម្ភារៈសង្គ្រោះគ្រប់គ្រាន់។[54]

## ២.៤ បញ្ហាបរិស្ថាន និងដំណោះស្រាយ

បរិស្ថាន គឺមានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយ និងជីវិតរស់នៅក្នុងសង្គម។ ភាវៈរស់ទាំងអស់រួមមានមនុស្ស សត្វ រុក្ខជាតិទាំងឡាយមានសុខភាពល្អ ឬមិនល្អ មានអាយុវែង ឬខ្លី គឺអាស្រ័យទៅនឹងកម្រិតបរិស្ថានដែលកំពុងរស់នៅជាមួយ។ បើសិនជាបរិស្ថានស្អាតក៏ធ្វើឱ្យជីវិតរស់នៅរបស់យើង និងសុខភាពរបស់យើងល្អ ទៅ

[54] ប្លង់គោលប្រើប្រាស់ដីខណ្ឌចំការមន ចក្ខុវិស័យឆ្នាំ២០៣៥

តាមមជ្ឈដ្ឋាននោះដែរ។ មនុស្សទាំងឡាយតែងតែគិតថាខ្លួនឯងជាចំណែកមួយផ្នែកនៃបរិស្ថាន ដែលពាក់ព័ន្ធនិងសុខុមាលភាពចាំបាច់សម្រាប់ជីវិតពួកគេ និងការអភិវឌ្ឍន៍បន្តទៀត។ ប៉ុន្តែមកដល់បច្ចុប្បន្ននេះការយល់ដឹងមួយនេះត្រូវបានអន់ថយបន្តិចម្តងៗដោយសារតែការរីកចម្រើនជឿនលឿនផ្នែកខាង ឧស្សាហកម្ម នគរូបនីយកម្ម និងការប្រើប្រាស់ដីធ្លី មនុស្សអ្នកបង្កើតនូវបញ្ហាទាំងឡាយនេះ តាមរយៈសកម្មភាព និងសេចក្តីសម្រេចចិត្ត។ ដោយសារតែសកម្មភាពរីកចម្រើនជឿនលឿនទាំងអស់នេះហើយ ទើបធ្វើឱ្យមានការផ្លាស់ប្តូរបរិស្ថានយ៉ាងឆាប់រហ័សក្នុងទ្រុងទ្រាយធំ តាមរយៈសកម្មភាពទាំងអស់របស់មនុស្ស ដូច្នេះហើយ យើងត្រូវយល់ដឹងពីបញ្ហា បរិស្ថាន និងការគ្រប់គ្រងបញ្ហាទាំងអស់នេះឱ្យបានសមស្រប ដែលអាចការពារបរិស្ថានសម្រាប់យើងផ្ទាល់ និងសម្រាប់មនុស្សជំនាន់ក្រោយៗផងដែរ។

### ២.៤.១.ការបំពុលទឹក និងដំណោះស្រាយ

ទឹកគឺជាប្រភពយ៉ាងសំខាន់សម្រាប់ទ្រទ្រង់ជីវិតមនុស្សសត្វនិងរុក្ខជាតិនៅលើភពផែនដី។ ប៉ុន្តែប្រភពទឹកក៏ទទួលរងនូវការបំពុលយ៉ាងខ្លាំងផងដែលជាហេតុនាំឱ្យមាន ផលប៉ះពាល់ទៅដល់ប្រភពទឹកស្អាតប៉ះពាល់ទៅដល់សុខភាពមនុស្ស និងជីវៈចម្រុះគ្រប់ប្រភេទ។ ប្រភេទនៃប្រភពទឹកមានការបែងចែកដាច់ដោយឡែកពីគ្នាចំណែកសារធាតុដែលចូលរួមនៅក្នុងការបំពុលទឹកក៏មានបែងចែកច្រើនប្រភេទដូចគ្នាដែលដូចជា៖

**តំបន់ទឹកសាធារណៈ**: សំដៅទៅលើទឹកសម្រាប់ប្រើប្រាស់សាធារណៈ ដូចជា ស្ទឹង ទន្លេ ជ្រោះ អូរ ព្រែក បឹង ស្រះ អណ្តូង ត្រពាំង ថ្លុក សមុទ្រ ដោយរាប់បញ្ចូលទាំងប្រឡាយធារាសាស្ត្រា និងផ្លូវទឹកដទៃទៀតដែលសម្រាប់ប្រើប្រាស់ជាសាធារណៈ និងទឹកក្រោមដី

**ប្រភពបំពុល**: សំដៅទៅលើទីតាំងអគារទាំងឡាយណា រួមទាំងលំនៅស្ថាន និងអគាររដ្ឋបាលសាធារណៈ ទីបរិវេណ មធ្យោបាយដឹកជញ្ជូន និងតំបន់សេវាកម្មដែលបញ្ចេញនូវសំណល់រាវ សារធាតុពុល ឬសារធាតុដែលបង្កឱ្យមានគ្រោះថ្នាក់ដោយផ្ទាល់ក្តី ឬមិនផ្ទាល់ក្តីចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូ

**សំណល់រាវ**: សំដៅទៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុលចូលទៅក្នុង តំបន់ទឹកសាធារណៈឬចូលទៅបណ្តាញលូសាធារណៈ ទោះមិនបានធ្វើប្រព្រឹត្តកម្មឬមិនបានធ្វើប្រព្រឹត្តកម្មក្តី

**ទឹកលូ**: សំដៅទៅលើទឹកកង្វក់ ដែលបញ្ចេញពីលំនៅស្ថាន ឬអគារសាធារណៈ

**សំរាម**: សំដៅទៅលើសារធាតុរាវ ឬរបស់រឹងដែលលែងប្រើប្រាស់ហើយបញ្ចេញពីលំនៅស្ថាន ឬអគារ

**សារធាតុបំពុល**: សំដៅទៅលើសារធាតុរឹង រាវ ឬសំណល់គ្រប់ប្រភេទដែលធ្វើឱ្យមានការប្រែប្រួលនូវសារធាតុផ្សំ ឬលក្ខណៈរបស់ទឹក ដូចជា ធ្វើឱ្យប្រែប្រួលនូវលក្ខណៈរូបគីមីឬលក្ខណៈជីវសាស្ត្ររបស់ទឹកនៅពេលបញ្ចេញឬចាក់វាចូលទៅក្នុងទឹកដោយចេតនាក្តីឬអចេតនាក្តី

**បរិមាណបំពុល**: សំដៅទៅលើបន្ទុក ឬចំណុះសារធាតុបំពុល រួមទាំងកំដៅដែលមាននៅក្នុងសំណល់រាវដែលបានបញ្ចេញចោលពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធាណៈ ឬប្រព័ន្ធលូសាធារណៈ

**សារធាតុប្រកបដោយគ្រោះថ្នាក់**: សំដៅលើសារធាតុ ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ទៅដល់សរីរាង្គមានជីវិត ឬធ្វើឱ្យខូច ឬបាក់បែករត្ថុសំភារ អាគារ ឬបណ្តាលឱ្យប៉ះពាល់មហន្តរាយដល់បរិស្ថាន។[55]

[55] អនុក្រឹត្យស្តីពីការពិនិត្យការបំពុលទឹក,លេខ២៧ អនក្រ.បក.ចុះថ្ងៃទី៦ មេសា ឆ្នាំ១១៩៩ មាត្រា៣

**ដំណោះស្រាយ**

នៅព្រះរាជាណាចក្រកម្ពុជា មុននឹងឈានដល់ដំណោះស្រាយ ក្រសួងបរិស្ថានដែលមាន សមត្ថកិច្ចក្នុងការត្រួតពិនិត្យនូវរាល់ការចាក់ចោល ឬការបង្ហូរចេញនូវសំណល់រាវ ត្រូវពិនិត្យ គុណភាពនៃទឹក និងស្វែងរកប្រភពនៃការបំពុលជាមុនសិន មុនឈានដល់ការចេញនូវដំណោះស្រាយពាក់ព័ន្ធ។[56] ការត្រួតពិនិត្យទៅលើការបំពុលទឹក គឺទប់ស្កាត់ និងកាត់បន្ថយនូវការបំពុលដើម្បី ការពារដល់សុខភាពរបស់មនុស្ស។ ការត្រួតពិនិត្យ និងស្វែងរករាល់ ប្រភពបំពុលក៏ដូចជាសកម្មភាពទាំងឡាយណាដែលបង្កឱ្យមាន ការបំពុលទឹកនៅតាមតំបន់សាធារណៈគឺជា ដំណោះស្រាយចម្បងមួយដែលល្អប្រសើរបំផុតដើម្បីធ្វើឱ្យ បរិស្ថាននៃប្រភពទឹកចៀសផុតពីការបំពុលហើយជាពិសេសគឺជួយ កែលម្អសោភ័ណភាពនិងប្រកបទៅដោយ ផាសុខភាពល្អនៅក្នុងការរស់នៅប្រចាំថ្ងៃ។ វិធានការដោះស្រាយសំខាន់ៗដែលគួរតែអនុវត្តឱ្យមានប្រសិទ្ធិភាពនិងភាពត្រឹមត្រូវមានដូចជា៖

-ហាមដាច់ខាតនូវការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ទៅក្នុងតំបន់ទឹកសាធារណៈ ឬប្រព័ន្ធលូសាធារណៈ។[57]

-ហាមឃាត់ជាដាច់ខាតនូវការបង្ហូរទឹកលូចេញពីលំនៅស្ថាន ឬពីអាគារសាធារណៈ ចូលទៅក្នុងតំបន់ទឹកសាធារណៈដោយពុំឆ្លងកាត់ប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធច្រោះសំអាតនានា។[58]

-ក្រសួងបរិស្ថានត្រូវធ្វើការត្រួតពិនិត្យ និងតាមដានជាប្រចាំពីស្ថានភាពនៃ ការបំពុលទឹកនៅតាមតំបន់សាធារណៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។[59]

-ក្រសួងបរិស្ថាន ត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពទឹក និងវាយតំលៃពីស្ថានភាពទឹកនៅតាមតំបន់ទឹកសាធារណៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។[60]

-ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ពីស្ថានភាពគុណភាពទឹក និងស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។[61]

-ក្នុងករណីដែលរកឃើញថា តំបន់ទឹកសាធារណៈត្រូវទទួលរងការបំពុល ដែលបង្កឱ្យមានការគំរាមកំហែងដល់ជីវិតមនុស្ស ឬជីវចំរុះ ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនិងជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់នេះ និងត្រូវចាត់វិធានការទប់ស្កាត់ការបំពុលទឹកតំបន់សាធារណៈ។[62]

[56] អនុក្រឹត្យស្ដីពីការពិនិត្យការបំពុលទឹក,លេខ២៧ អនក្រ.បក.ចុះថ្ងៃទី៦ មេសា ឆ្នាំ១១៩៩ មាត្រា១៨ និង១៩
[57] អនុក្រឹត្យស្ដីពីការត្រួតពិនិត្យការបំពុលទឹក,លេខ២៧ អនក្រ.បក.ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ មាត្រា៨
[58] អនុក្រឹត្យស្ដីពីការត្រួតពិនិត្យការបំពុលទឹក,លេខ២៧ អនក្រ.បក.ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ មាត្រា៩
[59] អនុក្រឹត្យស្ដីពីការត្រួតពិនិត្យការបំពុលទឹក,លេខ២៧ អនក្រ.បក.ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ មាត្រា២៦
[60] អនុក្រឹត្យស្ដីពីការត្រួតពិនិត្យការបំពុលទឹក,លេខ២៧ អនក្រ.បក.ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ មាត្រា២៧
[61] អនុក្រឹត្យស្ដីពីការត្រួតពិនិត្យការបំពុលទឹក,លេខ២៧ អនក្រ.បក.ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ មាត្រា២៨
[62] អនុក្រឹត្យស្ដីពីការត្រួតពិនិត្យការបំពុលទឹក,លេខ២៧ អនក្រ.បក.ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ មាត្រា២៩

-វិធានការសម្រាប់សាធារណៈ គឺជាកត្តាចាំបាច់បំផុតដែលត្រូវបំផុសគំនិតតាមគ្រប់មធ្យោបាយដើម្បីបង្កើនការយល់ដឹងឱ្យកាន់តែច្រើនអំពីការថែរក្សាគុណភាពទឹកស្អាតដើម្បីជាតម្រូវការប្រចាំថ្ងៃ និងចៀសវាងពីការបំពុលផ្សេងៗ។[63]

-វិធានការសម្រាប់រោងចក្រ សហគ្រាស សិប្បកម្ម : មានន័យថាគ្រប់រោងចក្រ សហគ្រាស សិប្បកម្ម និងនៅតាមបណ្តាក្រុមហ៊ុននានា ត្រូវតែអនុវត្តការគ្រប់គ្រង កាកសំណល់ឱ្យបានត្រឹមត្រូវ និងដាច់ខាតមិនត្រូវបង្ហូរកាកសំណល់សារធាតុរាវដែល មិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តកម្ម ចូលទៅប្រភពទឹកនោះទេ។ គ្រប់ស្ថាប័នដែលពាក់ព័ន្ធទាំងអស់ត្រូវចាត់វិធានការឱ្យរោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុនផ្សេងៗ ដែលបញ្ចេញនូវកាកសំណល់ជាសារធាតុរាវ ឬសារធាតុគីមីពុល ត្រូវមានការធ្វើប្រព្រឹត្តកម្មនូវសំណល់ជាសារធាតុរាវទាំងនោះជាមុនសិនមុននឹងបង្ហូរចូលទៅក្នុងទឹក ឬក៏រៀបចំឱ្យមានអាងស្តុកកាកសំណល់សារធាតុរាវ។

-ការអនុវត្តន៍ច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់: ត្រូវមានការត្រួតពិនិត្យសារធាតុពុល និងការត្រួតពិនិត្យក្នុងការគ្រប់គ្រងសំណល់ជាសារធាតុរាវ ដែលនាំឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការបំពុល ឱ្យបានម៉តចត់និងត្រូវចាត់វិធានការយ៉ាងតឹងរឹង ចំពោះគ្រប់មធ្យោបាយដែលបង្ហូរកាកសំណល់ជាសារធាតុរាវទៅក្នុងប្រភពទឹក។

### ២.៤.២.ការបំពុលខ្យល់ និងដំណោះស្រាយ

បរិយាកាស គឺជាប្រព័ន្ធធម្មជាតិយ៉ាងរឹងមាំដែលទ្រទ្រង់រាល់ជីវិតមនុស្ស សត្វនានា នៅលើផែនដី។ ការបំផ្លាញស្រទាប់អូហ្សូន គឺជាការបំផ្លាញទាំងការពារផែនដីពីកាំរស្មីអ៊ុលត្រាវីយ៉ូឡេ ដែលបង្កផលវិបាកដល់ជីវិតលើផែនដី។ នៅក្នុងអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង លេខ៤២ អនក្រ.បក ចុះថ្ងៃទី១០ កក្កដា ឆ្នាំ២០០០ បានបង្ហាញអំពីសារធាតុដែលនាំឱ្យមានការបំពុលខ្យល់មានពីរគឺ៖

- សារធាតុបំពុល សំដៅទៅលើផ្សែង លំអងផ្សែង ធូលី ផេះ ភាគល្អិតនៃសំណល់ឧស្ម័ន ចំហាយទឹក អ័ព្ទ ក្លិន និងសារធាតុវិទ្យុសកម្ម
- សារធាតុឆេះ សំដៅទៅលើប្រេងឥន្ទន ធ្យូងថ្ម ឧស្ម័នធម្មជាតិ អុស ធ្យូស ឬសារធាតុគីមីផ្សេងៗទៀតដែលមានប្រតិកម្មចំហេះ។[64]

សកម្មភាព និងមូលហេតុដែលបង្កឱ្យកើតមាននូវសារធាតុបំពុលទាំងនេះរួមមាន៖

_ ការដុតឥន្ទនៈហ្វូសិល ( ប្រេង ធ្យូង ម៉ាសូត សាំង )

_ ឧស្ម័នផ្ទះកញ្ចក់

_ការបំពុលដោយធូលី

[63] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក,លេខ២៧ អនក្រ.បក.ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ មាត្រា១៨ និង១៩

[64] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង លេខ៤២ អនក្រ.បក ចុះថ្ងៃទី១០ កក្កដា ឆ្នាំ២០០០ មាត្រា៣

_ ការបម្រែបម្រួលអាកាសធាតុ

_ ផ្សែងពុលចេញពីរោងចក្រគ្រឿងចាស់ៗ ដូចជាយានយន្ត ម៉ាសីនត្រជាក់ គ្រឿងចាក់ជាដើម

_ ភ្លៀងអាស៊ីត

_ ផេះពីបន្ទុះភ្នំភ្លើង

_ ផ្សែងពុលចេញពីឈាបនដ្ឋាន។

ការបំពុលខ្យល់ គឺវាមិនត្រឹមតែធ្វើឱ្យប៉ះពាល់ទៅដល់ បរិយាកាសអាកាសធាតុព្រមទាំងបរិស្ថានតែប៉ុណ្ណោះទេ តែវាថែមទាំងមានផលប៉ះពាល់ទៅដល់ សុខភាពរបស់មនុស្ស សត្វ តាមរយះការដកដង្ហើមដែលជាហេតុបណ្តាលឱ្យកើតមាននូវជម្ងឺផ្លូវដង្ហើម ជម្ងឺសួត ជំងឺភ្នែក ជំងឺសើរស្បែកជាដើម។[65]

**ដំណោះស្រាយ**

-កំរិតស្តង់ដាគុណភាពខ្យល់ និងកំរិតកំណត់ស្តង់ដារអតិបរិមាណនៃសារធាតុប្រកបដោយគ្រោះថ្នាក់ដែលអនុញ្ញាតឱ្យមាននៅក្នុងខ្យល់។[66]

-ហាមឃាត់ដាច់ខាតនូវការបញ្ចេញសារធាតុបំពុលទៅក្នុងបរិយាកាស ដែលមិនឆ្លើយតបទៅនឹងកំរិតស្តង់ដា។[67]

-ហាមដាច់ខាតការបង្ហូរ ឬការធ្វើឱ្យលេចធ្លាយសារធាតុឆេះ ប្រេងឥន្ទន ធាតុវិទ្យុសកម្ម ឬសារធាតុគីមីផ្សេងៗទៀតចូលក្នុងបរិយាកាស ទឹក និងដី។[68]

-កាត់បន្ថយការប្រើប្រាស់យានយន្តដែលជាហេតុនាំឱ្យមានផ្សែងបំពុលចូលទៅក្នុងបរិយាកាស

-កាត់បន្ថយការដុតកាកសំណល់កសិកម្ម និងការដុតអូស ដើម្បីកាបន្ថយកម្រិតផ្សែងពុល និងកាបូនឌីអុកស៊ីតនៅក្នុងខ្យល់

-ចាត់វិធានការច្បាប់ឱ្យបានតឹងរឹងចំពោះជនដែលបាន ល្មើសច្បាប់ដោយត្រូវផាកពិន័យ ឬផ្តន្ទាទោសតាមច្បាប់ដែលបានកំណត់។[69]

[65] គេហទំព័រ https://www.khsearch.com ដកស្រង់ថ្ងៃទី ១៥ កក្កដា ឆ្នាំ២០២៤

[66] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង លេខ៤២ អនក្រ.បក ចុះថ្ងៃទី១០កក្កដាឆ្នាំ២០០០ មាត្រា៤

[67] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង លេខ៤២ អនក្រ.បក ចុះថ្ងៃទី១០កក្កដាឆ្នាំ២០០០ មាត្រា៨

[68] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង លេខ៤២ អនក្រ.បក ចុះថ្ងៃទី១០កក្កដាឆ្នាំ២០០០ មាត្រា១២

[69] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង លេខ៤២ អនក្រ.បក ចុះថ្ងៃទី១០ កក្កដា ឆ្នាំ២០០០ មាត្រា៨ មាត្រា១០ មាត្រា១១ មាត្រា១២

### ២.៤.៣.ការបំពុលដោយសំលេង និងដំណោះស្រាយ

ជាការពិតណាស់ការបំពុលដោយសូរសំលេង គឺជាបញ្ហាបរិស្ថានដ៏ចម្បងនៅក្នុងទីក្រុងដែលប្រមូលផ្តុំដោយសំលេងចរាចរណ៍ សំលេងយន្តហោះ សំលេងរថភ្លើង សំលេងតន្ត្រី ឧបករណ៍បំពងសំលេង និងសំលេងដែលចេញពីរោងចក្រ សហគ្រាស សិប្បកម្មជាដើម គឺសុទ្ធសឹងតែជាបណ្តុំនៃការ បំពុលដោយសំលេង។ បើទោះបីជាមនុស្សមួយចំនួនយល់ថា ការបំពុលដោយសំលេង មិនសូវជាមានផលប៉ះពាល់ក៏ដោយតែវា ក៏អាចជះឥទ្ធិពលអាក្រក់ខ្លាំងចំពោះ ជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សគ្រប់គ្នា។ ដោយអនុលោមតាម អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីអំពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ បានបង្ហាញថាមូលហេតុដែលនាំឱ្យមានការបំពុលដោយសំលេងគឺមកពីប្រភពធំៗចំនួន២ គឺៈ

>ការបំពុលដោយប្រភពចល័តៈ គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មានៈ យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និង គ្រឿងបំពងសំលេងគ្រប់ប្រភេទ

>ការបំពុលដោយប្រភពអចល័តៈ គឺជាប្រភពដែលស្ថិតនៅទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មានៈ រោងចក្រ សហគ្រាស ឃ្លាំងស្តុកសំភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំលេង សិប្បកម្ម រួមនិងកសិដ្ឋានគ្រប់ប្រភេទ។[70]

**ដំណោះស្រាយ**

ការចូលរួមចំណែកដើម្បីការ កាត់បន្ថយការប្រើប្រាស់ឧបករណ៍ដែលមានសំលេងរំពងខ្លាំងមិនត្រឹមតែជាឥរិយាបថប្រកបដោយ សីលធម៍ប៉ុណ្ណោះទេតែវាក៏អាចជួយដោះស្រាយ បញ្ហាប្រឈមសុខភាពផ្សេងៗផងដែល។ជាមួយគ្នានេះដែលដើម្បី ដោះស្រាយការបំពុលដោយសំលេងមានវិធានការដូចជាៈ

-ត្រូវអប់រំដែលប្រជាពលរដ្ឋឱ្យបានយល់នូវបញ្ហានៃផលប៉ះពាល់និងធ្វើការផ្សព្វផ្សាយច្បាប់តាមគ្រប់មធ្យោបាយដើម្បីឱ្យប្រជាជនមានការយល់ដឹងព្រមទាំងចូលរួមកាត់បន្ថយការបំពុលដោយសំលេង។

-ហាមឃាតដាច់ខាតនូវការបង្កឱ្យមានសំលេង ដែលមិនឆ្លើងតបទៅនិងកំរិតស្តង់ដារ។[71]

-ហាមឃាត់ដាច់ខាត ការប្រើប្រាស់ និងផលិតយានយន្ត និងគ្រឿងយន្តគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ដែលយានយន្ត និងគ្រឿងយន្តទាំងនោះបានបញ្ចេញសារធាតុបំពុលនិងសំលេងមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ។[72]

-កម្រិតស្តង់ដារបញ្ចេញសំលេងចេញពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកំរិតស្តង់ដារសំលេងជាអតិបរិមាសម្រាប់ទីកន្លែងសាធារណៈនិងតំបន់លំនៅដ្ឋាន។[73]

[70] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង លេខ៤២ អនក្រ.បក ចុះថ្ងៃទី១០ កក្កដា ឆ្នាំ២០០០ មាត្រា៣

[71] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង លេខ៤២ អនក្រ.បក ចុះថ្ងៃទី១០ កក្កដា ឆ្នាំ២០០០ មាត្រា៩

[72] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង លេខ៤២ អនក្រ.បក ចុះថ្ងៃទី១០កក្កដាឆ្នាំ២០០០មាត្រា១១

[73] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង លេខ៤២ អនក្រ.បក ចុះថ្ងៃទី១០កក្កដាឆ្នាំ២០០០មាត្រា៧

ជាមួយគ្នានេះការបញ្ចេញសំលេងពីប្រភពយានយន្តទីតាំងផលិតកម្មផ្សេងៗ ការប្រើប្រាស់ ម៉ាស៊ីនភ្លើង សំលេងរំខានដែលចេញពីការដ្ឋានសំណង់នានា សំលេងដែលចេញពីក្លឹបកម្សាន្ត ខារ៉ាអូខេ ធុងបាស និងការប្រើប្រាស់ឧបករណ៍បំពងសំលេងគ្រប់ប្រភេទ ជាពិសេសសំលេងរំខានដែល កើតចេញពីការកែច្នៃបំពង់ស៊ីម៉ាំងខុសពីបច្ចេកទេស ដែលបង្កឱ្យមានការបំពុលដោយសំលេងគឺត្រូវធ្វើការហាមឃាត់ឱ្យបាន។ ហើយគប្បីកម្រិតស្តង់ដារនៃការបញ្ចេញសំលេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកម្រិតស្តង់ដារសំលេងជាអតិបរមាសម្រាប់ទីកន្លែងសាធារណៈនិងតំបន់ លំនៅដ្ឋាន។

## ២.៤.៤.ការបំពុលដោយសំណល់រឹង រាវ និងដំណោះស្រាយ

សំណល់រឹង និងសំណល់រាវ ប្រសិនបើជាមនុស្សមិនបានរៀបចំទុកដាក់អោយមានភាពត្រឹមត្រូវទេនោះវានិងបង្កអោយមានការបំពុល និងបញ្ហាផ្សេងៗទៀតដូចជាបង្កអោយមានសំរាមពាសវាលពាសកាលពេញផ្ទៃដីដែលបង្កអោយមានការស្ទះលូរៀងរាល់ពេលមានភ្លៀងធ្លាក់ដែលជា ហេតុបណ្តាលអោយមានការជន់លិចទឹកជាដើម។ ជារៀងរាល់ថ្ងៃសំរាមនិងកាកសំណល់ផ្សេងៗត្រូវបានចាក់ចោលបើទោះបីជាសំរាមប្រភេទណាក៏ដោយ ប្រសិនបើយើងមិនមាន ការទុកដាក់វេចខ្ចប់អោយបានត្រឹមត្រូវទេនោះវានិងមាន ផលប៉ះពាល់ទៅដល់បរិស្ថាន សុខភាពមនុស្សសត្វព្រមទាំងសោភ័ណភាពថែមទៀតផង។ ជាមួយគ្នានេះដែលយោងទៅតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង,លេខ៣៦ អនក្រ.បក,ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩បានអោយនិយមន័យដោយឡែកពីគ្នាអំពីសំណល់រឹង និងរាវះ

សំណល់រឹង : សំដៅទៅដល់វត្ថុរឹង សារធាតុ ផលិតផល ឬរបស់កំទេចកំទីដែលលែងត្រូវការប្រើប្រាស់ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោលឬតម្រូវឱ្យបោះបង់ចោល។[74]

សំណល់រាវ : គឺសំដៅដល់វត្ថុរាវដែលបញ្ចេញពីប្រភពបំពុល ដែលហូរចូលទៅ ក្នុងតំបន់សាធារណៈឬហូរចូលទៅក្នុងបណ្តាញលូ ទោះមិនបានធ្វើប្រព្រឹត្តកម្ម ឬបានធ្វើប្រព្រឹត្តកម្មក្តី។[75]

### ដំណោះស្រាយ

នៅក្នុងព្រះរាជាណាចក្រកម្ពុជា ការគ្រប់គ្រងសំណល់រឹងគឺត្រូវបានរៀបចំ និងអនុវត្តដោយ បន្ថែមអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង ដែលបានចែងទាក់ទងទៅនឹងការគ្រប់គ្រងសំរាមទាំង ២ប្រភេទះ គឺសំរាមធម្មតា និងសំរាមដែលប្រកបដោយគ្រោះថ្នាក់។ ក្នុងនោះដែលការរៀបចំ និងចាត់ចែងសំរាមទាំង ២ប្រភេទនេះត្រូវស្ថិតនៅក្រោមការសម្រេចរបស់ ក្រសួងបរិស្ថានក្នុងការពិនិត្យលើការអនុវត្តរៀបចំក្នុងការប្រមូលយកទៅបោះចោល

[74] អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង,លេខ៣៦ អនក្រ.បក,ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩, មាត្រា៣

[75] អនុក្រឹត្យស្តីពីការពិនិត្យការបំពុលទឹក,លេខ២៧ អនក្រ.បក.ចុះថ្ងៃទី៦ មេសា ឆ្នាំ១១៩៩ មាត្រា៣

ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយ និងការចាក់ ចោលសំរាម។[76] ចំពោះវិធានការសម្រាប់ការគ្រប់គ្រងនិងដំណោះស្រាយចំពោះកាកសំណល់រឹងមានដូចជា៖

-រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត ជាមួយក្រសួងស្ថានប័ន និងដៃគូដែលពាក់ព័ន្ធ។

-អប់រំផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងក្នុងទីប្រជុំជនប្រកបដោយសុវត្ថិភាពនិងបរិស្ថាន។

-លើកទឹកចិត្តទៅដល់ប្រជាជននៅក្នុងការប្រើប្រាស់សំភារដែលអាចកែច្នៃបានឡើងវិញ ព្រមទាំងការជំរុញអោយមានការផលិតសំភារៈដែលមិនមានផលប៉ះពាល់ទៅដល់បរិស្ថាន។

-ក្រសួងបរិស្ថានត្រូវរៀបចំប្រកាស ស្តីពីគោលការណ៍ណែនាំលើការប៉ះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណសំរាម និងការចាក់ចោលសំរាម តាមបណ្តាលខេត្ត ក្រុង ដើម្បីធានាបាននូវការគ្រប់គ្រងសំរាម ប្រកបដោយសុវត្ថិភាព។ អាជ្ញាធរខេត្ត ក្រុងត្រូវរៀបចំផែនការគ្រប់គ្រងសំរាម ក្នុងខេត្ត ក្រុងរបស់ខ្លួនសំរាប់ រយះពេលខ្លី រយះពេលមធ្យម រយះពេលវែង។[77]

-ណែនាំទៅដល់ប្រជាជនអោយមានការយល់ដឹង អំពីការបែងចែងកាកសំណល់ទៅតាមប្រភេទដូចជាត្រូវ វេចខ្ចប់ ការទុកដាក់សំរាម សំណល់រឹង ដែលអាចបង្កអោយមានគ្រោះថ្នាក់ដូចជា អំបែងកែវ ដប កញ្ចក់ ម្ជុល និងវត្ថុដែលបង្កគ្រោះថ្នាក់ផ្សេងៗទៅក្នុងថង់ពណ៌ក្រហម ឬធ្វើជាសញ្ញាសំគាល់ដើម្បីបញ្ជាក់ប្រាប់ដល់កម្មករប្រមូលសម្រាមអោយមានការប្រុងប្រយ័ត្ន។[78]

ចំណែកវិធានការសម្រាប់ការគ្រប់គ្រងនិងដំណោះស្រាយចំពោះកាកសំណល់រាវមានដូចជា៖

-ហាមដាច់ខាតនូវការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ទៅក្នុងតំបន់ទឹកសាធារណៈ ឬប្រព័ន្ធលូសាធារណៈ។[79]

-ហាមឃាត់ជាដាច់ខាតនូវការបង្ហូរទឹកលូចេញពីលំនៅស្ថាន ឬពីអាគារសាធារណៈ ចូលទៅក្នុងតំបន់ទឹកសាធារណៈដោយពុំឆ្លងកាត់ប្រព័ន្ធលូសាធារណ ឬប្រព័ន្ធច្រោះសំអាតនានា។[80]

-ក្រសួងបរិស្ថានត្រូវធ្វើការត្រួតពិនិត្យ និងតាមដានជាប្រចាំពីស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់សាធារណៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។[81]

[76] អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង,លេខ៣៦ អនក្រ.បក,ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩, មាត្រា៦

[77] អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង,លេខ៣៦ អនក្រ.បក,ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩, មាត្រា៤

[78] សេចក្តីណែនាំ លេខ០០៩/១៩ សណន.ស ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ស្តីពីការវេចខ្ចប់ ការទុកដាក់សំរាម

[79] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក,លេខ២៧ អនក្រ.បក.ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ មាត្រា៨

[80] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក,លេខ២៧ អនក្រ.បក.ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ មាត្រា៩

[81] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក,លេខ២៧ អនក្រ.បក.ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ មាត្រា២៦

-ក្រសួងបរិស្ថាន ត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពទឹក និងវាយតំលៃពីស្ថានភាពទឹកនៅតាមតំបន់ទឹកសាធារណៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។[82]

-ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ពីស្ថានភាពគុណភាពទឹក និងស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។[83]

-ក្នុងករណីរកឃើញថា នៅតំបន់ទឹកសាធារណៈត្រូវទទួលរកការបំពុល ដែលបង្កអោយមានការគំរាមកំហែងដល់ជីវិតមនុស្ស ឬជីវចំរុះ ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនិងជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់នេះ និងត្រូវចាត់វិធានការទប់ស្កាត់ការបំពុលទឹកតំបន់សាធារណៈ។[84]

### ២.៤.៥.ការបំពុលដី និងដំណោះស្រាយ

ដីគឺជាកត្តាដ៏ចាំបាច់បំផុតសម្រាប់ការដុះលូតលាស់នៃដំណាំ ហើយដំណាំអាចលូតលាស់បានល្អលុះត្រាតែដីនោះមានគុណភាពល្អសមស្របតាមតម្រូវការនៃរុក្ខជាតិ។ ប៉ុន្តែដំណាំអាចនឹងលូតលាស់មិនបានល្អនៅពេលដែលគុណភាពនៃដីធ្លាក់ចុះ។ ទាំងនេះគឺជាកត្តាមួយចំនួនដែលធ្វើឱ្យដីបាត់បង់គុណភាពសម្រាប់រុក្ខជាតិមានដូចជា៖

កត្តាមនុស្ស: សកម្មភាពរបស់មនុស្សជារៀងរាល់ថ្ងៃពិតជាផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងទៅកាន់បរិស្ថានដូចជា ការចោលសំរាមពាសវាលពាសកាល ការចោលសំណល់រឹង ការចាក់សារធាតុកង្វក់ ដែលបង្កគ្រោះថ្នាក់ទៅដល់ដីដែលជាហេតុនាំអោយមានការបំពុលដី ធ្វើឱ្យដីបាត់បង់គុណភាពជីជាតិ

កត្តាកសិកម្ម: នៅក្នុងសកម្មភាពកសិកម្ម កសិករបានប្រើប្រាស់នូវប្រភេទថ្នាំពុលដើម្បីកំចាត់សត្វល្អិត ជំងឺ និងស្មៅចង្រៃ ហើយវាបានផ្តល់នូវគុណសម្បត្តិ និងបន្សល់ទុកនូវគុណវិបត្តិនៃការសល់សារធាតុប៉ះពាល់ទៅដល់ដីមួយចំនួនផងដែរ។ ម៉្យាងទៀតការធ្វើឧស្សាហ៍កម្មជីកយករ៉ែ ការបោះចោលនូវកាកសំណល់ពុលមិនបានត្រឹមត្រូវ ក៏ជាកត្តារួមផ្សំដែលធ្វើឱ្យដីរងនូវសំណឹកជាដើម

ការកាប់បំផ្លាញព្រៃឈើ: ការកាប់ព្រៃដើម្បីធ្វើកសិកម្មគឺជាសកម្មភាពមួយដែលអាចបណ្តាលឱ្យដីធ្លាក់ចុះនូវគុណភាព ព្រោះវាបានគំរាមគំហែងទៅដល់ជីវៈចម្រុះ( ដី ទឹក សត្វ មនុស្ស រុក្ខជាតិ...) ព្រមទាំងរំខានទៅដល់តុល្យភាពនៃប្រព័ន្ធអេកូឡូស៊ីផងដែរ។ ដោយឡែកនៅពេលដែលដីបាត់បង់នូវគម្របវាក៏ងាយនឹងបាត់បង់តុល្យភាព និងធ្វើឱ្យឆាប់សឹករិចរិលជាដើម។[85]

ការប្រែប្រួលអាកាសធាតុ: ការផ្លាស់ប្តូរនៃអាកាសធាតុមានឥទ្ធិពលទៅលើ៖

---
[82] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក,លេខ២៧ អនក្រ.បក.ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ មាត្រា២៧

[83] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក,លេខ២៧ អនក្រ.បក.ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ មាត្រា២៨

[84] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក,លេខ២៧ អនក្រ.បក.ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ មាត្រា២៩

[85] គេហទំព័រ https://kaksekam-time.com ដកស្រង់ថ្ងៃទី១៥ កក្កដា ឆ្នាំ២០២៤

-ការកើនឡើងនៃសំណឹកតាមរយៈការផ្លាស់ប្តូរគំរូទឹកភ្លៀងដែលបង្កឱ្យមានព្យុះ និងភ្លៀងធ្លាក់ខ្លាំងដែលជាហេតុធ្វើឱ្យហូរច្រោះដី

-ការផ្លាស់ប្តូរសំណើមកើតឡើងតាមរយៈការកើនកម្តៅដែលធ្វើឱ្យដីឆាប់ហួត ដោយបង្កឱ្យប៉ះពាល់ដល់រចនាសម្ព័ន្ធដី លទ្ធិភាពនៃសារធាតុចិញ្ចឹម និងសកម្មភាពអតិសុខុមប្រាណក្នុងដី

-ដីកើនអំបិលនៅពេលដែលមានការផ្លាស់ប្តូររបបទឹកភ្លៀង និងសីតុណ្ហភាពនៅត្រង់ទីតាំងដែលស្ងួត និងពាក់កណ្តាលស្ងួត

-ការផ្លាស់ប្តូរpHដី និងប៉ះពាល់ដល់សារពាង្គកាយដីជាដើម។[86]

## ដំណោះស្រាយ

វិធានការនិងច្បាប់គតិយុត្តដើម្បីដោះស្រាយចំពោះការបំពុលដីរួមមានដូចជា៖

-អប់រំផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងក្នុងទីប្រជុំជនប្រកបដោយសុវត្ថិភាពនិងបរិស្ថាន។

-លើកទឹកចិត្តទៅដល់ប្រជាជននៅក្នុងការប្រើប្រាស់សំភារះដែលអាចកែច្នៃបានឡើងវិញ ព្រមទាំងការជំរុញឱ្យមានការផលិតសំភារដែលមិនមានផលប៉ះពាល់ទៅដល់បរិស្ថាន។

-ក្រសួងបរិស្ថានត្រូវរៀបចំប្រកាស ស្តីពីគោលការណ៍ណែនាំលើការប៉ះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណសំរាម និងការចាក់ចោលសំរាម តាមបណ្តាលខេត្ត ក្រុង ដើម្បីធានាបាននូវការគ្រប់គ្រងសំរាម ប្រកបដោយសុវត្ថិភាព។ អាជ្ញាធរខេត្ត ក្រុងត្រូវរៀបចំផែនការគ្រប់គ្រងសំរាម ក្នុងខេត្ត ក្រុងរបស់ខ្លួនសំរាប់ រយៈពេលខ្លី រយៈពេលមធ្យម រយៈពេលវែង។[87]

-គ្មានរូបបវន្តបុគ្គល ឬនីតិបុគ្គលណាមួយមានសិទ្ធិផ្តល់ការអនុញ្ញាត ទោះផ្ទាល់ក្តី ឬដោយប្រយោលក្តី ឱ្យកាប់ដើមឈើ រានដីព្រៃឈើ ឬធ្វើសកម្មភាពគ្រប់យ៉ាងដើម្បីប្រមូលផលអនុផល អនុផលព្រៃឈើ ឬកាន់កាប់ដីក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃន៍ ផ្ទុយនិងបទប្បញ្ញត្តិនេះឡើយ។[88]

-កាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិច ដប ឬកំប៉ុងជ័រ។

-ហាមឃាត់ការប្រើប្រាស់សារធាតុគីមី ឬជីគីមីនៅក្នុងបរិមាណមួយដែលសមរម្យដែលមិនមានផលប៉ះពាល់ធ្ងន់ធ្ងរទៅដល់គុណភាពដី។

-ហាមដាច់ខាតការបង្ហូរ ឬការធ្វើឱ្យលេចធ្លាយសារងាយធាតុឆេះ ប្រេងឥន្ធនៈ ធាតុវិទ្យុសកម្ម ឬសារធាតុគីមីផ្សេងៗទៀតចូលក្នុងបរិយាកាស ទឹក និងដី។[89]

[86] គេហទំព័រ https://kaksekam-time.com ដកស្រង់ថ្ងៃទី១៥ កក្កដា ឆ្នាំ២០២៤

[87] អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង,លេខ៣៦ អនក្រ.បក,ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩, មាត្រា៤

[88] ច្បាប់ស្តីពីព្រៃឈើ នស\រកម\០៨០២\០១៦ ចុះថ្ងៃទី ៣០ កក្កដា ឆ្នាំ២០០២ មាត្រា៣៩

[89] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង លេខ៤២ អនក្រ.បក ចុះថ្ងៃទី១០កក្កដាឆ្នាំ២០០០មាត្រា១២

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

យោងតាមការបកស្រាយខាងលើឃើញថា ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពពិតជាមាន សារៈសំខាន់ណាស់ដើម្បីធ្វើឱ្យទីក្រុងមានរបៀបរៀបរយ និងបរិស្ថានល្អ។ ដោយឡែកបើទោះបីជា ខណ្ឌចំការមន មានការអភិវឌ្ឍន៍យ៉ាងច្រើនស្ទើរគ្រប់វិស័យពិតមែន ក៏នៅតែមានជួបនូវបញ្ហាប្រឈមមួយចំនួននៅឡើយ ជាក់ស្តែងការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាព ក្នុងខណ្ឌចំការមន ក៏កំពុងជួបប្រទះដូចខណ្ឌដទៃទៀតដែល មានន័យថា ថ្វីត្បិតតែខណ្ឌ បានរៀបចំឱ្យមាននូវហេដ្ឋារចនាសម្ព័ន្ធ លូទឹកស្អាត ទឹកស្អុយ សួនច្បារ បង្គោលភ្លើងបំភ្លឺផ្លូវ ការការពារនូវសន្តិសុខ សណ្តាប់ធ្នាប់ ជាពិសេសបញ្ហាបរិស្ថាន និងអនាម័យ ពិតមែនក៏ខណ្ឌនៅតែជួបប្រទះបញ្ហាមួយចំនួនតូចផងដែរ។ ជាក់ស្តែងបញ្ហាសណ្តាប់ និងសោភ័ណភាព គឺជាបញ្ហាដែលត្រូវយកចិត្តទុកដាក់បន្ថែមទៀត ជាពិសេសទៅលើការរៀបចំឱ្យមាននូវហេដ្ឋារចនាសម្ព័ន្ធ និងការកែប្រែបរិស្ថានក្នុងខណ្ឌឱ្យរឹតតែល្អប្រសើរបន្ថែមទៀត។ ម្យ៉ាងទៀតការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងចិញ្ចើមផ្លូវសាធារណៈ សំណង់មិនរៀបរយ ការគ្រប់គ្រងកាកសំណល់តាមផ្ទះ ការវេចខ្ចប់សំរាម ការប្រើប្រាស់ថង់ប្លាស្ទិច សំរាមរាយប៉ាយទុកដាក់មិនបានត្រឹមត្រូវ ទាំងនេះដែលជាហេតុធ្វើឱ្យមានការកកស្ទះប្រព័ន្ធ លូបង្ហូរទឹក នឹងឈានទៅដល់ការលិចលង់តាមដងវិថីនានា នៅពេលមានភ្លៀងធ្លាក់រយៈពេលយូរ ដែលបណ្តាលធ្វើឱ្យពិបាកក្នុងការធ្វើដំណើរ ដែលបញ្ហាទាំងនេះនូវតែជាបញ្ហាស្មុកស្មាញដែលរដ្ឋបាលខណ្ឌកំពុងតែដោះស្រាយ។

ទន្ទឹមនឹងនេះផងដែលការសិក្សាស្វែងយល់ទៅលើប្រធានបទសារណា "**ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខណ្ឌចំការមន**" បានធ្វើឱ្យយើងខ្ញុំទាំងពីរនាក់មានការយល់ឃើញយល់ពីផលប៉ះពាល់នៃការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាព ហើយថែមទាំងយល់ដឹងពីផលប្រយោជន៍នៃការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពផងដែរ។ ផលប្រយោជន៍ដែលទទួលបានគឺធ្វើឱ្យខណ្ឌ មានសោភ័ណ្ឌភាព និងមានរបៀបរៀបរយ គ្មានការបំពុលដែលធ្វើឱ្យខណ្ឌនេះមានភាពទាក់ទាញ និងការអភិវឌ្ឍន៍ ជាពិសេសការរក្សាបាននូវសន្តិសុខសុវត្ថិភាព មានភាពស៊ីវីល័យ ឬភាពទាន់សម័យទៅនឹងសង្គមបច្ចុប្បន្ន។

សរុបសេចក្តីមកអាចសន្និដ្ឋានបានថា ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាព គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីឈានទៅរកការអភិវឌ្ឍន៍ និងការរីកចម្រើនរបស់ប្រទេស បើទោះបីជាក្នុងពេលនេះមិនទាន់ទទួលបានជោគជ័យទាំងស្រុងក៏ពិតមែន ប៉ុន្តែទៅថ្ងៃខាងមុខពិតជាទទួលបាននូវភាពជោគជ័យជាងនេះជាក់ជាមិនខាន ប្រសិនបើមានការចូលរួមសហការគ្នារវាងរាជរដ្ឋាភិបាល ជាអាជ្ញាធរមូលដ្ឋាន ក្រសួង ឬស្ថាប័នពាក់ព័ន្ធផ្សេងៗ និងបងប្អូន ប្រជាពលរដ្ឋ នោះប្រាកដជាទទួលបាននូវទេសភាពស្រស់បំព្រង និងបរិយាកាសក្នុងការរស់នៅល្អ ប្រកបដោយផាសុខភាព និងភាពយូរអង្វែង។

# អនុសាសន៍

# អនុសាសន៍

យោងតាមការបកស្រាយខាងលើឃើញថា ខណ្ឌចំការមនក៏ជួបនូវបញ្ហាប្រឈមមួយចំនួនផងដែរ បញ្ហាដែលបានកើតឡើងនោះភាគច្រើនជារឿងដដែល បើទោះបីជាមានការអភិវឌ្ឍន៍ខ្លះក៏ពិតមែនប៉ុន្តែវានៅតែចោទជាបញ្ហាដែលប្រជាពលរដ្ឋចង់ឱ្យអាជ្ញាធរធ្វើការកែសម្រួលនូវបញ្ហាទាំងនេះ ដែលមានដូចជា ផ្លូវ ប្រព័ន្ធលូ ការលក់ដូរ និងការចតយានយន្តលើផ្លូវគ្មានសណ្តាប់ធ្នាប់ និងបញ្ហាសន្តិសុខសណ្តាប់ធ្នាប់ផ្សេងៗ។ ម៉្យាងវិញទៀត បញ្ហាកាកសំណល់ ឬសំរាមវាជាបញ្ហាដែលកើតមានដែរ ព្រោះសំរាមតាមដងផ្លូវ និងការទុកដាក់គ្មាន សណ្តាប់ធ្នាប់ ដែលបានធ្វើឱ្យមានការបំពុលដល់បរិស្ថាន និងធ្វើឱ្យមានការកកស្ទះដល់ប្រព័ន្ធលូ បង្ហូរទឹកផ្សេងៗ។ ដើម្បីដោះស្រាយនឹងបញ្ហាទាំងនេះ ខ្ញុំទាំងពីរសូមមានមតិយោបល់ដូចតទៅៈ

-សូមអំពាវនាវដល់អាជ្ញាធរគ្រប់ជាន់ថ្នាក់ សូមជួយយកចិត្តទុកដាក់ឱ្យបានខ្ពស់ទៅលើបញ្ហា ទាំងអស់នេះដូចជាសន្តិសុខ សណ្តាប់ធ្នាប់ និងបន្ថែមការប្រុងប្រយ័ត្នចំពោះបញ្ហាចោរកម្ម ក្មេងទំនើង និងត្រួតពិនិត្យពីបញ្ហាបរិស្ថាន ដើម្បីកុំឱ្យមានការបំពុលដល់បរិយាកាស។

-សូមអំពាវនាវដល់សាលារាជធានីភ្នំពេញ សូមឱ្យមានការផ្តល់នូវកញ្ចប់ថវិកាទៅដល់ខណ្ឌ ចំការមន បន្ថែមទៀត ដើម្បីឱ្យខណ្ឌមានការអភិវឌ្ឍន៍ក្នុងខណ្ឌរបស់ខ្លួន។

-សូមអំពាវនាវដល់រាជរដ្ឋាភិបាល សូមឱ្យមានការអភិវឌ្ឍន៍លើបណ្តាវិថីឱ្យបានច្រើន ដើម្បីប្រែក្លាយពីផ្លូវដីឱ្យទៅជាផ្លូវបេតុង ឬថ្នល់កៅស៊ូជាដើម ហើយក៏សំណូមពរផងដែរចំពោះប្រព័ន្ធលូ សាធារណៈ សូមមេត្តារៀបចំឱ្យបានល្អ (ពីលូតូចឱ្យទៅជាលូធំវិញ) ព្រោះបញ្ហាស្ទះលូ ឬទឹកហូរមិនទាន់នេះក៏ជាបញ្ហាមួយនាំឱ្យមានការជន់លិចផ្លូវនៅពេលមានភ្លៀងធ្លាក់រយៈពេលយូរ។ ដូច្នេះសូមរៀបចំឱ្យបានគ្រប់ទីកន្លែងទៅតាម ស្តង់ដារដើម្បីជៀសវាងពីបញ្ហាកកស្ទះប្រព័ន្ធលូបង្ហូរទឹក ដែលបង្កឱ្យ មានការជន់លិចផ្លូវ និងពិបាកធ្វើដំណើរ។

# ឯកសារយោង

# ឯកសារយោង

## លិខិតបទដ្ឋានគតិយុត្ត

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២៣ ឧសភា ២០០៨
- ច្បាប់ស្តីពីផ្លូវថ្នល់,លេខ នស\រកម\០៥១៤\០០០៨, ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៤
- អនុក្រឹត្យលេខ២២១អនក្រ.បក ស្តីពីការកំណត់ផ្ទៃអាងស្តុកទឹកបឹងត្របែកស្ថិតនៅក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ
- អនុក្រឹត្យលេខ១១៩ អនក្រប ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចុះថ្ងៃទី ១៧ មិថុនា ២០២២
- អនុក្រឹត្យស្តីពីការពិនិត្យការបំពុលទឹក,លេខ២៧ អនក្រ.បក.ចុះថ្ងៃទី៦ មេសា ឆ្នាំ១៩៩៩
- អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង លេខ៤២ អនក្រ.បក ចុះថ្ងៃទី១០ កក្កដា ឆ្នាំ២០០០
- អនុក្រឹតស្តីពីការគ្រប់គ្រងសំណល់រឹង,លេខ៣៦ អនក្រ.បក,ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩
- គោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់ទីប្រជុំជន ២០២០-២០២៣
- គោលនយោបាយស្តីពីលំនៅដ្ឋាន ថ្ងៃទី៩ ឧសភា ឆ្នាំ២០១៤ ត្រង់ទី៥ ផែនការសកម្មភាព
- យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា និតិកាលទី៧
- សេចក្តីណែនាំ លេខ០០៩/១៩ សណន.ស ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ស្តីពីការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាមឱ្យបានត្រឹមត្រូវតាមកម្មវិធីសម្អាត ដឹកជញ្ជូន និងប្រមូលសំរាម
- ផែនការណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញលេខ ០០៥/២៣ សនណអ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣

## សៀវភៅនិងឯកសារផ្សេងៗ

- ខណ្ឌចំការមន កម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌ
- ខណ្ឌចំការមន របាយការណ៍ស្តីការអនុវត្តការងាររបស់ខណ្ឌ ប្រចាំឆ្នាំ២០២៣
- ខណ្ឌចំការមន ប្លង់គោលប្រើប្រាស់ដីខណ្ឌ ចក្ខុវិស័យឆ្នាំ២០៣៥
- សៀវភៅ ការគ្រប់គ្រប់រដ្ឋបាលខណ្ឌ ឆ្នាំ២០២០
- ស្ថិតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩
- សៀវភៅនគររូបនីយកម្មវិទ្យា របស់បណ្ឌិត អ៊ុន សកក្កដា

# គេហទំព័រផ្សេងៗ

- គេហទំព័រ https://www.cpp.org.kh
- គេហទំព័រ https://www.information.gov.kh
- គេហទំព័រ https://phnompenh.gov.kh
- គេហទំព័រ https://economy.ams.com.kh
- គេហទំព័រ https://www.khsearch.com

# បញ្ជីឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១ ផែនទីភូមិសាស្ត្រ**

**ឧបសម្ព័ន្ធទី២ ការប្រព្រឹត្តទៅរបស់ខណ្ឌ**

**ឧបសម្ព័ន្ធទី៣ អនុក្រឹត្យស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**ឧបសម្ព័ន្ធទី៤ អនុក្រឹត្យស្តីពីការពិនិត្យការបំពុលទឹក**

**ឧបសម្ព័ន្ធទី៥ អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង**

**ឧបសម្ព័ន្ធទី៦ អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់ទីប្រជុំជន**

**ឧបសម្ព័ន្ធទី៧ ផែនការណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ**

**ឧបសម្ព័ន្ធទី៨ រូបភាពស្តីពីសកម្មភាពការងារផ្សេងៗ របស់រដ្ឋបាលខណ្ឌ**

# ឧបសម្ព័ន្ធទី១


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ប្លង់ព្រំប្រទល់រដ្ឋបាល ខណ្ឌចំការមន រាជធានីភ្នំពេញ


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ប្លង់គោលប្រើប្រាស់ដី ខណ្ឌចំការមន រាជធានីភ្នំពេញ ចក្ខុវិស័យឆ្នាំ២០៣៥

# ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៣ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពី**
**ការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១៣ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបង្កើត**ខណ្ឌបឹងកេងកង** នៃរាជធានីភ្នំពេញ ដោយកាត់យកសង្កាត់ចំនួន**០៧** ពីខណ្ឌចំការមន នៃរាជធានីភ្នំពេញគឺ សង្កាត់បឹងកេងកងទី១ សង្កាត់បឹងកេងកងទី២ សង្កាត់បឹងកេងកងទី៣ សង្កាត់អូឡាំពិច សង្កាត់ទំនប់ទឹក សង្កាត់ទួលស្វាយព្រៃទី១ និងសង្កាត់ទួលស្វាយព្រៃទី២។

ព្រំប្រទល់រដ្ឋបាល**ខណ្ឌបឹងកេងកង** ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានផ្ទេរទីតាំងសាលាខណ្ឌចំការមនដែលស្ថិតក្នុងសង្កាត់បឹងកេងកងទី៣ ទៅឲ្យសាលា**ខណ្ឌបឹងកេងកង**។

ទីតាំងសាលាខណ្ឌចំការមន ត្រូវស្ថិតនៅក្នុងសង្កាត់ទន្លេបាសាក់។

**មាត្រា ៣.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល**ខណ្ឌបឹងកេងកង** ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានីភ្នំពេញ គណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សាខណ្ឌចំការមន គណៈអភិបាលខណ្ឌចំការមន ក្រុមប្រឹក្សាខណ្ឌបឹងកេងកង គណៈអភិបាលខណ្ឌបឹងកេងកង និងក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៣ កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែមករា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ
រដ្ឋបាលខណ្ឌចំការមន

ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣

# រចនាសម្ព័ន្ធរដ្ឋបាលខណ្ឌចំការមន



# ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២៩ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២២/០០៥ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

កំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្តនីមួយៗ អនុលោមតាមមាត្រា១៤០ថ្មី នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រួមមានដូចខាងក្រោម៖

| | | |
|---|---|---|
| ១-រាជធានីភ្នំពេញ | មានចំនួនគណៈអភិបាល | ១១នាក់ |
| ២-ខេត្ត កណ្តាល | - ដ - | ១១នាក់ |
| ៣-ខេត្ត កំពង់ចាម | - ដ - | ១១នាក់ |
| ៤-ខេត្ត បាត់ដំបង | - ដ - | ១១នាក់ |
| ៥-ខេត្ត ព្រៃវែង | - ដ - | ១១នាក់ |
| ៦-ខេត្ត សៀមរាប | - ដ - | ១១នាក់ |
| ៧-ខេត្ត តាកែវ | - ដ - | ១១នាក់ |
| ៨-ខេត្ត ត្បូងឃ្មុំ | - ដ - | ១១នាក់ |
| ៩-ខេត្ត បន្ទាយមានជ័យ | - ដ - | ១១នាក់ |
| ១០-ខេត្ត កំពង់ស្ពឺ | - ដ - | ១១នាក់ |
| ១១-ខេត្ត កំពង់ធំ | - ដ - | ១១នាក់ |
| ១២-ខេត្ត កំពង់ឆ្នាំង | - ដ - | ១១នាក់ |
| ១៣-ខេត្ត កំពត | - ដ - | ១១នាក់ |
| ១៤-ខេត្ត ស្វាយរៀង | - ដ - | ១១នាក់ |
| ១៥-ខេត្ត ពោធិ៍សាត់ | - ដ - | ១១នាក់ |
| ១៦-ខេត្ត ក្រចេះ | - ដ - | ១១នាក់ |
| ១៧-ខេត្ត ព្រះសីហនុ | - ដ - | ១១នាក់ |
| ១៨-ខេត្ត ព្រះវិហារ | - ដ - | ១១នាក់ |
| ១៩-ខេត្ត រតនគិរី | - ដ - | ១១នាក់ |
| ២០-ខេត្ត កោះកុង | - ដ - | ១១នាក់ |
| ២១-ខេត្ត ស្ទឹងត្រែង | - ដ - | ១១នាក់ |
| ២២-ខេត្ត ឧត្តរមានជ័យ | - ដ - | ១១នាក់ |
| ២៣-ខេត្ត មណ្ឌលគិរី | - ដ - | ១១នាក់ |
| ២៤-ខេត្ត កែប | - ដ - | ១១នាក់ |
| ២៥-ខេត្ត ប៉ៃលិន | - ដ - | ១១នាក់ |

**មាត្រា ២.-**

កំណត់ចំនួនគណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌនីមួយៗ អនុលោម តាមមាត្រា ១៤០ថ្មី នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រួមមានដូច ខាងក្រោម៖

**១-រាជធានីភ្នំពេញ**

| | | |
|---|---|---|
| ១-ខណ្ឌ ចំការមន | មានចំនួនគណៈអភិបាល | ៧នាក់ |
| ២-ខណ្ឌ ដូនពេញ | - ដ - | ៧នាក់ |
| ៣-ខណ្ឌ ៧មករា | - ដ - | ៧នាក់ |
| ៤-ខណ្ឌ ទួលគោក | - ដ - | ៧នាក់ |
| ៥-ខណ្ឌ ដង្កោ | - ដ - | ៧នាក់ |
| ៦-ខណ្ឌ មានជ័យ | - ដ - | ៧នាក់ |
| ៧-ខណ្ឌ ឫស្សីកែវ | - ដ - | ៧នាក់ |
| ៨-ខណ្ឌ សែនសុខ | - ដ - | ៧នាក់ |
| ៩-ខណ្ឌ ពោធិ៍សែនជ័យ | - ដ - | ៧នាក់ |
| ១០-ខណ្ឌ ច្បារអំពៅ | - ដ - | ៧នាក់ |
| ១១-ខណ្ឌ ជ្រោយចង្វារ | - ដ - | ៧នាក់ |
| ១២-ខណ្ឌ ព្រែកព្នៅ | - ដ - | ៧នាក់ |
| ១៣-ខណ្ឌ បឹងកេងកង | - ដ - | ៧នាក់ |
| ១៤-ខណ្ឌ កំបូល | - ដ - | ៧នាក់ |

**២-ខេត្តកំពង់ចាម**

| | | |
|---|---|---|
| ១៥-ស្រុក បាធាយ | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១៦-ស្រុក ចំការលើ | - ដ - | ៧នាក់ |
| ១៧-ស្រុក ជើងព្រៃ | - ដ - | ៧នាក់ |
| ១៨-ក្រុង កំពង់ចាម | - ដ - | ៧នាក់ |
| ១៩-ស្រុក កំពង់សៀម | - ដ - | ៧នាក់ |
| ២០-ស្រុក កងមាស | - ដ - | ៧នាក់ |
| ២១-ស្រុក កោះសូទិន | - ដ - | ៧នាក់ |
| ២២-ស្រុក ព្រៃឈរ | - ដ - | ៧នាក់ |
| ២៣-ស្រុក ស្រីសន្ធរ | - ដ - | ៧នាក់ |
| ២៤-ស្រុក ស្ទឹងត្រង់ | - ដ - | ៧នាក់ |

## ៣-ខេត្តកណ្តាល

| | | |
|---|---|---|
| ២៥-ស្រុក អង្គស្នួល | មានចំនួនគណៈអភិបាល | ៧នាក់ |
| ២៦-ស្រុក ខ្សាច់កណ្ដាល | - ដ - | ៧នាក់ |
| ២៧-ស្រុក កណ្ដាលស្ទឹង | - ដ - | ៧នាក់ |
| ២៨-ស្រុក កោះធំ | - ដ - | ៧នាក់ |
| ២៩-ស្រុក លើកដែក | - ដ - | ៧នាក់ |
| ៣០-ស្រុក ល្វាឯម | - ដ - | ៧នាក់ |
| ៣១-ស្រុក មុខកំពូល | - ដ - | ៧នាក់ |
| ៣២-ស្រុក ពញាឮ | - ដ - | ៧នាក់ |
| ៣៣-ស្រុក ស្អាង | - ដ - | ៧នាក់ |
| ៣៤-ស្រុក កៀនស្វាយ | - ដ - | ៧នាក់ |
| ៣៥-ក្រុង តាខ្មៅ | - ដ - | ៧នាក់ |

## ៤-ខេត្តបាត់ដំបង

| | | |
|---|---|---|
| ៣៦-ស្រុក បាណន់ | មានចំនួនគណៈអភិបាល | ៧នាក់ |
| ៣៧-ស្រុក ថ្មគោល | - ដ - | ៧នាក់ |
| ៣៨-ស្រុក បវេល | - ដ - | ៧នាក់ |
| ៣៩-ស្រុក ឯកភ្នំ | - ដ - | ៧នាក់ |
| ៤០-ស្រុក មោងឫស្សី | - ដ - | ៧នាក់ |
| ៤១-ស្រុក រុក្ខគិរី | - ដ - | ៧នាក់ |
| ៤២-ស្រុក រតនមណ្ឌល | - ដ - | ៧នាក់ |
| ៤៣-ស្រុក សង្កែ | - ដ - | ៧នាក់ |
| ៤៤-ស្រុក សំឡូត | - ដ - | ៧នាក់ |
| ៤៥-ស្រុក សំពៅលូន | - ដ - | ៧នាក់ |
| ៤៦-ស្រុក កំរៀង | - ដ - | ៧នាក់ |
| ៤៧-ស្រុក គាស់ក្រឡ | - ដ - | ៧នាក់ |
| ៤៨-ស្រុក ភ្នំព្រឹក | - ដ - | ៧នាក់ |
| ៤៩-ក្រុង បាត់ដំបង | - ដ - | ៧នាក់ |

## ៥-ខេត្តព្រៃវែង

| | | |
|---|---|---|
| ៥០-ស្រុក កញ្ជ្រៀច | មានចំនួនគណៈអភិបាល | ៧នាក់ |
| ៥១-ស្រុក ពាមជរ | - ដ - | ៧នាក់ |
| ៥២-ស្រុក ពាមរក៍ | - ដ - | ៧នាក់ |
| ៥៣-ស្រុក ព្រះស្ដេច | - ដ - | ៧នាក់ |
| ៥៤-ស្រុក កំចាយមារ | - ដ - | ៧នាក់ |
| ៥៥-ស្រុក ស៊ីធរកណ្ដាល | - ដ - | ៧នាក់ |
| ៥៦-ស្រុក បាភ្នំ | - ដ - | ៧នាក់ |
| ៥៧-ស្រុក ស្វាយអន្ទរ | - ដ - | ៧នាក់ |
| ៥៨-ស្រុក ពោធិ៍រៀង | - ដ - | ៧នាក់ |
| ៥៩-ស្រុក មេសាង | - ដ - | ៧នាក់ |
| ៦០-ស្រុក កំពង់ត្របែក | - ដ - | ៧នាក់ |
| ៦១-ស្រុក ពារាំង | - ដ - | ៧នាក់ |
| ៦២-ក្រុង ព្រៃវែង | - ដ - | ៧នាក់ |

## ៦-ខេត្តសៀមរាប

| | | |
|---|---|---|
| ៦៣-ស្រុក វ៉ារិន | មានចំនួនគណៈអភិបាល | ៧នាក់ |
| ៦៤-ស្រុក ស្វាយលើ | - ដ - | ៧នាក់ |
| ៦៥-ស្រុក ស្រីស្នំ | - ដ - | ៧នាក់ |
| ៦៦-ស្រុក សូទ្រនិគម | - ដ - | ៧នាក់ |
| ៦៧-ស្រុក ប្រាសាទបាគង | - ដ - | ៧នាក់ |
| ៦៨-ស្រុក ពួក | - ដ - | ៧នាក់ |
| ៦៩-ស្រុក ក្រឡាញ់ | - ដ - | ៧នាក់ |
| ៧០-ស្រុក ជីក្រែង | - ដ - | ៧នាក់ |
| ៧១-ស្រុក បន្ទាយស្រី | - ដ - | ៧នាក់ |
| ៧២-ស្រុក អង្គរជុំ | - ដ - | ៧នាក់ |
| ៧៣-ក្រុង សៀមរាប | - ដ - | ៧នាក់ |
| ៧៤-ស្រុក អង្គរធំ | - ដ - | ៧នាក់ |

## ៧-ខេត្តតាកែវ

| | | |
|---|---|---|
| ៧៥-ស្រុក ទ្រាំង | មានចំនួនគណៈអភិបាល | ៧នាក់ |
| ៧៦-ស្រុក ត្រាំកក់ | - ដ - | ៧នាក់ |
| ៧៧-ស្រុក សំរោង | - ដ - | ៧នាក់ |
| ៧៨-ស្រុក ព្រៃកប្បាស | - ដ - | ៧នាក់ |
| ៧៩-ស្រុក កោះអណ្តែត | - ដ - | ៧នាក់ |
| ៨០-ស្រុក គិរីវង់ | - ដ - | ៧នាក់ |
| ៨១-ស្រុក បូរីជលសារ | - ដ - | ៧នាក់ |
| ៨២-ស្រុក បាទី | - ដ - | ៧នាក់ |
| ៨៣-ស្រុក អង្គរបូរី | - ដ - | ៧នាក់ |
| ៨៤-ក្រុង ដូនកែវ | - ដ - | ៧នាក់ |

## ៨-ខេត្តបន្ទាយមានជ័យ

| | | |
|---|---|---|
| ៨៥-ស្រុក មង្គលបូរី | មានចំនួនគណៈអភិបាល | ៧នាក់ |
| ៨៦-ស្រុក ភ្នំស្រុក | - ដ - | ៧នាក់ |
| ៨៧-ស្រុក ព្រះនេត្រព្រះ | - ដ - | ៧នាក់ |
| ៨៨-ស្រុក អូរជ្រៅ | - ដ - | ៧នាក់ |
| ៨៩-ស្រុក ថ្មពួក | - ដ - | ៧នាក់ |
| ៩០-ស្រុក ស្វាយចេក | - ដ - | ៧នាក់ |
| ៩១-ស្រុក ម៉ាឡៃ | - ដ - | ៧នាក់ |
| ៩២-ក្រុង សិរីសោភ័ណ | - ដ - | ៧នាក់ |
| ៩៣-ក្រុង ប៉ោយប៉ែត | - ដ - | ៧នាក់ |

## ៩-ខេត្តកំពង់ស្ពឺ

| | | |
|---|---|---|
| ៩៤-ស្រុក សំរោងទង | មានចំនួនគណៈអភិបាល | ៧នាក់ |
| ៩៥-ស្រុក បសេដ្ឋ | - ដ - | ៧នាក់ |
| ៩៦-ស្រុក គងពិសី | - ដ - | ៧នាក់ |
| ៩៧-ស្រុក ឧដុង្គ | - ដ - | ៧នាក់ |
| ៩៨-ស្រុក ភ្នំស្រួច | - ដ - | ៧នាក់ |
| ៩៩-ស្រុក ថ្ពង | - ដ - | ៧នាក់ |
| ១០០-ស្រុក ឱរ៉ាល់ | - ដ - | ៧នាក់ |
| ១០១-ក្រុង ច្បារមន | - ដ - | ៧នាក់ |

## ១០-ខេត្តកំពង់ធំ

| | | |
|---|---|---|
| ១០២-ស្រុក បារាយណ៍ | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១០៣-ស្រុក កំពង់ស្វាយ | - ដ - | ៧នាក់ |
| ១០៤-ស្រុក ប្រាសាទបល្ល័ង្គ | - ដ - | ៧នាក់ |
| ១០៥-ស្រុក ប្រាសាទសំបូរ | - ដ - | ៧នាក់ |
| ១០៦-ស្រុក សណ្តាន់ | - ដ - | ៧នាក់ |
| ១០៧-ស្រុក សន្ទុក | - ដ - | ៧នាក់ |
| ១០៨-ស្រុក ស្ទោង | - ដ - | ៧នាក់ |
| ១០៩-ស្រុក តាំងគោក | - ដ - | ៧នាក់ |
| ១១០-ក្រុង ស្ទឹងសែន | - ដ - | ៧នាក់ |

## ១១-ខេត្តកំពង់ឆ្នាំង

| | | |
|---|---|---|
| ១១១-ស្រុក ទឹកផុស | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១១២-ស្រុក កំពង់ត្រឡាច | - ដ - | ៧នាក់ |
| ១១៣-ស្រុក ជលគិរី | - ដ - | ៧នាក់ |
| ១១៤-ស្រុក បរិបូណ៌ | - ដ - | ៧នាក់ |
| ១១៥-ស្រុក សាមគ្គីមានជ័យ | - ដ - | ៧នាក់ |
| ១១៦-ស្រុក កំពង់លែង | - ដ - | ៧នាក់ |
| ១១៧-ស្រុក រលាប្អៀរ | - ដ - | ៧នាក់ |
| ១១៨-ក្រុង កំពង់ឆ្នាំង | - ដ - | ៧នាក់ |

## ១២-ខេត្តកំពត

| | | |
|---|---|---|
| ១១៩-ស្រុក ឈូក | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១២០-ស្រុក ទឹកឈូ | - ដ - | ៧នាក់ |
| ១២១-ស្រុក បន្ទាយមាស | - ដ - | ៧នាក់ |
| ១២២-ស្រុក អង្គរជ័យ | - ដ - | ៧នាក់ |
| ១២៣-ស្រុក ដងទង់ | - ដ - | ៧នាក់ |
| ១២៤-ស្រុក កំពង់ត្រាច | - ដ - | ៧នាក់ |

| | | |
|---|---|---|
| ១២៥-ស្រុក ជុំគិរី | - ដ - | ៧នាក់ |
| ១២៦-ក្រុង កំពត | - ដ - | ៧នាក់ |
| ១២៧-ក្រុង បូកគោ | - ដ - | ៧នាក់ |

## ១៣-ខេត្តស្វាយរៀង

| | | |
|---|---|---|
| ១២៨-ស្រុក ចន្ទ្រា | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១២៩-ស្រុក កំពង់រោទិ៍ | - ដ - | ៧នាក់ |
| ១៣០-ស្រុក រំដួល | - ដ - | ៧នាក់ |
| ១៣១-ស្រុក រមាសហែក | - ដ - | ៧នាក់ |
| ១៣២-ស្រុក ស្វាយជ្រំ | - ដ - | ៧នាក់ |
| ១៣៣-ស្រុក ស្វាយទាប | - ដ - | ៧នាក់ |
| ១៣៤-ក្រុង ស្វាយរៀង | - ដ - | ៧នាក់ |
| ១៣៥-ក្រុង បាវិត | - ដ - | ៧នាក់ |

## ១៤-ខេត្តពោធិ៍សាត់

| | | |
|---|---|---|
| ១៣៦-ស្រុក ក្រគរ | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១៣៧-ស្រុក កណ្ដៀង | - ដ - | ៧នាក់ |
| ១៣៨-ស្រុក បាកាន | - ដ - | ៧នាក់ |
| ១៣៩- ក្រុង ពោធិ៍សាត់ | - ដ - | ៧នាក់ |
| ១៤០-ស្រុក ភ្នំក្រវាញ | - ដ - | ៧នាក់ |
| ១៤១-ស្រុក តាលោសែនជ័យ | - ដ - | ៧នាក់ |
| ១៤២-ស្រុក វាលវែង | - ដ - | ៧នាក់ |

## ១៥-ខេត្តក្រចេះ

| | | |
|---|---|---|
| ១៤៣-ស្រុក ឆ្លូង | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១៤៤-ស្រុក ស្នួល | - ដ - | ៧នាក់ |
| ១៤៥-ស្រុក សំបូរ | - ដ - | ៧នាក់ |
| ១៤៦-ស្រុក ព្រែកប្រសព្វ | - ដ - | ៧នាក់ |
| ១៤៧-ស្រុក ចិត្របុរី | - ដ - | ៧នាក់ |
| ១៤៨-ក្រុង ក្រចេះ | - ដ - | ៧នាក់ |

## ១៦-ខេត្តព្រះសីហនុ

| | | |
|---|---|---|
| ១៤៩-ស្រុក ព្រៃនប់ | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១៥០-ក្រុង ព្រះសីហនុ | - ដ - | ៧នាក់ |
| ១៥១-ស្រុក ស្ទឹងហាវ | - ដ - | ៧នាក់ |
| ១៥២-ស្រុក កំពង់សីលា | - ដ - | ៧នាក់ |
| ១៥៣-ក្រុង កោះរ៉ុង | - ដ - | ៧នាក់ |

## ១៧-ខេត្តព្រះវិហារ

| | | |
|---|---|---|
| ១៥៤-ស្រុក ជាំក្សាន្ត | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១៥៥-ស្រុក គូលែន | - ដ - | ៧នាក់ |
| ១៥៦-ស្រុក រវៀង | - ដ - | ៧នាក់ |
| ១៥៧-ស្រុក ជ័យសែន | - ដ - | ៧នាក់ |
| ១៥៨-ស្រុក ឆែប | - ដ - | ៧នាក់ |
| ១៥៩-ស្រុក សង្គមថ្មី | - ដ - | ៧នាក់ |
| ១៦០-ស្រុក ត្បែងមានជ័យ | - ដ - | ៧នាក់ |
| ១៦១-ក្រុង ព្រះវិហារ | - ដ - | ៧នាក់ |

## ១៨-ខេត្តរតនគិរី

| | | |
|---|---|---|
| ១៦២-ក្រុង បានលុង | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១៦៣-ស្រុក បរកែវ | - ដ - | ៧នាក់ |
| ១៦៤-ស្រុក កូនមុំ | - ដ - | ៧នាក់ |
| ១៦៥-ស្រុក លំផាត់ | - ដ - | ៧នាក់ |
| ១៦៦-ស្រុក អូរជុំ | - ដ - | ៧នាក់ |
| ១៦៧-ស្រុក អូរយ៉ាដាវ | - ដ - | ៧នាក់ |
| ១៦៨-ស្រុក តាវែង | - ដ - | ៧នាក់ |
| ១៦៩-ស្រុក វើនសៃ | - ដ - | ៧នាក់ |
| ១៧០-ស្រុក អណ្ដូងមាស | - ដ - | ៧នាក់ |

## ១៩-ខេត្តកោះកុង

| | | |
|---|---|---|
| ១៧១-ក្រុង ខេមរភូមិន្ទ | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១៧២-ស្រុក ស្រែអំបិល | - ដ - | ៧នាក់ |

| | | |
|---|---|---|
| ១៧៣-ស្រុក កោះកុង | - ដ - | ៧នាក់ |
| ១៧៤-ស្រុក មណ្ឌលសីមា | - ដ - | ៧នាក់ |
| ១៧៥-ស្រុក បូទុមសាគរ | - ដ - | ៧នាក់ |
| ១៧៦-ស្រុក ថ្មបាំង | - ដ - | ៧នាក់ |
| ១៧៧-ស្រុក គិរីសាគរ | - ដ - | ៧នាក់ |

## ២០-ខេត្តស្ទឹងត្រែង

| | | |
|---|---|---|
| ១៧៨-ក្រុង ស្ទឹងត្រែង | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១៧៩-ស្រុក ថាឡាបរិវ៉ាត់ | - ដ - | ៧នាក់ |
| ១៨០-ស្រុក សៀមប៉ាង | - ដ - | ៧នាក់ |
| ១៨១-ស្រុក សៀមបូក | - ដ - | ៧នាក់ |
| ១៨២-ស្រុក បុរីអូរស្វាយសែនជ័យ | - ដ - | ៧នាក់ |
| ១៨៣-ស្រុក សេសាន | - ដ - | ៧នាក់ |

## ២១-ខេត្តឧត្តរមានជ័យ

| | | |
|---|---|---|
| ១៨៤-ស្រុក អន្លង់វែង | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១៨៥-ស្រុក បន្ទាយអំពិល | - ដ - | ៧នាក់ |
| ១៨៦-ស្រុក ត្រពាំងប្រាសាទ | - ដ - | ៧នាក់ |
| ១៨៧-ក្រុង សំរោង | - ដ - | ៧នាក់ |
| ១៨៨-ស្រុក ចុងកាល់ | - ដ - | ៧នាក់ |

## ២២-ខេត្តមណ្ឌលគិរី

| | | |
|---|---|---|
| ១៨៩-ស្រុក កែវសីមា | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១៩០-ស្រុក កោះញែក | - ដ - | ៧នាក់ |
| ១៩១-ស្រុក អូររាំង | - ដ - | ៧នាក់ |
| ១៩២-ស្រុក ពេជ្រាដា | - ដ - | ៧នាក់ |
| ១៩៣-ក្រុង សែនមនោរម្យ | - ដ - | ៧នាក់ |

## ២៣-ខេត្តកែប

| | | |
|---|---|---|
| ១៩៤-ស្រុក ដំណាក់ចង្អើរ | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១៩៥-ក្រុង កែប | - ដ - | ៧នាក់ |

| | | |
|---|---|---|
| ១៧៣-ស្រុក កោះកុង | - ដ - | ៧នាក់ |
| ១៧៤-ស្រុក មណ្ឌលសីមា | - ដ - | ៧នាក់ |
| ១៧៥-ស្រុក បូទុមសាគរ | - ដ - | ៧នាក់ |
| ១៧៦-ស្រុក ថ្មបាំង | - ដ - | ៧នាក់ |
| ១៧៧-ស្រុក គិរីសាគរ | - ដ - | ៧នាក់ |

## ២០-ខេត្តស្ទឹងត្រែង

| | | |
|---|---|---|
| ១៧៨-ក្រុង ស្ទឹងត្រែង | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១៧៩-ស្រុក ថាឡាបរិវ៉ាត់ | - ដ - | ៧នាក់ |
| ១៨០-ស្រុក សៀមប៉ាង | - ដ - | ៧នាក់ |
| ១៨១-ស្រុក សៀមបូក | - ដ - | ៧នាក់ |
| ១៨២-ស្រុក បុរីអូរស្វាយសែនជ័យ | - ដ - | ៧នាក់ |
| ១៨៣-ស្រុក សេសាន | - ដ - | ៧នាក់ |

## ២១-ខេត្តឧត្តរមានជ័យ

| | | |
|---|---|---|
| ១៨៤-ស្រុក អន្លង់វែង | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១៨៥-ស្រុក បន្ទាយអំពិល | - ដ - | ៧នាក់ |
| ១៨៦-ស្រុក ត្រពាំងប្រាសាទ | - ដ - | ៧នាក់ |
| ១៨៧-ក្រុង សំរោង | - ដ - | ៧នាក់ |
| ១៨៨-ស្រុក ចុងកាល់ | - ដ - | ៧នាក់ |

## ២២-ខេត្តមណ្ឌលគិរី

| | | |
|---|---|---|
| ១៨៩-ស្រុក កែវសីមា | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១៩០-ស្រុក កោះញែក | - ដ - | ៧នាក់ |
| ១៩១-ស្រុក អូររាំង | - ដ - | ៧នាក់ |
| ១៩២-ស្រុក ពេជ្រាដា | - ដ - | ៧នាក់ |
| ១៩៣-ក្រុង សែនមនោរម្យ | - ដ - | ៧នាក់ |

## ២៣-ខេត្តកែប

| | | |
|---|---|---|
| ១៩៤-ស្រុក ដំណាក់ចង្អើរ | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១៩៥-ក្រុង កែប | - ដ - | ៧នាក់ |

## ២៤-ខេត្តប៉ៃលិន

| | | |
|---|---|---|
| ១៩៦-ស្រុក សាលាក្រៅ | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១៩៧-ក្រុង ប៉ៃលិន | - ដ - | ៧នាក់ |

## ២៥-ខេត្តត្បូងឃ្មុំ

| | | |
|---|---|---|
| ១៩៨-ស្រុក តំបែរ | មានចំនួនគណៈអភិបាល | ៧នាក់ |
| ១៩៩-ស្រុក ក្រូចឆ្មារ | - ដ - | ៧នាក់ |
| ២០០-ស្រុក មេមត់ | - ដ - | ៧នាក់ |
| ២០១-ស្រុក អូររាំងឪ | - ដ - | ៧នាក់ |
| ២០២-ស្រុក ពញាក្រែក | - ដ - | ៧នាក់ |
| ២០៣-ស្រុក ត្បូងឃ្មុំ | - ដ - | ៧នាក់ |
| ២០៤-ក្រុង សួង | - ដ - | ៧នាក់។ |

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១២កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៤

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលទឹក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាល**

**លេខ** : ២៧ អ.ន.ក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការត្រួតពិនិត្យការបំពុលទឹក

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ និងការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៩៩ ។

## សំរេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅ កំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយដែលបង្កឱ្យមានការបំពុលទឹកនៅតាមតំបន់សាធារណៈ ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក-"**តំបន់ទឹកសាធារណៈ**" គឺសំដៅទៅលើតំបន់ទឹកសំរាប់ប្រើប្រាស់ជាសាធារណៈ ដូចជា : ទន្លេ ស្ទឹង ជ្រោះ អូរ ព្រែក បឹង ស្រះ អណ្តូង ត្រពាំង ថ្លុក សមុទ្រ ពាម ដោយរាប់បញ្ចូលទាំងប្រព័ន្ធប្រឡាយធារាសាស្ត្រ និងផ្លូវទឹកដទៃទៀតដែលសំរាប់ប្រើប្រាស់ជាសាធារណៈ និងទឹកក្រោមដី ។

ខ-"**ប្រភពបំពុល**" គឺសំដៅទៅលើទីតាំងអាគារទាំងឡាយណា រួមទាំងលំនៅស្ថាន និងអាគាររដ្ឋបាលសាធារណៈ ទីបរិវេណ មធ្យោបាយដឹកជញ្ជូន និងតំបន់អាជីវកម្ម ឬសេវាកម្ម ដែលបញ្ចេញសំណល់រាវ សារធាតុពុល ឬសារធាតុដែលបង្កអោយមានគ្រោះថ្នាក់ ដោយផ្ទាល់ក្តី ឬមិនផ្ទាល់ក្តី ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ

គ-"**សំណល់រាវ**" គឺសំដៅទៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបានធ្វើប្រព្រឹត្តកម្មក្តី ។

ឃ-"**ទឹកលូ**" គឺសំដៅទៅលើទឹកកខ្វក់ ដែលបញ្ចេញពីលំនៅស្ថាន និងអាគារសាធារណៈ ។

ង-"**សំណល់រឹង**" គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ហើយត្រូវបានបញ្ចេញចោលពីប្រភពបំពុល ។

ច-"**សំរាម**" គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ ហើយត្រូវបានបញ្ចេញចោលពីលំនៅស្ថាន និងអាគារសាធារណៈ ។

ឆ-"**សារធាតុបំពុល**" គឺសំដៅទៅលើសារធាតុរឹង រាវ ឬឧស្ម័ន ឬសំណល់គ្រប់ប្រភេទដែលធ្វើឱ្យមានការប្រែប្រួលនូវធាតុផ្សំ ឬលក្ខណៈរបស់ទឹក ដូចជា ធ្វើឱ្យប្រែប្រួលនូវ លក្ខណៈរូប លក្ខណៈគីមី ឬលក្ខណៈជីវសាស្ត្ររបស់ទឹក នៅពេលបញ្ចេញ ឬចាក់វាចោលចូលទៅក្នុងទឹកដោយចេតនាក្តី ឬអចេតនាក្តី ។

ជ-"**បរិមាណសារធាតុបំពុល**" គឺសំដៅទៅលើបន្ទុក ឬចំណុះសារធាតុបំពុល រួមទាំងកំដៅដែលមាននៅក្នុងសំណល់រាវ ដែលត្រូវបានបញ្ចេញចោលពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹក សាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ឈ-"**សារធាតុប្រកបដោយគ្រោះថ្នាក់**" គឺសំដៅទៅសារធាតុ ដែលបណ្តាលអោយមានគ្រោះថ្នាក់ទៅដល់សរីរាង្គមានជីវិត ឬធ្វើអោយខូច ឬបាក់បែកវត្ថុសំភារៈ អាគារ ឬបណ្តាលអោយប៉ះពាល់ ឬមហន្តរាយដល់បរិស្ថាន ។ ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ២
## បញ្ញត្តិលើការបញ្ចេញសំណល់
## និងសារធាតុប្រកបដោយគ្រោះថ្នាក់

**មាត្រា ៤.-**

ក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវពីប្រភពបំពុលទាំងឡាយ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

**មាត្រា ៥.-**

ក្នុងករណីចាំបាច់ និងតំរូវការទៅតាមតំបន់នីមួយៗ ក្នុងការការពារសុខភាពមនុស្ស និងការអភិរក្សជីវចំរុះ ក្រសួងបរិស្ថាន ត្រូវរៀបចំក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក សំរាប់អនុវត្តលើប្រភពបំពុល ដែលតាំងនៅជុំវិញតំបន់ទឹកសាធារណៈនោះ ។

ក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ មាត្រា ៥ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៦.-**

ហាមឃាត់ជាដាច់ខាតនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុលណាមួយដែលមិនអនុវត្តតាមក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា៥ នៃអនុក្រឹត្យនេះ ។

**មាត្រា ៧.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំក៏រិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុលនៅក្នុងសំណល់រាវ ដែលអាចអនុញ្ញាតឱ្យបញ្ចេញពីប្រភពបំពុលនានា ចូលទៅក្នុងតំបន់ទឹកសាធារណៈដែលត្រូវការពារ ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស និង ការអភិរក្សជីវៈចំរុះ ។

ក៏រិតស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា៧ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៨.-**

ហាមឃាត់ជាដាច់ខាតនូវការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ទៅក្នុងតំបន់ទឹក

សាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ហាមឃាត់ជាដាច់ខាតនូវការទុកដាក់ ឬការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលនាំឱ្យមានការបំពុលទឹកតំបន់ទឹកសាធារណៈ ។

**មាត្រា ៩.-**

ហាមឃាត់ជាដាច់ខាតនូវការបង្ហូរទឹកលូចេញពីលំនៅស្ថាន ឬពីអាគារសាធារណៈ ចូលទៅក្នុងតំបន់ទឹកសាធារណៈ ដោយពុំឆ្លងកាត់ប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធច្រោះសំអាតនានា ។

## ជំពូកទី ៣

## ការសុំអនុញ្ញាតបញ្ចេញសំណល់រាវ

**មាត្រា ១០.-**

ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពីប្រភពបំពុលទៅកន្លែងដទៃ ក្នុងគោលបំណងណាមួយ ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន និងត្រូវធ្វើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ១១.-**

ប្រភេទនៃប្រភពបំពុល ដែលតំរូវអោយសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ ដូចមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៣ នៃអនុក្រឹត្យនេះ ហើយដែលចែកចេញជាពីរប្រភេទ ដូចតទៅ :

ក-ប្រភពបំពុលប្រភេទថ្នាក់ទី១ តំរូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណសំណល់រាវរបស់ប្រភពបំពុលនោះមានចំនួនច្រើនជាង ១០ ម៉ែត្រគូបក្នុងមួយថ្ងៃដោយពុំគិតបញ្ចូលនូវបរិមាណទឹកដែលប្រើប្រាស់សំរាប់ប្រព័ន្ធត្រជាក់គ្រឿងចក្រ ។

ខ-ប្រភពបំពុលប្រភេទថ្នាក់ទី២ ចាំបាច់តំរូវអោយមានការសុំការអនុញ្ញាតពីក្រសួងបរិស្ថាន ។

**មាត្រា ១២.-**

ការសុំអនុញ្ញាតលើការបញ្ចេញចោល ឬការដឹកសំណល់រាវចេញពីប្រភពបំពុលទៅកន្លែងដទៃដូចមានចែងក្នុងមាត្រា១០ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុល ទាំងគំរោងថ្មី និងទាំងគំរោងកំពុងដំណើរការ លើកលែងតែគំរោងប្រភពបំពុលថ្មី ដែលរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គំរោងនោះត្រូវបានអនុម័ត នឹងត្រូវបានរួចផុតពីការតំរូវឱ្យសុំការអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ ។

**មាត្រា ១៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះដែលមានបំណងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកាន់កន្លែងដទៃ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន :

-អោយបានមុន ៤០ថ្ងៃសំរាប់គំរោងនៅភ្នំពេញ និង ៦០ថ្ងៃ សំរាប់គំរោងនៅតាមខេត្ត ក្រុងនៃការចាប់ផ្តើម

ដំណើរការ សំរាប់ប្រភពបំពុលដែលជាគំរោងថ្មី ។

-អោយបានក្នុងរយៈពេល ៣០ថ្ងៃ សំរាប់ប្រភពបំពុលនៅភ្នំពេញ និង ៥០ថ្ងៃសំរាប់ប្រភពបំពុលនៅតាមខេត្ត ក្រុង ក្រោយពេលទទួលបានការណែនាំពីក្រសួងបរិស្ថាន សំរាប់ប្រភពបំពុលដែលកំពុងដំណើរការ ។

**មាត្រា ១៤.-**

លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុលទៅកាន់កន្លែងដទៃ នឹងត្រូវបានផ្តល់ជូន ប្រសិនបើបែបបទនៃការសុំអនុញ្ញាតនោះត្រូវបានបំពេញទៅតាមគោលការណ៍ណែនាំបច្ចេកទេស ដែលកំនត់ដោយក្រសួង បរិស្ថាន ។

**មាត្រា ១៥.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដែលទទួលបានការអនុញ្ញាតពីក្រសួងបរិស្ថានអោយបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅទីដទៃ ហើយមានបំណងចង់ធ្វើការផ្លាស់ប្តូរប្រព័ន្ធបញ្ចេញសំណល់រាវរបស់ខ្លួន ត្រូវដាក់ពាក្យ សុំការអនុញ្ញាតជាថ្មី ទៅក្រសួងបរិស្ថានអោយបានមុន ៣០ថ្ងៃ នៃការចាប់ផ្តើមដំណើរការផ្លាស់ប្តូរ ។

**មាត្រា ១៦.-**

បុគ្គលដែលជួល ឬអ្នកកាន់កាប់បន្តប្រភពបំពុលពីម្ចាស់កម្មសិទ្ធិដើម ឬអ្នកទទួលខុសត្រូវដើមដែលបានទទួលការ អនុញ្ញាតពីក្រសួងបរិស្ថានឱ្យបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅទីដទៃត្រូវអនុវត្តបន្តអោយបានត្រឹមត្រូវនូវចំនុច ដែលបានកំណត់នៅក្នុងពាក្យសុំការអនុញ្ញាត ដែលម្ចាស់កម្មសិទ្ធិដើម ឬអ្នកទទួលខុសត្រូវដើម បានដាក់ជូនទៅក្រសួង បរិស្ថាន ។

ម្ចាស់កម្មសិទ្ធិថ្មី ឬអ្នកទទួលខុសត្រូវថ្មីនៃប្រភពបំពុល ត្រូវផ្តល់សេចក្តីជូនដំណឹងពីការជួល ឬការកាន់កាប់បន្ត របស់ខ្លួនទៅក្រសួងបរិស្ថាន ក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរ ក្រោយពីមានការជួល ឬកាន់កាប់បន្តនោះ ។

**មាត្រា ១៧.-**

លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុលទៅកន្លែងដទៃ ដែលបានផ្តល់ជូនទៅឱ្យ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល នឹងត្រូវបានដកហូតជាបណ្តោះអាសន្ន ឬជាស្ថាពរ បន្ទាប់ពីមានការពិគ្រោះ យោបល់ជាមុនជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ប្រសិនបើម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះប្រព្រឹត្ត ល្មើសធ្ងន់ធ្ងរ និងមាត្រាណាមួយនៃមាត្រា ១៤ មាត្រា ១៥ ឬមាត្រា ១៦ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៤
## ការត្រួតពិនិត្យប្រភពបំពុល

**មាត្រា ១៨.-**

ការត្រួតពិនិត្យនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុល ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន

**មាត្រា ១៩.-**

ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងសំណល់រាវ នៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២០.-**

ការវិភាគគំរូតាងសំណល់រាវ ដែលយកបានមកពីប្រភពបំពុលក្នុងពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ច ត្រូវធ្វើនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

**មាត្រា ២១.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវបង់ថ្លៃវិភាគសំណល់រាវរបស់ខ្លួន តាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំណត់ជាមុន ដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំនូលនេះត្រូវបញ្ចូលទៅក្នុងថវិកាជាតិ ដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

**មាត្រា ២២.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសំណល់រាវរបស់ខ្លួននៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តវិធីសាស្ត្រវិភាគដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

**មាត្រា ២៣.-**

ចំពោះប្រភពបំពុល ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវ :

ក-ទទួលខុសត្រូវក្នុងការកំណត់យកនូវវិធីសាស្ត្រធ្វើប្រព្រឹត្តកម្មសំអាតនិងបញ្ចេញសំណល់រាវរបស់ខ្លួន ដើម្បីឱ្យឆ្លើយតបទៅ និងកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះ និងកំរិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ។

ខ-មានសំភារៈ និងមធ្យោបាយគ្រប់គ្រាន់សំរាប់រារាំង ឬទប់ស្កាត់ការបំពុលតំបន់ទឹកសាធារណៈនៅពេលដែលមានគ្រោះថ្នាក់ដោយចៃដន្យបង្កឡើងពីប្រភពបំពុលរបស់ខ្លួន ។

គ-ទទួលខុសត្រូវក្នុងការដំឡើងឧបករណ៍ សំរាប់ធ្វើការវាស់នូវចរន្តហូរ កំហាប់ និងបរិមាណសារធាតុបំពុលដែលមាននៅក្នុងសំណល់រាវរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជាឯកសារ ។ លទ្ធផលនៃការវាស់ស្ទង់ ត្រូវធ្វើជារបាយការណ៍មកកាន់ក្រសួងបរិស្ថានរៀងរាល់ ៣ខែម្តង ។

**មាត្រា ២៤.-**

ក្នុងករណីដែលរកឃើញថា ការបញ្ចេញសំណល់រាវពីប្រភពបំពុលណាមួយ ពុំបានឆ្លើយតបទៅ និងកំរិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ ឬពុំឆ្លើយតបទៅ និងកំរិតស្តង់ដារបរិមាណសារធាតុ

បំពុល ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ក្រសួងបរិស្ថានត្រូវ :

ក-ចេញបញ្ជាជាលាយលក្ខណ៍អក្សរ តម្រូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ក្នុងរយៈពេលជាក់លាក់ណាមួយ ប្រសិនបើសកម្មភាពល្មើសនោះមិនទាន់បង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬប៉ះពាល់ដល់គុណភាពទឹក ។

ខ-ចេញបញ្ជាជាលាយលក្ខណ៍អក្សរ តម្រូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះផ្អាកសកម្មភាពរបស់ខ្លួនជាបណ្តោះអាសន្ន រហូតដល់បទល្មើសនោះត្រូវបានកែប្រែ ប្រសិនបើសកម្មភាពល្មើសបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬប៉ះពាល់ដល់គុណភាពទឹក ។

## ជំពូកទី ៥
## ការត្រួតពិនិត្យការបំពុលទឹក
## នៅតាមតំបន់ទឹកសាធារណៈ

**មាត្រា ២៥.-**

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹកមានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៤ នៃអនុក្រឹត្យនេះ ។

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សំរាប់ការពារសុខភាពសាធារណៈមានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៥ នៃអនុក្រឹត្យនេះ ។

**មាត្រា ២៦.-**

ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យ តាមដានជាប្រចាំពីស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ ។

**មាត្រា ២៧.-**

ក្រសួងបរិស្ថាន ត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពទឹក និងវាយតំលៃពីស្ថានភាពគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៨.-**

ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ពីស្ថានភាពគុណភាពទឹក និងស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៩.-**

ក្នុងករណីរកឃើញថា តំបន់ទឹកសាធារណៈត្រូវទទួលរងការបំពុល ដែលបង្កអោយមានការគំរាមកំហែងដល់ជីវិតមនុស្ស ឬជីវៈចំរុះ ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់នេះ និងត្រូវចាត់

វិធានការទប់ស្កាត់ការបំពុលទឹក និងស្តារនូវគុណភាពទឹកតំបន់ទឹកសាធារណៈនោះ ។

## ជំពូកទី ៦
## នីតិវិធីនៃការធ្វើអធិការកិច្ច

**មាត្រា ៣០.-**

នៅពេលចុះធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថាន ត្រូវអនុវត្តន៍តាមនីតិវិធីដូចចែងខាងក្រោម :

ក-បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកម្មរបស់ខ្លួន នៅពេលចូលក្នុងបរិវេណ ឬទីកន្លែងប្រភពបំពុលដើម្បីអធិការកិច្ច យកគំរូតាង ឬពិនិត្យកត់ត្រា

ខ-កំណត់ហេតុ និងរបាយការណ៍តំបូងនៃការត្រួតពិនិត្យ ឬការយកគំរូតាង ត្រូវធ្វើនៅទីកន្លែងដែលធ្វើអធិការកិច្ច ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់

គ-មន្ត្រីអធិការកិច្ចអាចសាកសួរ និងតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលផ្តល់នូវពត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ និងកំណត់ហេតុ សំរាប់ប្រើប្រាស់ជាវត្ថុតាង

ឃ-របាយការណ៍ ឬកំណត់ហេតុត្រូវផ្តល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល មួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន ។

**មាត្រា ៣១.-**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា ប្រភពបំពុលណាមួយបានបង្ហូរបញ្ចេញនូវសំណល់រាវ ដែលមានផ្ទុកសារធាតុពុល បង្កឱ្យមានគ្រោះថ្នាក់សុខភាពមនុស្សសត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្កអោយមានការបំពុលតំបន់ទឹកសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិចូលធ្វើអធិការកិច្ច នៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ ។

**មាត្រា ៣២.-**

ក្នុងករណីមានឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយ នៃការបំពុលទឹកនៅតំបន់ទឹកសាធារណៈ ក្រសួងបរិស្ថានត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ និងត្រូវជូនពតិមានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

**មាត្រា ៣៣.-**

ក្នុងករណីបទល្មើសជាក់ស្តែងដែលបង្កឱ្យមានការបំពុលទឹក មន្ត្រីអធិការកិច្ចក្រសួងបរិស្ថានត្រូវ :

ក-ធ្វើកំណត់ហេតុ ប្រមូល ឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ប្រសិនបើបទល្មើសនោះមិនទាន់បង្កអោយមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ ឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ ។

ខ-ប្រមូល និងឃាត់ទុកភស្តុតាងនៃបទល្មើសនោះ ដើម្បីធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿងទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កអោយមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាពមនុស្សសត្វ ឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ ។

## ជំពូកទី ៧

## ទោសបញ្ញត្តិ

**មាត្រា ៣៤.-**

ការរំលោភល្មើសទៅ និងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោស ដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៥ ជំពូកទី ៩ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ៣៥.-**

កំណត់ហេតុចោទប្រកាន់បទល្មើស ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តន៍តាមមាត្រាណាមួយនៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថានត្រូវអនុវត្តវិធានការច្បាប់ចំពោះបទល្មើសទាំងឡាយនៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣៦.-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណាដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិត និងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨
## អវសានបញ្ញត្តិ

**មាត្រា ៣៧.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៩.-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**កន្លែងទទួល**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣៨

-កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

# ឧបសម្ព័ន្ធទី៥

# អនុក្រឹត្យ

## ស្តីពី

## ការត្រួតពិនិត្យការបំពុលខ្យល់
## និងការរំខានដោយសំលេង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការត្រួតពិនិត្យការបំពុលខ្យល់

## និងការរំខានដោយសំលេង

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០០ ។

### សំរេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសំលេងក្នុងបរិយាកាសសំដៅការពារគុណភាពបរិស្ថានៈនិងសុខភាពសាធារណៈ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័ត និងអចល័តទាំងឡាយដែលបង្កអោយមានការបំពុលខ្យល់ និងការរំខានដោយសំលេងនៅក្នុងបរិយាកាស ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក- "ប្រភពបំពុល" ចែកចេញជាពីរគឺ :

- ប្រភពចល័ត : គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មាន : យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសំលេងគ្រប់ប្រភេទ
- ប្រភពអចល័ត : គឺជាប្រភពដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មាន : រោងចក្រ សហគ្រាស ឃ្លាំងស្តុកសំភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំលេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ ។

ខ- "សារធាតុបំពុល" គឺសំដៅទៅលើផ្សែង លំអងផ្សែង ធូលី ផេះ ភាគល្អិតនៃសំណល់ ឧស្ម័ន ចំហាយទឹក អ័ព្ទ ក្លិន និងសារធាតុវិទ្យុសកម្ម ។

គ- "សារធាតុឆេះ" គឺសំដៅទៅលើប្រេងឥន្ធនៈ ធ្យូងថ្ម ឧស្ម័នធម្មជាតិ អុស ធ្យូង ឬសារធាតុគីមីផ្សេងៗទៀត ដែលមានប្រតិកម្មចំហេះ

ឃ- "កំរិតកំណត់ស្តង់ដារ" គឺជាកំរិតកំណត់កំពស់អតិបរមានៃសារធាតុបំពុល ដែលអាចអនុញ្ញាតអោយមាននៅក្នុងមជ្ឈដ្ឋានបរិស្ថាន ឬដែលអាចអនុញ្ញាតអោយបញ្ចេញពីប្រភពបំពុលចូលទៅក្នុងបរិស្ថាន ។

## ជំពូកទី ២
## បញ្ញត្តិលើការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេង

**មាត្រា ៤.-**

កំរិតកំណត់ស្តង់ដារគុណភាពខ្យល់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ១ និងកំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ២ ។

**មាត្រា ៥.-**

កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញពីប្រភពអចល័តចូលទៅក្នុងបរិយាកាស មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និងកំរិតកំណត់ស្តង់ដារនៃការបញ្ចេញឧស្ម័នពីប្រភពចល័ត មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ ។

**មាត្រា ៦.-**

ក្នុងករណីចាំបាច់ កំរិតកំណត់ស្តង់ដារដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះ និងត្រូវពិនិត្យកែសំរួលឡើងវិញរាល់ប្រាំឆ្នាំម្តងតាមសំណើរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៧.-**

កំរិតកំណត់ស្តង់ដារបញ្ចេញសំលេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកំរិតកំណត់ស្តង់ដារសំលេងអតិបរមាសំរាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ ៦ និងឧបសម្ព័ន្ធ ៧ ។

**មាត្រា ៨.-**

ហាមឃាត់ដាច់ខាតនូវការបញ្ចេញសារធាតុបំពុលទៅក្នុងបរិយាកាស ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និងឧបសម្ព័ន្ធ ៤ ។

**មាត្រា ៩.-**

ហាមឃាត់ដាច់ខាតនូវការបង្កអោយមានសំលេង ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ ៦ និងឧបសម្ព័ន្ធ ៧ ។

**មាត្រា ១០.-**

ការនាំចូល និងផលិតនូវសារធាតុឆេះ ដែលមានជាតិស្ពាន់ធ័រ សំណ បង់សែន និងសារធាតុអ៊ីដ្រូកាប៊ូប្រហើរ ត្រូវឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៨ ។

**មាត្រា ១១.-**

ហាមឃាត់ដាច់ខាតការនាំចូល ប្រើប្រាស់ ផលិតយានយន្ត និងគ្រឿងយន្តគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ដែលយានយន្ត និងគ្រឿងយន្តទាំងនោះបានបញ្ចេញសារធាតុបំពុល និងសំលេងមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ និងឧបសម្ព័ន្ធ ៥ ។

**មាត្រា ១២.-**

ហាមដាច់ខាតការបង្ហូរ ឬការធ្វើអោយលេចធ្លាយសារធាតុឆេះ ប្រេងឥន្ធនៈ ធាតុវិទ្យុសកម្ម ឬសារធាតុគីមីផ្សេងៗទៀតចូលក្នុងបរិយាកាស ទឹក និងដី ។

## ជំពូកទី ៣

## ការសុំអនុញ្ញាត

**មាត្រា ១៣.-**

ការបញ្ចេញសារធាតុបំពុល និងសំលេងចូលទៅក្នុងបរិយាកាសពីប្រភពអចល័ត ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថាន និងត្រូវផ្ញើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ១៤.-**

ការសុំអនុញ្ញាតនាំចូលនូវសារធាតុឆេះ ត្រូវមានភ្ជាប់នូវលទ្ធផលវិភាគ ដែលបញ្ជាក់ពីបរិមាណជាតិពុលស្ពាន់ធ័រ សំណ បង់សែន ឬ អ៊ីដ្រូកាប៊ូប្រហើរពីប្រភពដើមនៃការនាំចូល ឬការផលិត ។

**មាត្រា ១៥.-**

ការសុំអនុញ្ញាតលើការបញ្ចេញសារធាតុបំពុល និងសំលេងដូចមានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុលទាំងត់រោងថ្មី និងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ លើកលែងតែគំរោងដែលមានរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរួចហើយ ។

**មាត្រា ១៦.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលដូចមានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន :

- អោយបានមុន ៤០ថ្ងៃ នៃការចាប់ផ្តើមដំណើរការ សំរាប់តំបន់ភ្នំពេញ
- អោយបានមុន ៦០ថ្ងៃ នៃការចាប់ផ្តើមដំណើរការ សំរាប់តំរោងនៅតាមខេត្ត-ក្រុង ។

## ជំពូកទី ៤
## ការត្រួតពិនិត្យប្រភពបំពុល

**មាត្រា ១៧.-**

ការត្រួតពិនិត្យនូវបរិមាណជាតិពុលក្នុងសារធាតុនេះ ការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេងពីប្រភពអចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

**មាត្រា ១៨.-**

ការត្រួតពិនិត្យនូវការបញ្ចេញឧស្ម័ន និងសំលេងពីប្រភពចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដោយមានកិច្ចសហការពីក្រសួងស្ថាប័នពាក់ព័ន្ធ ។ បំពេញនីតិវិធីក្នុងការត្រួតពិនិត្យនេះត្រូវកំណត់ដោយប្រកាសរួមរបស់អន្តរក្រសួង ។

**មាត្រា ១៩.-**

ក្រសួងបរិស្ថានត្រូវរៀបចំគោលការណ៍ណែនាំបច្ចេកទេស ស្តីពីវិធីសាស្ត្រត្រួតពិនិត្យប្រភពបំពុល វិធីសាស្ត្រកំណត់ទីតាំងយកគំរូតាង និងវិធីសាស្ត្រវិភាគគុណភាពខ្យល់ និងសំលេង ។

**មាត្រា ២០.-**

ក្រសួងបរិស្ថានត្រូវចុះយកគំរូតាងនៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល ។ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាងដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២១.-**

នៅពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីបរិស្ថានអាចធ្វើការវិភាគគំរូតាងនៅទីកន្លែង ឬយកមកធ្វើនៅមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

**មាត្រា ២២.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវបង់ថ្លៃសំរាប់វិភាគតាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំណត់ជាមុនដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំណូលនេះត្រូវបញ្ចូលទៅក្នុងថវិកាជាតិដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

**មាត្រា ២៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសារធាតុបំពុលរបស់ខ្លួននៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តវិធីសាស្ត្រវិភាគដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ។

**មាត្រា ២៤.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលទាំងអស់ត្រូវ :

- ទទួលខុសត្រូវក្នុងការដំឡើង ឬបំពាក់ឧបករណ៍ច្រោះសំអាតសារធាតុបំពុល និងឧបករណ៍សំរាប់កាត់បន្ថយសំលេង ដើម្បីអោយឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ
- ទទួលខុសត្រូវក្នុងការដំឡើងគ្រឿងបរិក្ខារវាស់ស្ទង់សារធាតុបំពុលដែលបញ្ចេញពីប្រភពបំពុលរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជាឯកសារ ហើយត្រូវផ្ញើរបាយការណ៍មកក្រសួងបរិស្ថានរៀងរាល់ ៣ខែម្តង
- ជ្រើសរើសអ្នកជំនាញបរិស្ថានចំនួនមួយរូប ជាអ្នកទទួលខុសត្រូវក្នុងកិច្ចសំរបសំរួលការងារបរិស្ថាន និងរៀបចំផែនការការពារបរិស្ថានក្នុងមូលដ្ឋានរបស់ខ្លួន ដែលក្រសួងបរិស្ថានអាចផ្តល់ការបណ្តុះបណ្តាលតាមសំណូមពររបស់ម្ចាស់កម្មសិទ្ធិ ។

**មាត្រា ២៥.-**

ក្នុងករណីដែលគេឃើញថាការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេងពីប្រភពណាមួយពុំបានឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងក្នុងមាត្រា ៥ មាត្រា ៧ នៃអនុក្រឹត្យនេះក្រសួងបរិស្ថានត្រូវ :

ក- ចេញបញ្ជាជាលាយល័ក្ខណ៍អក្សរតំរូវអោយម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ក្នុងរយៈពេលជាក់លាក់មួយ ។

ខ- ចេញបញ្ជាជាលាយល័ក្ខណ៍អក្សរសុំអោយម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះផ្អាកសកម្មភាពរបស់ខ្លួនជាបណ្តោះអាសន្នរហូតដល់បទល្មើសនោះត្រូវបានកែប្រែ ប្រសិនបើសកម្មភាពល្មើសបង្កអោយមានគ្រោះថ្នាក់ដល់សុខភាពសាធារណៈ ឬប៉ះពាល់ដល់គុណភាពបរិស្ថាន ។

## ជំពូកទី ៥

## ការត្រួតពិនិត្យគុណភាពខ្យល់

**មាត្រា ២៦.-**

ក្រសួងបរិស្ថានត្រូវធ្វើការត្រួតពិនិត្យតាមដានជាប្រចាំពីស្ថានភាព និងគុណភាពខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជាដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់បានទាន់ពេលវេលា ។

**មាត្រា ២៧.-**

ក្រសួងបរិស្ថានត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពខ្យល់ និងវាយតំលៃពីស្ថានភាពគុណភាពខ្យល់ ព្រមទាំងធ្វើការផ្សព្វផ្សាយជាសាធារណៈពីស្ថានភាពគុណភាព និងការបំពុលខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៨.-**

ក្នុងករណីរកឃើញថាតំបន់ណាមួយត្រូវទទួលរងការបំពុលខ្យល់ ដែលបង្កអោយមានការគំរាមកំហែងដល់អាយុជីវិតសាធារណៈ ឬគុណភាពបរិស្ថាន ក្រសួងបរិស្ថានត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់ និងត្រូវស៊ើបអង្កេតរកប្រភពដែលបង្កអោយមានការបំពុល ព្រមទាំងចាត់វិធានការទប់ស្កាត់ប្រភពបំពុលទាំងនោះ ដើម្បីស្តារនូវគុណភាពខ្យល់អោយបានប្រសើរឡើងវិញ ។

## ជំពូកទី ៦
## នីតិវិធីនៃការធ្វើអធិការកិច្ច

**មាត្រា ២៩.-**

នៅពេលចុះធ្វើអធិការកិច្ចតាមប្រភពបំពុល មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថានត្រូវអនុវត្តតាមនីតិវិធីដូចមានចែងខាងក្រោម :

ក- បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មរបស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬកន្លែងប្រភពបំពុលដើម្បីធ្វើអធិការកិច្ច យកគំរូតាង ឬពិនិត្យកំណត់ត្រា ។

ខ- កំណត់ហេតុ និងរបាយការណ៍ដំបូងនៃការត្រួតពិនិត្យ ឬយកគំរូតាង ត្រូវធ្វើនៅទីកន្លែងដែលធ្វើអធិការកិច្ចដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់ ។

គ- មន្ត្រីអធិការកិច្ចអាចសាកសួរ និងតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលផ្តល់ពត៌មាន ឬឯកសារនានាដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ និងកំណត់ហេតុសំរាប់ប្រើជាវត្ថុតាង ។

ឃ- របាយការណ៍ ឬកំណត់ហេតុត្រូវផ្តល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល មួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន ។

**មាត្រា ៣០.-**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថាប្រភពបំពុលណាមួយបានបញ្ចេញសារធាតុបំពុលខ្យល់ ឬសំលេង ឬរំញ័របង្កអោយមានគ្រោះថ្នាក់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិធ្វើអធិការកិច្ចនៅក្នុងបរិវេណប្រភពបំពុលនោះ មិនរង់ចាំតំរូវតាមអាណត្តិការវិភាគ ។

**មាត្រា ៣១.-**

ក្នុងករណីមានឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយនៃការបំពុលខ្យល់ ឬការរំខានដោយសំលេង ក្រសួងបរិស្ថានត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ និងត្រូវជូនពត៌មានទៅស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

**មាត្រា ៣២.-**

ក្នុងករណីបទល្មើសជាក់ស្តែងដែលបង្កអោយមានការបំពុលខ្យល់ ឬការរំខានដោយសំលេង មន្ត្រីអធិការកិច្ចក្រសួងបរិស្ថានត្រូវ :

ក- ធ្វើកំណត់ហេតុ ប្រមូលឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ប្រសិនបើបទល្មើសនោះមិនបង្កអោយមានការបំពុលធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន ។

ខ- ប្រមូល និងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះដើម្បីធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿងទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កអោយមានការបំពុលធ្ងន់ធ្ងរ ឬប៉ះពាល់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន ។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ៣៣.-**

ការរំលោភល្មើសទៅនឹងអនុក្រឹត្យនេះនឹងត្រូវទទួលពិន័យ និងផ្តន្ទាទោសដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៥ ជំពូកទី ៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ៣៤.-**

កំណត់ហេតុចោទប្រកាន់បទល្មើសចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តជួយ ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថានត្រូវអនុវត្តវិធានការច្បាប់ចំពោះបទល្មើសទាំងឡាយនៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣៥.-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែសខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលដល់អ្នកប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់ពីបទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៦.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៨.-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

# ឧបសម្ព័ន្ធទី៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## សម្រេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាពសាធារណៈ និងបរិស្ថាន។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី ក្រុងនិងស្រុក និងធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ
- កំណត់វិធានការចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើការញែក ការទុកដាក់ ការសម្អាត ការប្រមូល ការដឹកជញ្ជូន ការកែច្នៃ និងការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះពុំមានវិសាលភាពអនុវត្តលើការងារគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម និងសំណល់គ្រោះថ្នាក់ឡើយ។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

## ជំពូកទី២

## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥ .-**

ក្រសួងបរិស្ថាន មានតួនាទីដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ
- ផ្តល់ការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ដឹកនាំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន ឬសាធារណៈ ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារ គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការអប់រំក្នុងនិងក្រៅប្រព័ន្ធ និងការផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ (3R: Reduce, Reuse, Recycle) និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៦.-**

ក្រសួងមហាផ្ទៃ មានតួនាទីជំរុញដល់កិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- គាំទ្រនិងសហការជាមួយក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធន៍អំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងកៀរគរការគាំទ្រនានាទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ផ្តល់អន្តរាគមន៍ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៧.-**

រដ្ឋបាលខេត្តត្រូវផ្តល់ការគាំទ្រ និងការសម្របសម្រួល ព្រមទាំងជំរុញកិច្ចប្រតិបត្តិការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលអនុវត្តដោយរដ្ឋបាលក្រុង ស្រុក និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានចាំបាច់នានាសម្រាប់ណែនាំនិងជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ណែនាំដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកា

ប្រចាំឆ្នាំសម្រាប់គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ជំរុញ និងគាំទ្រការបង្កើតសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន
- កៀរគរធនធាន មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលក្រុង ស្រុកលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងជំរុញការអប់រំ និងការផ្សព្វផ្សាយតាមគ្រប់រូបភាពដល់សាធារណជនអំពីសារប្រយោជន៍នៃការញែកសំរាម សំណល់រឹងទីប្រជុំជន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន
- សម្របសម្រួលដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំនិងប្រើប្រាស់រួមគ្នានូវសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តរបស់រដ្ឋបាលក្រុង ស្រុកក្នុងការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៨.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្តលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖
- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីអនាម័យបរិស្ថានតាមរយៈការអប់រំ និងធ្វើការផ្សព្វផ្សាយអំពីការទុកដាក់ ការសម្អាត ការញែក ការកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការចូលរួមប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួមរៀបចំផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើសំណើ ឬគម្រោងសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងដំណើរការសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងសកម្មភាពកែច្នៃសំរាម សំណល់រឹងប្រជុំជន
- ជំរុញការអនុវត្តវិធានការច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងចូលរួមការអនុវត្តវិធានការពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន និង
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីស្ថានភាព និងដំណើរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកមានតួនាទីក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំ និងអនុវត្តនូវវិធានការសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមរយៈការដាក់ចេញជាដីកា ឬលិខិតបទដ្ឋាននានា
- បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធ្វើការណែនាំដល់ប្រជាពលរដ្ឋអំពីការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលបានរៀបចំនៅក្នុងមូលដ្ឋាន និង
- អប់រំនិងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកនីមួយៗអាចស្នើសុំបង្កើតអង្គភាព ឬការិយាល័យជាក់លាក់ចំណុះរដ្ឋបាលរបស់ខ្លួនសម្រាប់ទទួលខុសត្រូវលើកិច្ចការនេះ ស្របតាមគោលការណ៍ និងនីតិវិធីជាធរមាន ដើម្បីធានាដល់ប្រសិទ្ធភាព និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១១.-**

រដ្ឋបាលរាជធានីត្រូវផ្ទេរមុខងារមួយផ្នែក ឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឬ/និងរដ្ឋបាលសង្កាត់។

រដ្ឋបាលក្រុង ស្រុកអាចធ្វើប្រតិភូកម្មមុខងារមួយផ្នែកក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១២.-**

រដ្ឋបាលខណ្ឌត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួល និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងរាជធានី និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តមុខងារដែលបានទទួលក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួម និងសហការអនុវត្តនូវកម្មវិធីនានានៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូលនិងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១៣.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួលប្រតិភូកម្ម និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមការធ្វើប្រតិភូកម្ម
- ចូលរួមអប់រំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការប្រើប្រាស់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ច
- ចូលរួមផ្តល់យោបល់លើការរៀបចំកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការងារសេវាសម្អាតប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង
- ចូលរួមសហការពង្រឹងការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១៤.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចដាក់ចេញលិខិតបទដ្ឋានសម្រាប់ណែនាំដល់ការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

## ជំពូកទី៣
## ការញែក ការវេចខ្ចប់ ការទុកដាក់
## និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា១៥.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវអនុវត្តការញែក និងការវេចខ្ចប់សំរាម សំណល់រឹងដែលអាចប្រើប្រាស់ឡើងវិញ ឬកែច្នៃបានដាច់ដោយឡែកពីសំរាម សំណល់រឹងដែលត្រូវបោះចោលទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៦.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការវេចខ្ចប់ដោយថង់ ឬការដាក់នៅក្នុងធុងសំរាមផ្ទាល់ខ្លួននូវសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងលក្ខណៈហ្មត់ចត់ មិនឱ្យលេចធ្លាយ មិនឱ្យលេចជ្រាបទឹកស្អុយ ឬមិនឱ្យមានភាយក្លិនស្អុយក្នុងរយៈពេលនៃការទុកដាក់រង់ចាំការបញ្ចេញទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៧.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការរក្សាទុកនូវកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬបរិវេណនៃលំនៅឋាន អគារ ឬទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមពេលម៉ោងដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការត្រួតពិនិត្យឱ្យបានម៉ឺងម៉ាត់លើការអនុវត្តការបញ្ចេញកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជនទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈរង់ចាំការប្រមូល និងដឹកជញ្ជូនទៅតាមពេលម៉ោងដែលបានកំណត់។

**មាត្រា១៨.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំដីកា ឬលិខិតបទដ្ឋាននានា ដើម្បីណែនាំអនុវត្តការសម្អាត ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃទីប្រជុំជននីមួយៗ និងត្រូវធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងលើកកម្ពស់សោភ័ណភាព អនាម័យ និងបរិស្ថាននៅតាមទីប្រជុំជន ។

ដីកា ឬលិខិតបទដ្ឋានខាងលើនេះ ត្រូវរៀបចំឡើងដោយអនុលោមតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសជាធរមាន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវផ្សព្វផ្សាយដីកា ឬលិខិតបទដ្ឋាននានា ដូចមានចែងក្នុងកថាខ័ណ្ឌខាងលើឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាឱ្យមានការចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវ។

## ជំពូកទី៤
## វិធានការទូទៅលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា២០.-**

ត្រូវបានហាមឃាត់ដាច់ខាតនូវការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល តាមប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការទប់ស្កាត់ការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល ប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

**មាត្រា២១.-**

រូបវន្តបុគ្គល និងនីតិបុគ្គលដែលប្រើប្រាស់ទីសាធារណៈសម្រាប់ការប្រារព្ធ ឬដំណើរការកម្មវិធីរបស់ខ្លួន ត្រូវទទួលខុសត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងពិធីទៅឱ្យអ្នកផ្ដល់សេវាប្រមូលក្នុងមូលដ្ឋាន ទៅតាមតម្លៃដែលបានកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២២.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់ចែងឱ្យមានធុងសំរាមសាធារណៈ និងត្រូវរៀបចំឱ្យមានសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតពីការលក់ដូរនៅតាមដងផ្លូវ និងទីសាធារណៈ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ម្ចាស់ ឬអ្នកគ្រប់គ្រងផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាសសិប្បកម្ម មណ្ឌលកំសាន្តត្រូវរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណ សម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន។

**មាត្រា២៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកម៉ៅការការដ្ឋានវាយកម្ទេច ជួសជុល ឬសាងសង់លំនៅឋាន ឬអគារត្រូវទទួលខុសត្រូវលើសំរាម សំណល់រឹងដែលចេញពីការដ្ឋានរបស់ខ្លួន ដូចខាងក្រោម៖

- ទុកដាក់ឱ្យបានត្រឹមត្រូវ មិនបង្កការប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ និងបរិស្ថាន និង
- សម្អាត ប្រមូល និងដឹកជញ្ជូនដោយខ្លួនឯងទៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ឬប្រើប្រាស់សេវា សម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានក្នុងមូលដ្ឋាន និងត្រូវបង់ថ្លៃតាមការកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់កន្លែងសមស្របសម្រាប់ស្តុកសំរាម សំណល់រឹងទីប្រជុំជនបណ្ដោះអាសន្នតាមការចាំបាច់ ដើម្បីជានាប្រសិទ្ធភាពក្នុងការប្រមូល និងដឹកជញ្ជូន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់ពេលវេលាដែលអាចអនុញ្ញាតឱ្យបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនយកទៅដាក់នៅកន្លែងស្តុកសំរាមបណ្ដោះអាសន្ន និងត្រូវចាត់វិធានការរារាំងការយកសំរាម សំណល់រឹងទៅបញ្ចេញនៅកន្លែងស្តុកសំរាមបណ្ដោះអាសន្នខុសពេលវេលាដែលបានកំណត់។

**មាត្រា២៥.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងនានា និងបុរីលំនៅឋាន ត្រូវរៀបចំកន្លែងសមស្របសម្រាប់ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងបរិវេណគ្រប់គ្រងរបស់ខ្លួនរង់ចាំការដឹកចេញដែលមិនបង្កផលប៉ះពាល់ដល់សោភ័ណភាព សណ្ដាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងសុខភាពសាធារណៈ។

**មាត្រា២៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការបន្ទាន់ចំពោះករណីមានការកកស្ទះសំរាម សំណល់រឹងទីប្រជុំជនដែលបណ្តាលមកពីភាពអសកម្មនៃអ្នកផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនដោយប្រើប្រាស់គ្រប់មធ្យោបាយតាមដែលអាចធ្វើបានក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដើម្បីដោះស្រាយភាពកកស្ទះ។

ចំពោះការចំណាយក្នុងប្រតិបត្តិការខាងលើ គឺជាបន្ទុកផ្ទាល់របស់អ្នកផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅក្នុងទីប្រជុំជននោះ។

**ប្រការ២៧.-**

ការធ្វើអាជីវកម្មបូម ដឹកជញ្ជូន និងការបោះចោលសំណល់កក់ពីអាងស៊ិបទិក ត្រូវមានការអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌបន្ទាប់ពីបានទទួលយោបល់បច្ចេកទេសពីមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា២៨.-**

ក្រសួងបរិស្ថានត្រូវផ្តល់ការណែនាំអំពីបច្ចេកទេសគ្រប់គ្រងដោយឡែក សម្រាប់ប្រភេទសំណល់គ្រោះថ្នាក់ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

បញ្ជីសំណល់គ្រោះថ្នាក់ដែលបង្កើតតាមលំនៅឋាន ស្ថាប័នឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍មានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា២៩.-**

សំណល់រឹងឧស្សាហកម្ម និងសំណល់គ្រោះថ្នាក់ដែលបង្កើតចេញពីសកម្មភាពផលិតកម្មនៃរោងចក្រ អាជីវកម្មរ៉ែ និងពីប្រភពដទៃទៀតក្រៅពីទីតាំង ឬប្រភពដែលមានចែងក្នុងមាត្រា២៨នៃអនុក្រឹត្យនេះ ត្រូវគ្រប់គ្រងដោយក្រសួងបរិស្ថាន ដែលកំណត់ដោយបទបញ្ញត្តិដោយឡែក។

## ជំពូកទី៥
## សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវលើការងារគ្រប់គ្រងសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងមានសុវត្ថិភាពបរិស្ថាន។

**មាត្រា៣១.-**

ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រដ្ឋបាលរាជធានី ក្រុង ស្រុកអាចៈ

ក. រៀបចំ និងប្រតិបត្តិការដោយរដ្ឋបាលរបស់ខ្លួនផ្ទាល់នូវមុខងារមួយផ្នែក ឬទាំងស្រុងនៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ខ. ធ្វើកិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ដែលមានព្រំប្រទល់រដ្ឋបាលជាប់គ្នាក្នុងការផ្តល់សេវារួមជាមួយគ្នា។

គ. ផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូន ឬ/និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនទៅឱ្យផ្នែកឯកជន ជាអ្នកទទួលបន្ទុកអនុវត្ត។

ឃ. ផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ឬផ្តល់សិទ្ធិទៅឱ្យសហគមន៍អនុវត្តនូវមុខងារណាមួយ ឬមួយចំនួននៃមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន។

**មាត្រា៣២.-**

ការផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនត្រូវមានរយៈពេលមិនលើសពី១០ឆ្នាំក្នុងកិច្ចសន្យាមួយលើក និងត្រូវអនុវត្តទៅតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មជាធរមាន។

**មាត្រា៣៣.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយផ្អែកលើកម្រៃសេវាអតិបរមា ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់កម្រៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនសម្រាប់អនុវត្តនៅក្នុងមូលដ្ឋានរបស់ខ្លួន ដោយគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធានាប្រសិទ្ធភាព និងគុណភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- កំណត់កម្រៃសេវាផ្អែកតាមប្រភេទអាជីវកម្ម ទីតាំង កម្រិតប្រាក់ចំណូល បរិមាណសំរាម សំណល់រឹងទីប្រជុំជន ដែលត្រូវបញ្ចេញ និង
- ត្រូវមានការពិនិត្យ និងអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា៣៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវកំណត់អំពីវិធានការ និងនីតិវិធីសមស្រប មានតម្លាភាព និងមានប្រសិទ្ធភាពសម្រាប់ការប្រមូល ការគ្រប់គ្រង និងការទូទាត់កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ស្ថាប័ន និងអ្នកពាក់ព័ន្ធ។

ចំណូលដែលប្រមូលបានពីសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជាចំណូលផ្ទាល់របស់

រដ្ឋបាលរាជធានី ក្រុង ស្រុកសាមី។

រដ្ឋបាលរាជធានី ក្រុង ស្រុកអាចប្រើប្រាស់ថវិការបស់ខ្លួន ឬថវិកាពីប្រភពផ្សេងទៀត សម្រាប់គាំទ្របន្ថែមលើការចំណាយសម្រាប់ការផ្ដល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៣៥.-**

ក្នុងករណីមានសំណើពីសហគមន៍ អង្គការ ឬប្រជាពលរដ្ឋសុំការអនុញ្ញាតប្រមូលយកសំរាម សំណល់រឹងទីប្រជុំជនមកប្រើប្រាស់ក្នុងប្រយោជន៍ណាមួយ រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយមានការពិគ្រោះយោបល់ជាមួយមន្ទីរបរិស្ថានរាជធានី ខេត្តអាច ៖

ក. ពិនិត្យផ្ដល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនសម្រាប់យកទៅធ្វើការកែច្នៃធ្វើជីកំប៉ុស្ដិ៍ ផលិតឧស្ម័ន ប្រសិនបើសកម្មភាពប្រមូលយកសំរាមសំណល់រឹងនោះ មិនធ្វើឱ្យប៉ះពាល់ដល់ផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផលប៉ះពាល់ជាអវិជ្ជមានដល់ការរស់នៅនៃមជ្ឈដ្ឋានជុំវិញ និងបរិស្ថាន។

ខ. ផ្ដល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់កម្ទេចកម្ទីថ្ម និងដីចេញពីសកម្មភាពការដ្ឋានផ្លូវថ្នល់ សំណង់អគារ ឬលំនៅឋាន ដែលមិនមានលាយឡំសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផ្ទុកឬលាយឡំជាមួយសំណល់គ្រោះថ្នាក់ ដើម្បីយកទៅចាក់បំពេញរណ្ដៅដីកម្មសិទ្ធិសហគមន៍ អង្គការ ឬដីឯកជន។

## ជំពូកទី៦
## វិធានការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវធ្វើការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនឱ្យស្របតាមទីតាំងស្ថានភាពភូមិសាស្ត្រជាក់ស្ដែងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ចំពោះរដ្ឋបាលក្រុង ស្រុក ការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាមសំណល់រឹងទីប្រជុំជន ត្រូវមានការឯកភាពពីរដ្ឋបាលខេត្ត។

រាល់គម្រោងស្នើសុំបង្កើតទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនត្រូវស្នើសុំការពិនិត្យ សម្រេចពីក្រសួងបរិស្ថានលើបច្ចេកទេសរៀបចំទីលាន វិធានការការពារបរិស្ថានក្នុងពេលដំណើរការ និងពេលបិទបញ្ចប់ការប្រើប្រាស់ទីលាន និងរយៈពេលនៃការប្រើប្រាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣៧.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ត្រូវដំណើរការទីលានរបស់ខ្លួនតាមលក្ខខណ្ឌបច្ចេកទេស និងវិធានការការពារបរិស្ថាន តាមការកំណត់របស់ក្រសួងបរិស្ថាន។

ក្នុងករណីកើតមានហេតុការណ៍បំពុលបរិស្ថានបង្កដោយដំណើរការនៃទីលាន ម្ចាស់ ឬអ្នកគ្រប់

គ្រងទីលានត្រូវចាត់វិធានទប់ស្កាត់ជាបន្ទាន់ និងត្រូវផ្តល់ព័ត៌មានជាបន្ទាន់ទៅរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ និងមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា៣៨.-**

ក្រសួងបរិស្ថាន និងរដ្ឋបាលរាជធានី ខេត្តត្រូវចុះធ្វើការតាមដានត្រួតពិនិត្យជាប្រចាំលើការអនុវត្ត របស់ម្ចាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន នូវវិធានការទប់ស្កាត់និងកាត់បន្ថយផលប៉ះពាល់ បរិស្ថានពីដំណើរការគ្រប់គ្រងទីលាន។

## ជំពូកទី៧
## ទោសបញ្ញត្តិ

**មាត្រា៣៩.-**

ការមិនអនុវត្តតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌក្នុងការញែក និងការវេចខ្ចប់ ដោយឡែកនូវសំរាម សំណល់រឹងទីប្រជុំជនដែលអាចប្រើប្រាស់ឡើងវិញឬកែច្នៃបាន ដូចមានចែងក្នុង មាត្រា១៥នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ១០.០០០ (មួយម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១០០.០០០ (មួយសែន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ២០០.០០០ (ពីរសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ លើកមុន។

**មាត្រា៤០.-**

បុគ្គលដែលនាំយកកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជន ទៅដាក់នៅតាមដងផ្លូវ ឬទី សាធារណៈខុសពេលម៉ោងអនុញ្ញាតឱ្យធ្វើការបញ្ចេញ ដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៧នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំង សិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ លើកមុន។

**មាត្រា៤១.-**

បុគ្គលដែលបានប្រើប្រាស់សេវាគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន ហើយមិនព្រមបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន ឬសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលរៀបចំ ឬកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៨ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃតម្លៃសេវាសំរាម សំណល់រឹងដែលត្រូវបង់ក្នុងមួយខែ។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤២.-**

បុគ្គលដែលបោះចោលសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌហាមឃាត់ការបោះចោលសំរាម សំណល់រឹងទីប្រជុំជន ដូចមានចែងក្នុងមាត្រា២០ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូល សំអាត យកទៅដាក់ធុងសំរាមសាធារណៈ
- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមផ្ទះ ភោជនីយដ្ឋាន ទីកំសាន្ត និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៣.-**

បុគ្គលដែលដុតសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានីឬខណ្ឌ ក្រុង ស្រុកហាមឃាត់ ដូចមានចែងក្នុងមាត្រា២០នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូលសំអាត
- ចំនួន ១០០.០០០ (មួយសែន) រៀល ចំពោះម្ចាស់លំនៅឋាន អ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលសំអាត

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ ភោជនីយដ្ឋាន ទីកំសាន្ត អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៤.-**

បុគ្គលដែលគេចវេសមិនទទួលខុសត្រូវលើសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតនៅក្នុងពិធីនានារបស់ខ្លួនដែលប្រារព្ធនៅលើដងផ្លូវ ឬនៅលើទីសាធារណៈ ដូចមានចែងក្នុងមាត្រា២១នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់បន្ថែមទៅលើតម្លៃសេវាសំអាត ប្រមូលនិងដឹកជញ្ជូនដូចខាងក្រោម៖

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះពិធីមង្គលការ សម្ពោធហាង និងបុណ្យ លើកលែងពិធីបុណ្យសព
- ចំនួន ៦០០.០០០ (ប្រាំមួយសែន) រៀល ចំពោះពិធីប្រជុំ មិទ្ទិញ
- ចំនួន ២.០០០.០០០ (ពីរលាន) រៀល ចំពោះការប្រគុំតន្ត្រីសាធារណៈ

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៥.-**

បុគ្គលម្ចាស់ ឬអ្នកគ្រប់គ្រងទីផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម មណ្ឌលកំសាន្ត ដែលមិនបានរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណសម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន ដូចមានចែងក្នុងវាក្យខណ្ឌ២ មាត្រា២២នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួន៤០០.០០០(បួនសែន) រៀល។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៦.-**

បុគ្គលម្ចាស់ការដ្ឋានសំណង់អគារដែលធ្វើការទុកដាក់សំរាម សំណល់រឹងទីប្រជុំជនពីការងារសំណង់ ឬសម្ភារៈសំណង់មិនបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬការទុកដាក់បង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព ឬបរិស្ថាន ដូចមានចែងក្នុងមាត្រា២៣នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះការដ្ឋានសំណង់លំនៅឋាន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន

- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល ចំពោះការដ្ឋានសំណង់អគារធំៗ បុរីលំនៅឋាន និង ត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៧.-**

បុគ្គលដែលធ្វើអាជីវកម្មបូមសំណល់កក់ពីប្រព័ន្ធលូ ឬពីអាងស៊ិបទិក ដោយមិនមានលិខិតអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬដឹកយកទៅបញ្ចេញចោលខុសទីកន្លែងដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ដូចមានចែងក្នុងមាត្រា២៧នៃអនុក្រឹត្យនេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះអាជីវកម្មជាលក្ខណៈគ្រួសារ
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះអាជីវកម្មជាលក្ខណៈក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៨.-**

បុគ្គលដែលធ្វើការទុកដាក់ វេចខ្ចប់ ឬប្រមូលនិងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន លាយឡំជាមួយសំណល់រឹងឧស្សាហកម្ម សំណល់វេជ្ជសាស្ត្រ ឬសំណល់គ្រោះថ្នាក់ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ៥០០.០០០ (ប្រាំសែន) រៀល សម្រាប់អាជីវកម្ម សិប្បកម្ម មន្ទីរពេទ្យ សម្ភព
- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល សម្រាប់ក្រុមហ៊ុនសេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៩.-**

បុគ្គលដែលមិនបានបង់ប្រាក់ពិន័យអន្តរការណ៍នេះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃដែលបានទទួលបង្កាន់ដៃបង់ប្រាក់ពិន័យ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាពីរដង បើលើសពី៦០(ហុកសិប)ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាបីដង។ បើផុតរយៈពេល៩០(កៅសិប)ថ្ងៃ រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំសំណុំឯកសារប្ដឹងទៅសាលាដំបូងរាជធានី ខេត្ត។

**មាត្រា៥០.-**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចផាកពិន័យអន្តរការណ៍របស់មន្ត្រីមានសមត្ថកិច្ចរបស់រាជធានី ក្រុង ស្រុក ខណ្ឌ មានសិទ្ធិប្តឹងតវ៉ាទៅអភិបាលរាជធានី ក្រុង ស្រុក ខណ្ឌសាមី។

អភិបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ យ៉ាងយូរគិតពីថ្ងៃទទួលពាក្យបណ្តឹង។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រាជធានី ក្រុង ស្រុក ខណ្ឌមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន។

**មាត្រា៥១.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវក្នុងការរៀបចំយន្តការសម្រាប់អនុវត្តវិធានការពិន័យអន្តរការណ៍ឱ្យមានប្រសិទ្ធភាព។

នីតិវិធីនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ចំណូលពីការពិន័យអន្តរការណ៍នេះនឹងត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ។

## ជំពូកទី៨
## អន្តរបញ្ញត្តិ

**មាត្រា៥២.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវពិនិត្យការអនុវត្តកិច្ចសន្យាកន្លងមក និងធ្វើការពិភាក្សាពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវា ព្រមទាំងអ្នកពាក់ព័ន្ធនានាដើម្បីពិនិត្យនិងកែសម្រួលនូវកិច្ចសន្យាផ្តល់សេវាសំរាម សំណល់រឹងដែលកំពុងអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងរយៈពេល១២(ដប់ពីរ)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា ៥៣.-**

ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបង្កើតក្រុមការងារអន្តរក្រសួងមួយ ដើម្បីពិភាក្សា និងសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ទេរការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងប្រតិភូកម្មការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ។

## ជំពូកទី៩
## អវសានបញ្ញត្តិ

**មាត្រា៥៤.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្តេចក្រឡាហោម ស ខេង**

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សាយ សំអាល់**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥៥*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ឧបសម្ព័ន្ធទី៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**
លេខ :០០៥/២៣ សណន.រ

## សេចក្ដីណែនាំ
## ស្ដីពី
## ការចូលរួមលើកកម្ពស់សោភណភាព និងការថែរក្សាអនាម័យ-បរិស្ថាន ក្នុងអំឡុងពេលរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ចាប់ពីថ្ងៃទី០៥ ដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ចាប់ពីថ្ងៃទី០៣ ដល់ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៣ នៅរាជធានីភ្នំពេញ

**ព្រះរាជាណាចក្រកម្ពុជា** នឹងធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ចាប់ពីថ្ងៃទី០៥ ដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ចាប់ពី ថ្ងៃទី០៣ ដល់ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៣ នាពេលខាងមុខនេះ ដូច្នេះ ដើម្បីចូលរួមអបអរសាទរក្នុងព្រឹត្តិការណ៍ជាកំណត់ត្រាប្រវត្តិសាស្ត្រជាតិឱ្យប្រព្រឹត្តទៅដោយរលូន ជោគជ័យ និងអធិកអធម សំដៅចូលរួមចំណែកលើកកម្ពស់កិត្យានុភាពជាតិ ធានាបាននូវសោភ័ណភាព និងអនាម័យ-បរិស្ថានស្អាត រដ្ឋបាលរាជធានីភ្នំពេញសូមធ្វើការណែនាំដូចខាងក្រោម៖

១- គ្រប់លំនៅឋាន ផ្សារទំនើប អគារពាណិជ្ជកម្ម រោងចក្រ សហគ្រាស រមណីយដ្ឋាន មជ្ឈមណ្ឌលកម្សាន្ត សំណង់បុរី មូលដ្ឋានអាជីវកម្មទេសចរណ៍ (ដូចជាសណ្ឋាគារ ខុនដូ ភោជនីយដ្ឋានជាអាទ៍) និងមូលដ្ឋានអាជីវកម្មគ្រប់ប្រភេទផ្សេងទៀត សូមចងទង់ជាតិ ដោយដាក់ដងឱ្យបានត្រឹមត្រូវ និងរៀបចំតុបតែង លម្អ ភ្លើងពណ៌ នៅមុខគេហដ្ឋាន លើអគារ តាមរបង និងនៅមុខមូលដ្ឋានអាជីវកម្មរបស់ខ្លួនឱ្យបានផុលផុស ។ ទង់ជាតិត្រូវមានលក្ខណៈត្រឹមត្រូវស្របតាមអត្តសញ្ញាណជាតិ និងត្រូវចងឱ្យមានរបៀបរៀបរយល្អ ព្រមទាំងត្រូវពិនិត្យមើលក្រណាត់ទង់ជាតិ ចៀសវាងប្រើប្រាស់ក្រណាត់ដាច់រហែក ស្លក់ពណ៌ ឬទក់ ដែលធ្វើឱ្យបាត់បង់សោភណភាព

២- គ្រប់គ្រឹះស្ថានរដ្ឋ-ឯកជន ផ្សារទំនើប អគារពាណិជ្ជកម្ម រោងចក្រ-សហគ្រាស រមណីយដ្ឋាន មជ្ឈមណ្ឌលកម្សាន្ត សំណង់បុរី និងមូលដ្ឋានអាជីវកម្មគ្រប់ប្រភេទនៅក្នុងរាជធានីភ្នំពេញ សូម៖
- ចងបដាពាក្យស្លោក ដែលមានខ្លឹមសារឆ្លុះបញ្ចាំងពីការអភិវឌ្ឍជាតិ និងព្រឹត្តិការណ៍ប្រកួតកីឡាទាំងពីរនេះ ដោយត្រូវចងតាមលក្ខណៈបច្ចេកទេស និងសមស្របតាមទំហំអគារ ឬទីតាំងរបស់ខ្លួនចៀសវាងបង្កគ្រោះថ្នាក់ និងបាត់បង់សោភណភាព
- រៀបចំបំពាក់ខ្សែភ្លើងពណ៌បំភ្លឺ និងដាក់គោមភ្លើងបំភ្លឺនៅតាមរបងនៅមុខអគារ ឬតាមជញ្ជាំងអគារ ឬដើមឈើ និងមូលដ្ឋានអាជីវកម្មរបស់ខ្លួន ឱ្យមានភាពទាក់ទាញ និងសោភណភាព
- នៅមុខទីតាំងផ្សារទំនើប និងអគារពាណិជ្ជកម្មធំៗ ដែលមានសួនច្បារ និងទឹកបាញ់ ត្រូវរៀបចំតុបតែងលម្អភ្លើងពណ៌បំភ្លឺចម្រុះពណ៌ ហើយទីតាំងដែលមានបំពាក់ទូរទស្សន៍ LED ត្រូវចាក់ផ្សាយអំពីសកម្មភាព និងខ្លឹមសារផ្សេងៗពាក់ព័ន្ធនឹងព្រឹត្តិការណ៍ប្រកួតកីឡានេះ
- សម្រាប់មូលដ្ឋានអាជីវកម្មទេសចរណ៍ ត្រូវដាក់ពាក្យស្លោក ផ្សព្វផ្សាយ និងប្រើប្រាស់ខ្លឹមសារ និងនិមិត្តសញ្ញាផ្សព្វផ្សាយ "ឆ្នាំទស្សនាកម្ពុជា ២០២៣" (**Visit Cambodia Year 2023**) ដើម្បីផ្សារភ្ជាប់ជាមួយនឹងនិមិត្តសញ្ញា "ព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣" ជាមួយរូបតំណាង "បូរី និងរំដួល" និងពាក្យស្លោក "កម្ពុជាព្រះរាជាណាចក្រអច្ឆរិយ ផ្ដល់ភាពកក់ក្ដៅ" និង "គ្រប់ថ្ងៃ គឺជាអច្ឆរិយភាព" (**Every Day Is A Wonder**)



a

៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

៣- គ្រប់ផ្សាររដ្ឋ ផ្សារឯកជន ផ្សារមីនីម៉ាត (Mini Mart) ហាងលក់ទំនិញ ហាងលក់វត្ថុអនុស្សាវរីយ៍ និងមូលដ្ឋានអាជីវកម្មគ្រប់ប្រភេទនៅក្នុងរាជធានីភ្នំពេញត្រូវលក់ទំនិញដែលមានបិទស្លាកតម្លៃត្រឹមត្រូវ និងគុណភាពល្អ

៤- គ្រប់លំនៅឋាន មូលដ្ឋានអាជីវកម្ម និងការដ្ឋានសាងសង់សំណង់នានា នៅក្នុងរាជធានីភ្នំពេញ សូមចូលរួមថែរក្សា និងសម្អាតអនាម័យ-បរិស្ថាននៅតាមទីតាំងរបស់ខ្លួន ដោយត្រូវធ្វើការបោសសម្អាត ប្រមូលទុកដាក់ និងវេចខ្ចប់សំរាម ឬកាកសំណល់ផ្សេងៗឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងបញ្ចេញឱ្យបានទៀងទាត់តាមពេលវេលាកំណត់

៥- គ្រប់គេហដ្ឋាន និងមូលដ្ឋានអាជីវកម្មគ្រប់ប្រភេទនៅក្នុងរាជធានីភ្នំពេញ ត្រូវបញ្ឈប់ការហាលសម្លៀកបំពាក់ ឬសម្ភារៈប្រើប្រាស់ផ្សេងៗនៅខាងមុខ ឬលើដំបូលគេហដ្ឋានធ្វើឱ្យប៉ះពាល់ដល់សោភណភាព

៦- ដោយឡែកចំពោះទីតាំងដីទំនេរ និងម្ចាស់ការដ្ឋានសាងសង់សំណង់នានាស្ថិតនៅតាមបណ្តោយមហាវិថី និងវិថីសំខាន់ៗនានា ត្រូវរៀបចំធ្វើរបងបិទបាំងទីតាំងរបស់ខ្លួន ឬកែលម្អឱ្យមានសោភណភាព និងរបៀបរៀបរយល្អ

៧- បងប្អូនប្រជាពលរដ្ឋ និងគ្រប់មូលដ្ឋានអាជីវកម្មទាំងអស់ ត្រូវចូលរួមសហការជាមួយកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ដើម្បីរក្សាការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ឱ្យបានល្អប្រសើរក្នុងអំឡុងពេលរៀបចំព្រឹត្តិការណ៍ទាំងពីរនេះ សំដៅចូលរួមលើកកម្ពស់កិត្តិនាមរបស់ព្រះរាជាណាចក្រកម្ពុជា និង ប្រជាជនកម្ពុជាទាំងមូល

៨- រដ្ឋបាលខណ្ឌទាំង១៤ និងមន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ ត្រូវបំផុសចលនាប្រជាពលរដ្ឋ និងវិស័យឯកជនទាំងអស់ ឱ្យយល់ដឹងទូលំទូលាយពីសារសំខាន់ ដើម្បីបង្កើនការចូលរួមលើកទឹកចិត្ត និងគាំទ្រដល់ការរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាទាំងពីរនេះឱ្យបានផុលផុស និងអធិកអធម ។

រដ្ឋបាលរាជធានីភ្នំពេញសង្ឃឹមជឿជាក់ថា បងប្អូនប្រជាពលរដ្ឋ និងគ្រប់មូលដ្ឋានអាជីវកម្មទាំងអស់ នឹងផ្តល់ការយោគយល់អធ្យាស្រ័យ និងចូលរួមសហការអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ស្របតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ព្រមទាំងចូលរួមទស្សនា និងគាំទ្រព្រឹត្តិការណ៍កីឡាទាំងពីរនេះឱ្យបានកុះករ និងអធិកអធម ។

ទទួលបានសេចក្តីណែនាំនេះ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌទាំង១៤ និងមន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់៕

ថ្ងៃសុក្រ ៩កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល ៖**
- ក្រសួងមហាផ្ទៃ
- ក្រសួងទេសចរណ៍
- គណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣
  *"ដើម្បីគោរពជូនជ្រាប"*
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌទាំង១៤
- មន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ
  *"ដើម្បីសហការអនុវត្ត"*
- គ្រប់បណ្តាញសារព័ត៌មាន
  *"ដើម្បីជួយផ្សព្វផ្សាយ"*
- ឯកសារ-កាលប្បវត្តិ



៦៩ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

# ឧបសម្ព័ន្ធទី៨

ស្ថានីយបូមទឹកបឹងត្របែក




ការស្តារប្រឡាយទឹកបឹងត្របែក



ស្ថានីយបូមទឹកបឹងត្របែក



ការធ្វើគ្រឹះបាតបេតុងឆ្អឹងដែក ដែលស្ថិតនៅផ្លូវលេខ៤៧៨ ផ្លូវលេខ១៣៥ សង្កាត់ទួលទំពូងទី១



ការអ៊ុតកៅស៊ូផ្លូវលេខ៤៦៦ សង្កាត់ទន្លេបាសាក់




ការអ៊ុតកៅស៊ូ ស្ថិតក្នុងសង្កាត់ទន្លេបាសាក់



ការជួសជុលប្រព័ន្ធលូបង្ហូរ




ការធ្វើផ្លូវក្រាលកៅស៊ូ នៅតាមបណ្តោយផ្លូវលេខ៤៣២ ស្ថិតក្នុងសង្កាត់ទួលទំពូងទី១



ស្ពានបេតុងខ្សែកាប្លិ៍កោះនរា ឆ្លងពីទីក្រុងកោះពេជ្រ ទៅទីក្រុងកោះនរា



សម្អាត អនាម័យ បរិស្ថាន



ត្រួតពិនិត្យអាវុធជាតិផ្ទុះ

រៀបចំសោភ័ណភាពដងផ្លូវ




សម្អាតអនាម័យ និងបរិស្ថាន



រៀបចំសោភ័ណភាពដងផ្លូវ




ពីធីបើកការដ្ឋានគម្រោងមូលនិធិអភិវឌ្ឍន៍សង្កាត់



រៀបចំសម្អាត អនាម័យ បរិស្ថាន



ពិធីភ្ជាប់ស្ពានអាកាសមរតកតេជោ




ជ័យលាភីទីក្រុងស្អាត